[ ៦២៥ ] ធម៌ដ៏ថោកទាប ជាហេតុ អាស្រ័យនូវធម៌ដ៏ថោកទាប ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ដ៏ថោកទាប មិនមែនជាហេតុ អាស្រ័យនូវធម៌ដ៏ថោកទាប មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ដ៏ថោកទាប ជាហេតុ អាស្រ័យនូវធម៌ដ៏ថោកទាប ជាហេតុផង នូវធម៌ដ៏ថោកទាប មិនមែនជាហេតុ

ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦២៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦២៧ ] ធម៌ដ៏ថោកទាប ជាហេតុ អាស្រ័យនូវធម៌ដ៏ថោកទាប មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៦២៨ ] ធម៌ដ៏ថោកទាប ជាហេតុ អាស្រ័យនូវធម៌ដ៏ថោកទាប ជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ មានវារៈ ៣ ។ ធម៌ដ៏ថោកទាប មិនមែនជាហេតុ អាស្រ័យនូវធម៌ដ៏ថោកទាប មិនមែនជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ មានវារៈ ៣ ។ ធម៌ដ៏ថោកទាប ជាហេតុ អាស្រ័យនូវធម៌ដ៏ថោកទាប ជាហេតុផង នូវធម៌ដ៏ថោកទាប មិនមែនជាហេតុផង ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ មានវារៈ ៣ ។

[ ៦២៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុង

នវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៦៣០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៦៣១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។ សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៦៣២ ] ធម៌ដ៏ថោកទាប ជាហេតុ ជាបច្ច័យនៃធម៌ដ៏ថោកទាប ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៣៣ ] ធម៌ដ៏ថោកទាប ជាហេតុ ជាបច្ច័យនៃធម៌ដ៏ថោកទាប ជាហេតុ ដោយអារម្មណប្បច្ច័យ ។ ... ជាបច្ច័យដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ ។

[ ៦៣៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦៣៥ ] ធម៌ដ៏ថោកទាប ជាហេតុ ជាបច្ច័យនៃធម៌ដ៏ថោកទាប ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៦៣៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៦៣៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៦៣៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកហីនត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៦៣៩ ] ធម៌ជាកណ្តាល ជាហេតុ អាស្រ័យនូវធម៌ជាកណ្តាល ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៤០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦៤១ ] ធម៌ជាកណ្តាល មិនមែនជាហេតុ អាស្រ័យនូវធម៌ជាកណ្តាល មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៦៤២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ

មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៦៤៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៦៤៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។ សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៦៤៥ ] ធម៌ជាកណ្តាល ជាហេតុ ជាបច្ច័យនៃធម៌ជាកណ្តាល ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៤៦ ] ធម៌ជាកណ្តាល ជាហេតុ ជាបច្ច័យនៃធម៌ជាកណ្តាល ជាហេតុ ដោយអារម្មណប្បច្ច័យ ។ ... ជាបច្ច័យដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។

[ ៦៤៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦៤៨ ] ធម៌ជាកណ្តាល ជាហេតុ ជាបច្ច័យនៃធម៌ជាកណ្តាល ជា

ហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៦៤៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៦៥០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៦៥១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកហីនត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

# បដិច្ចវារៈ

[ ៦៥២ ] ធម៌ដ៏ប្រសើរ ជាហេតុ អាស្រ័យនូវធម៌ដ៏ប្រសើរ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ដ៏ប្រសើរ មិនមែនជាហេតុ អាស្រ័យនូវធម៌ដ៏ប្រសើរ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ដ៏ប្រសើរ ជាហេតុ អាស្រ័យនូវធម៌ដ៏ប្រសើរ ជាហេតុផង នូវធម៌ដ៏ប្រសើរ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៥៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុង

វិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគ-តប្បច្ច័យ មានវារៈ ៩ ។

[ ៦៥៤ ] ធម៌ដ៏ប្រសើរ ជាហេតុ អាស្រ័យនូវធម៌ដ៏ប្រសើរ ជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៦៥៥ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៦៥៦ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ព្រោះហេតុប្បច្ច័យ ។

[ ៦៥៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៦៥៨ ] ធម៌ដ៏ប្រសើរ ជាហេតុ ជាបច្ច័យនៃធម៌ដ៏ប្រសើរ ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៥៩ ] ធម៌ដ៏ប្រសើរ មិនមែនជាហេតុ ជាបច្ច័យនៃធម៌ដ៏ប្រសើរ មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៦៦០ ] ធម៌ដ៏ប្រសើរ ជាហេតុ ជាបច្ច័យនៃធម៌ដ៏ប្រសើរ ជាហេតុ

ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ មាន វារៈ ៣ ។

[ ៦៦១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មាន វារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុង អញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧប-និស្សយប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្ប-យុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦៦២ ] ធម៌ដ៏ប្រសើរ ជាហេតុ ជាបច្ច័យនៃធម៌ដ៏ប្រសើរ ជាហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៦៦៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៦៦៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៦៦៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយា-នុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយ

យ៉ាងណា ( ក្នុងហេតុទុកហីនត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាង នោះដែរ ។

ចប់ ហេតុទុកហីនត្តិកៈ ។

# ហេតុទុកមិច្ឆត្តត្តិកៈ

## បដិច្ចវារៈ

[ ៦៦៦ ] ធម៌មានសភាពខុសនិងទៀង ជាហេតុ អាស្រ័យនូវធម៌មានសភាពខុសនិងទៀង ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានសភាពខុសនិងទៀង មិនមែនជាហេតុ អាស្រ័យនូវធម៌មានសភាពខុសនិងទៀង មិនមែនជាហេតុ ទើបកើតឡើងព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានសភាពខុសនិងទៀង ជាហេតុ អាស្រ័យនូវធម៌មានសភាពខុសនិងទៀង ជាហេតុផង នូវធម៌មានសភាពខុសនិងទៀង មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៦៧ ] ធម៌មានសភាពខុសនិងទៀង ជាហេតុ អាស្រ័យនូវធម៌មានសភាពខុសនិងទៀង ជាហេតុ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៦៦៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុង

អញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦៦៩ ] ធម៌មានសភាពខុសនិងទៀង មិនមែនជាហេតុ អាស្រ័យនូវធម៌មានសភាពខុសនិងទៀង ជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៦៧០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ។

[ ៦៧១ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៦៧២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៦៧៣ ] ធម៌មានសភាពខុសនិងទៀង ជាហេតុ ជាបច្ច័យនៃធម៌មានសភាពខុសនិងទៀង ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៧៤ ] ធម៌មានសភាពខុសនិងទៀង មិនមែនជាហេតុ ជាបច្ច័យនៃធម៌មានសភាពខុសនិងទៀង មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ មានវារៈ ៣ ។

[ ៦៧៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦៧៦ ] ធម៌មានសភាពខុសនិងទៀង ជាហេតុ ជាបច្ច័យនៃធម៌មានសភាពខុសនិងទៀង ជាហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៦៧៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៦៧៨ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៦៧៩ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយ

យ៉ាងណា ( ក្នុងហេតុទុកមិច្ឆត្តត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាង
នោះដែរ ។

# បដិច្ចវារៈ

[ ៦៨០ ] ធម៌មានសភាពត្រូវនិងទៀង ជាហេតុ អាស្រ័យនូវធម៌មានសភាពត្រូវនិងទៀង ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានសភាពត្រូវនិងទៀង មិនមែនជាហេតុ អាស្រ័យនូវធម៌មានសភាពត្រូវនិងទៀង មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានសភាពត្រូវនិងទៀង ជាហេតុ អាស្រ័យនូវធម៌មានសភាពត្រូវនិងទៀង ជាហេតុផង នូវធម៌មានសភាពត្រូវនិងទៀង មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៨១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦៨២ ] ធម៌មានសភាពត្រូវនិងទៀង ជាហេតុ អាស្រ័យនូវធម៌មានសភាពត្រូវនិងទៀង ជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៦៨៣ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៦៨៤ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ព្រោះហេតុប្បច្ច័យ ។

[ ៦៨៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ព្រោះនអធិបតិប្បច្ច័យ ។ សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៦៨៦ ] ធម៌មានសភាពត្រូវនិងទៀង ជាហេតុ ជាបច្ច័យនៃធម៌មានសភាពត្រូវនិងទៀង ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៨៧ ] ធម៌មានសភាពត្រូវនិងទៀង ជាហេតុ ជាបច្ច័យនៃធម៌មានសភាពត្រូវនិងទៀង ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ មានវារៈ ៣ ។ ធម៌មានសភាពត្រូវនិងទៀង មិនមែនជាហេតុ ជាបច្ច័យនៃធម៌មានសភាពត្រូវនិងទៀង មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ មានវារៈ ៣ ។

[ ៦៨៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យមានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ

មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦៨៩ ] ធម៌មានសភាពត្រូវនិងទៀង ជាហេតុ ជាបច្ច័យនៃធម៌មានសភាពត្រូវនិងទៀង ជាហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៦៩០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៦៩១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៦៩២ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកមិច្ឆត្តត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៦៩៣ ] ធម៌មិនទៀង ជាហេតុ អាស្រ័យនូវធម៌មិនទៀង ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនទៀង មិនមែនជាហេតុ អាស្រ័យនូវធម៌មិនទៀង មិនមែនជាហេតុ ទើបកើតឡើងព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនទៀង ជាហេតុ អាស្រ័យនូវធម៌មិនទៀង ជាហេតុផង នូវធម៌មិនទៀង មិនមែនជាហេតុផង ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៩៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៦៩៥ ] ធម៌មិនទៀង មិនមែនជាហេតុ អាស្រ័យនូវធម៌មិនទៀង មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ ធម៌មិនទៀង ជាហេតុ អាស្រ័យនូវធម៌មិនទៀង មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៩៦ ] ធម៌មិនទៀង មិនមែនជាហេតុ អាស្រ័យនូវធម៌មិនទៀង ជាហេតុ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ ធម៌មិនទៀង មិនមែនជាហេតុ អាស្រ័យនូវធម៌មិនទៀង មិនមែនជាហេតុ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ ធម៌មិនទៀង មិនមែនជាហេតុ អាស្រ័យនូវធម៌មិនទៀង ជាហេតុផង នូវធម៌មិនទៀង មិនមែនជាហេតុផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។

[ ៦៩៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មាន

វារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៦៩៨ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៦៩៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៧០០ ] ធម៌មិនទៀង ជាហេតុ ជាបច្ច័យនៃធម៌មិនទៀង ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧០១ ] ធម៌មិនទៀង ជាហេតុ ជាបច្ច័យនៃធម៌មិនទៀង ជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧០២ ] ធម៌មិនទៀង ជាហេតុ ជាបច្ច័យនៃធម៌មិនទៀង ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌មិនទៀង មិនមែនជាហេតុ ជាបច្ច័យនៃធម៌មិនទៀង មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតា-

ធិបតិ មានវារៈ ៣ ។ ធម៌មិនទៀង ជាហេតុក្តី ធម៌មិនទៀង មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌មិនទៀង ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិនិងសហជាតាធិបតិ មានវារៈ ៣ ។

[ ៧០៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧០៤ ] ធម៌មិនទៀង ជាហេតុ ជាបច្ច័យនៃធម៌មិនទៀង ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៧០៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មាន

វារៈ ៩ ។

[ ៧០៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧០៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។ អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកមិច្ឆត្តត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ ហេតុទុកមិច្ឆត្តត្តិកៈ ។**

## ហេតុទុកមគ្គារម្មណត្តិកៈ

## បដិច្ចវារៈ

[ ៧០៨ ] ធម៌មានមគ្គជាអារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌មានមគ្គជាអារម្មណ៍ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានមគ្គជាអារម្មណ៍ មិនមែនជាហេតុ អាស្រ័យនូវធម៌មានមគ្គជាអារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានមគ្គជាអារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌មានមគ្គជាអារម្មណ៍ ជាហេតុផង នូវធម៌មានមគ្គជាអារម្មណ៍ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧០៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧១០ ] ធម៌មានមគ្គជាអារម្មណ៍ មិនមែនជាហេតុ អាស្រ័យនូវធម៌មានមគ្គជាអារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើងព្រោះនហេតុប្បច្ច័យ ។

[ ៧១១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៧១២ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៧១៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី
សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យ
ពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៧១៤ ] ធម៌មានមគ្គជាអារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាអារម្មណ៍ ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧១៥ ] ធម៌មានមគ្គជាអារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាអារម្មណ៍ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ មានវារៈ ៣ ។ ធម៌មានមគ្គជាអារម្មណ៍ មិនមែនជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាអារម្មណ៍ មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់សហ-ជាតាធិបតិ មានវារៈ ៣ ។

[ ៧១៦ ] ធម៌មានមគ្គជាអារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាអារម្មណ៍ ជាហេតុ ដោយអនន្តរប្បច្ច័យ ។

[ ៧១៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហា-រប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគ-តប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧១៨ ] ធម៌មានមគ្គជាអារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាអារម្មណ៍ ជាហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្ស-យប្បច្ច័យ ។

[ ៧១៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧២០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧២១ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។
អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកមគ្គារម្មណត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៧២២ ] ធម៌មានមគ្គជាហេតុ ជាហេតុ អាស្រ័យនូវធម៌មានមគ្គជាហេតុ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានមគ្គជាហេតុ មិនមែនជាហេតុ អាស្រ័យនូវធម៌មានមគ្គជាហេតុ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានមគ្គជាហេតុ ជាហេតុ អាស្រ័យនូវធម៌មានមគ្គជាហេតុ ជាហេតុផង នូវធម៌មានមគ្គជាហេតុ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧២៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩

ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧២៤ ] ធម៌មានមគ្គជាហេតុ ជាហេតុ អាស្រ័យនូវធម៌មានមគ្គជាហេតុ ជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៧២៥ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៧២៦ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ព្រោះហេតុប្បច្ច័យ ។

[ ៧២៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៧២៨ ] ធម៌មានមគ្គជាហេតុ ជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាហេតុ ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧២៩ ] ធម៌មានមគ្គជាហេតុ ជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាហេតុ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ មានវារៈ ៣ ។ ធម៌មានមគ្គជាហេតុ មិនមែនជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាហេតុ

មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ មានវារៈ ៣ ។

[ ៧៣០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៣១ ] ធម៌មានមគ្គជាហេតុ ជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាហេតុ ជាហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៧៣២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧៣៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧៣៤ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

> អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកមគ្គារម្មណត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

# បដិច្ចវារៈ

[ ៧៣៥ ] ធម៌មានមគ្គជាអធិបតិ ជាហេតុ អាស្រ័យនូវធម៌មានមគ្គជាអធិបតិ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានមគ្គជាអធិបតិ មិនមែនជាហេតុ អាស្រ័យនូវធម៌មានមគ្គជាអធិបតិ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានមគ្គជាអធិបតិ ជាហេតុ អាស្រ័យនូវធម៌មានមគ្គជាអធិបតិ ជាហេតុផង នូវធម៌មានមគ្គជាអធិបតិ មិនមែនជាហេតុផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧៣៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៣៧ ] ធម៌មានមគ្គជាអធិបតិ ជាហេតុ អាស្រ័យនូវធម៌មានមគ្គជាអធិបតិ ជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៧៣៨ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៧៣៩ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៧៤០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៧៤១ ] ធម៌មានមគ្គជាអធិបតិ ជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាអធិបតិ ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧៤២ ] ធម៌មានមគ្គជាអធិបតិ ជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាអធិបតិ ជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧៤៣ ] ធម៌មានមគ្គជាអធិបតិ ជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាអធិបតិ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌មានមគ្គជាអធិបតិ មិនមែនជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាអធិបតិ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ មានវារៈ ៣ ។ ធម៌មានមគ្គជាអធិបតិ ជាហេតុក្តី ធម៌មានមគ្គជាអធិបតិ មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌មានមគ្គជាអធិបតិ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ មានវារៈ ៣ ។

[ ៧៤៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧប-

និស្សយបច្ច័យ មានវារៈ ៩ ក្នុងអាសេវនបច្ច័យ មានវារៈ ៩ ក្នុងកម្មបច្ច័យ មានវារៈ ៣ ក្នុងអាហារបច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយបច្ច័យ មានវារៈ ៩ ក្នុងឈានបច្ច័យ មានវារៈ ៣ ក្នុងមគ្គបច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តបច្ច័យ មានវារៈ ៩ ក្នុងអត្ថិបច្ច័យ មានវារៈ ៩ ក្នុងអវិគតបច្ច័យ មានវារៈ ៩ ។

[ ៧៤៥ ] ធម៌មានមគ្គជាអធិបតិ មិនមែនជាហេតុ ជាបច្ច័យនៃធម៌មានមគ្គជាអធិបតិ ជាហេតុ ដោយអារម្មណបច្ច័យ ជាបច្ច័យដោយសហជាតបច្ច័យ ជាបច្ច័យដោយឧបនិស្សយបច្ច័យ ។

[ ៧៤៦ ] ក្នុងនហេតុបច្ច័យ មានវារៈ ៩ ក្នុងនអារម្មណបច្ច័យ មានវារៈ ៩ ។

[ ៧៤៧ ] ក្នុងនអារម្មណបច្ច័យ មានវារៈ ៣ ព្រោះហេតុបច្ច័យ ។

[ ៧៤៨ ] ក្នុងអារម្មណបច្ច័យ មានវារៈ ៩ ព្រោះនហេតុបច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមបច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកមគ្គារម្មណត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ ហេតុទុកមគ្គារម្មណត្តិកៈ ។**

# ហេតុទុកឧប្បន្នត្តិកៈ

## បញ្ហាវារៈ

[ ៧៤៩ ] ធម៌ដែលកើតឡើងហើយ ជាហេតុ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧៥០ ] ធម៌ដែលកើតឡើងហើយ មិនមែនជាហេតុ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៧៥១ ] ធម៌ដែលកើតឡើងហើយ ជាហេតុ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ មានវារៈ ៣ ។ ធម៌ដែលកើតឡើងហើយ មិនមែនជាហេតុ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ មានវារៈ ៣ ។

[ ៧៥២ ] ធម៌ដែលកើតឡើងហើយ ជាហេតុ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ជាហេតុ ដោយសហជាតប្បច្ច័យ ។

[ ៧៥៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ បុគ្គលអាស្រ័យនូវរដូវ ដែលកើតឡើងហើយ ញុំាងឈានឲ្យកើតឡើង ញុំាងវិបស្សនាឲ្យកើតឡើង ញុំាងមគ្គឲ្យកើតឡើង ញុំាងអភិញ្ញាឲ្យកើតឡើង ញុំាងសមាបត្តិ ឲ្យកើតឡើង ក្នុង

បុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៥៤ ] ធម៌ដែលកើតឡើងហើយ ជាហេតុ ជាបច្ច័យនៃធម៌ដែលកើតឡើងហើយ ជាហេតុ ដោយសហជាតប្បច្ច័យ ។

[ ៧៥៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧៥៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧៥៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកឧប្បន្នត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។ បដិច្ចវារៈក្តី សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ( ធម៌ ) មិនកើតហើយក្តី កំពុងកើតក្តី មិនមានក្នុងទុកត្តិកៈនេះទេ ។

**ចប់ ហេតុទុកឧប្បន្នត្តិកៈ ។**

# ហេតុទុកអតីតត្តិកៈ

## បញ្ហាវារៈ

[ ៧៥៨ ] ធម៌ជាបច្ចុប្បន្ន ជាហេតុ ជាបច្ច័យនៃធម៌ជាបច្ចុប្បន្ន ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧៥៩ ] ធម៌ជាបច្ចុប្បន្ន មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាបច្ចុប្បន្ន មិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៧៦០ ] ធម៌ជាបច្ចុប្បន្ន ជាហេតុ ជាបច្ច័យនៃធម៌ជាបច្ចុប្បន្ន ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌ជាបច្ចុប្បន្ន មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាបច្ចុប្បន្ន មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ មានវារៈ ៣ ។

[ ៧៦១ ] ធម៌ជាបច្ចុប្បន្ន ជាហេតុ ជាបច្ច័យនៃធម៌ជាបច្ចុប្បន្ន ជាហេតុ ដោយសហជាតប្បច្ច័យ ។

[ ៧៦២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យមានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យមានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុង

សម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៦៣ ] ធម៌ជាបច្ចុប្បន្ន ជាហេតុ ជាបច្ច័យនៃធម៌ជាបច្ចុប្បន្ន ជាហេតុ ដោយសហជាតប្បច្ច័យ ។

[ ៧៦៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧៦៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧៦៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកអតីតត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។ បដិច្ចវារៈក្តី សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី អតីតធម៌ក្តី អនាគតធម៌ក្តី មិនមានក្នុងទុកត្តិកៈនេះទេ ។

**ចប់ ហេតុទុកអតីតត្តិកៈ ។**

# ហេតុទុកអតីតារម្មណត្តិកៈ

# បដិច្ចវារៈ

[ ៧៦៧ ] ធម៌ជាអតីតារម្មណ៍ ( ធម៌មានអារម្មណ៍ជាអតីត ) ជាហេតុ អាស្រ័យនូវធម៌ជាអតីតារម្មណ៍ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអតីតារម្មណ៍ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាអតីតារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអតីតារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាអតីតារម្មណ៍ ជាហេតុផង នូវធម៌ជាអតីតារម្មណ៍ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧៦៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៦៩ ] ធម៌ជាអតីតារម្មណ៍ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាអតីតារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ ធម៌ជាអតីតារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាអតីតារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៧៧០ ] ធម៌ជាអតីតារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាអតីតារម្មណ៍ ជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៧៧១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៧៧២ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៧៧៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៧៧៤ ] ធម៌ជាអតីតារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌ជាអតីតារម្មណ៍ ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧៧៥ ] ធម៌ជាអតីតារម្មណ៍ជាហេតុ ជាបច្ច័យនៃធម៌ជាអតីតារម្មណ៍ជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧៧៦ ] ធម៌ជាអតីតារម្មណ៍ជាហេតុ ជាបច្ច័យនៃធម៌ជាអតីតារម្មណ៍ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌ជាអតីតារម្មណ៍ មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាអតីតារម្មណ៍ មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណា-

ធិបតិនិងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌ជាអតីតារម្មណ៍ ជាហេតុក្តី ជាអតីតារម្មណ៍ មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាអតីតារម្មណ៍ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ មានវារៈ ៣ ។

[ ៧៧៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៧៨ ] ធម៌ជាអតីតារម្មណ៍ជាហេតុ ជាបច្ច័យនៃធម៌ជាអតីតារម្មណ៍ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៧៧៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧៨០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧៨១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកអតីតារម្មណត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

# បដិច្ចវារៈ

[ ៧៨២ ] ធម៌ជាអនាគតារម្មណ៍ ( ធម៌មានអារម្មណ៍ជាអនាគត ) ជាហេតុ អាស្រ័យនូវធម៌ជាអនាគតារម្មណ៍ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអនាគតារម្មណ៍ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាអនាគតារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអនាគតារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាអនាគតារម្មណ៍ ជាហេតុផង នូវធម៌ជាអនាគតារម្មណ៍ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧៨៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៨៤ ] ធម៌ជាអនាគតារម្មណ៍ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាអនាគតារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ ធម៌ជាអនាគតារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាអនាគតារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៧៨៥ ] ធម៌ជាអនាគតារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាអនាគតារម្មណ៍ ជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៧៨៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៧៨៧ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៧៨៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៧៨៩ ] ធម៌ជាអនាគតារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌ជាអនាគតារម្មណ៍ ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧៩០ ] ធម៌ជាអនាគតារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌ជាអនាគតារម្មណ៍ ជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧៩១ ] ធម៌ជាអនាគតារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌ជាអនាគតារម្មណ៍ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និង

សហជាតាធិបតិ មានវារៈ ៣ ។ ធម៌ជាអនាគតារម្មណ៍ មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាអនាគតារម្មណ៍ មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌ជាអនាគតារម្មណ៍ ជាហេតុក្តី ធម៌ជាអនាគតារម្មណ៍ មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាអនាគតារម្មណ៍ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ មានវារៈ ៣ ។

[ ៧៩២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៩៣ ] ធម៌ជាអនាគតារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌ជាអនាគតារម្មណ៍ ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៧៩៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧៩៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧៩៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។ អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកអតីតារម្មណត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៧៩៧ ] ធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុ ទើបកើតឡើងព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាបច្ចុប្បន្នារម្មណ៍ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាបច្ចុប្បន្នារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុផង នូវធម៌ជាបច្ចុប្បន្នារម្មណ៍ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧៩៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៩៩ ] ធម៌ជាបច្ចុប្បន្នារម្មណ៍ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាបច្ចុប្បន្នារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

ធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាបច្ចុប្បន្នារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៨០០ ] ធម៌ជាបច្ចុប្បន្នារម្មណ៍ជាហេតុ អាស្រ័យនូវធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៨០១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៨០២ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៨០៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៨០៤ ] ធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៨០៥ ] ធម៌ជាបច្ចុប្បន្នារម្មណ៍ជាហេតុ ជាបច្ច័យនៃធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៨០៦ ] ធម៌ជាបច្ចុប្បន្នារម្មណ៍ជាហេតុ ជាបច្ច័យនៃធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌ជាបច្ចុប្បន្នារម្មណ៍ មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាបច្ចុប្បន្នារម្មណ៍ មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុក្តី ធម៌ជាបច្ចុប្បន្នារម្មណ៍ មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ មានវារៈ ៣ ។

[ ៨០៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨០៨ ] ធម៌ជាបច្ចុប្បន្នារម្មណ៍ជាហេតុ ជាបច្ច័យនៃធម៌ជាបច្ចុប្បន្នារម្មណ៍ ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៨០៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៨១០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៨១១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកអតីតារម្មណត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ ហេតុទុកអតីតារម្មណត្តិកៈ ។**

# ហេតុទុកអជ្ឈត្តត្តិកៈ

## បដិច្ចវារៈ

[ ៨១២ ] ធម៌ខាងក្នុង ជាហេតុ អាស្រ័យនូវធម៌ខាងក្នុង ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ខាងក្នុង មិនមែនជាហេតុ អាស្រ័យនូវធម៌ខាងក្នុង មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ខាងក្នុង ជាហេតុ អាស្រ័យនូវធម៌ខាងក្នុង ជាហេតុផង នូវធម៌ខាងក្នុង មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៨១៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មាន វារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨១៤ ] ធម៌ខាងក្នុង មិនមែនជាហេតុ អាស្រ័យនូវធម៌ខាងក្នុង មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ ធម៌ខាងក្នុង ជាហេតុ អាស្រ័យនូវធម៌ខាងក្នុង មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៨១៥ ] ធម៌ខាងក្នុង មិនមែនជាហេតុ អាស្រ័យនូវធម៌ខាងក្នុង ជាហេតុ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ ធម៌ខាងក្នុង មិនមែនជាហេតុ អាស្រ័យនូវធម៌ខាងក្នុង មិនមែនជាហេតុ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ ធម៌ខាងក្នុង មិនមែនជាហេតុ អាស្រ័យនូវធម៌ខាងក្នុង ជាហេតុផង នូវធម៌ខាងក្នុង មិនមែនជាហេតុផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។

[ ៨១៦ ] ធម៌ខាងក្នុង ជាហេតុ អាស្រ័យនូវធម៌ខាងក្នុង ជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៨១៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មាន វារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មាន

វារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ១ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងឈានប្បច្ច័យ មានវារៈ ១ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្ប-យុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោ-នត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៨១៨ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៨១៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៨២០ ] ធម៌ខាងក្នុង ជាហេតុ ជាបច្ច័យនៃធម៌ខាងក្នុង ជាហេតុដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៨២១ ] ធម៌ខាងក្នុង ជាហេតុ ជាបច្ច័យនៃធម៌ខាងក្នុង ជាហេតុដោយអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៨២២ ] ធម៌ខាងក្នុង ជាហេតុ ជាបច្ច័យនៃធម៌ខាងក្នុង ជាហេតុដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ មាន

ភារៈ ៣ ។ ធម៌ខាងក្នុង មិនមែនជាហេតុ ជាបច្ច័យនៃធម៌ខាងក្នុង មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ មានភារៈ ៣ ។ ធម៌ខាងក្នុងជាហេតុក្តី ធម៌ខាងក្នុងមិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ខាងក្នុង ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ មានភារៈ ៣ ។

[ ៨២៣ ] ក្នុងហេតុប្បច្ច័យ មានភារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានភារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានភារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានភារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានភារៈ ៩ ក្នុងសហជាតប្បច្ច័យ មានភារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានភារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានភារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានភារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានភារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានភារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានភារៈ ៩ ក្នុងកម្មប្បច្ច័យ មានភារៈ ៣ ក្នុងវិបាកប្បច្ច័យ មានភារៈ ៩ ក្នុងអាហារប្បច្ច័យ មានភារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានភារៈ ៩ ក្នុងឈានប្បច្ច័យ មានភារៈ ៣ ក្នុងមគ្គប្បច្ច័យ មានភារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានភារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានភារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានភារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានភារៈ ៩ ក្នុងវិគតប្បច្ច័យ មានភារៈ ៩ ក្នុងអវិគតប្បច្ច័យ មានភារៈ ៩ ។

[ ៨២៤ ] ធម៌ខាងក្នុង ជាហេតុ ជាបច្ច័យនៃធម៌ខាងក្នុង ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយ

ឧបនិស្សយប្បច្ច័យ ។

[ ៨២៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៨២៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៨២៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកអជ្ឈត្តត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៨២៨ ] ធម៌ខាងក្រៅ ជាហេតុ អាស្រ័យនូវធម៌ខាងក្រៅ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨២៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨៣០ ] ធម៌ខាងក្រៅ មិនមែនជាហេតុ អាស្រ័យនូវធម៌ខាងក្រៅ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ ធម៌ខាងក្រៅ ជាហេតុ អាស្រ័យនូវធម៌ខាងក្រៅ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៨៣១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៨៣២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៨៣៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៨៣៤ ] ធម៌ខាងក្រៅ ជាហេតុ ជាបច្ច័យនៃធម៌ខាងក្រៅ ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៨៣៥ ] ធម៌ខាងក្រៅ ជាហេតុ ជាបច្ច័យនៃធម៌ខាងក្រៅ ជាហេតុ

ដោយអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៨៣៦ ] ធម៌ខាងក្រៅ ជាហេតុ ជាបច្ច័យនៃធម៌ខាងក្រៅ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌ខាងក្រៅ មិនមែនជាហេតុ ជាបច្ច័យនៃធម៌ខាងក្រៅ មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌ខាងក្រៅ ជាហេតុក្តី ធម៌ខាងក្រៅ មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ខាងក្រៅ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ មានវារៈ ៣ ។

[ ៨៣៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨៣៨ ] ធម៌ខាងក្រៅ ជាហេតុ ជាបច្ច័យនៃធម៌ខាងក្រៅ ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៨៣៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៨៤០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៨៤១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយា-នុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយ យ៉ាងណា ( ក្នុងហេតុទុកអជ្ឈត្តត្តិកៈ ) បណ្ឌិតគប្បីរាប់ យ៉ាងនោះដែរ ។ អជ្ឈត្តពហិទ្ធាធម៌ទាំងឡាយ បណ្ឌិតមិនបាច់ និយាយឡើយ ។

**ចប់ ហេតុទុកអជ្ឈត្តត្តិកៈ ។**

## ហេតុទុកអជ្ឈត្តារម្មណត្តិកៈ

## បដិច្ចវារៈ

[ ៨៤២ ] ធម៌ជាអជ្ឈត្តារម្មណ៍ ( ធម៌មានអារម្មណ៍ជាខាងក្នុង ) ជាហេតុ អាស្រ័យនូវធម៌ជាអជ្ឈត្តារម្មណ៍ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអជ្ឈត្តារម្មណ៍ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាអជ្ឈត្តារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអជ្ឈត្តារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាអជ្ឈត្តារម្មណ៍ ជាហេតុផង នូវធម៌ជាអជ្ឈត្តារម្មណ៍ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៨៤៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨៤៤ ] ធម៌ជាអជ្ឈត្តារម្មណ៍ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាអជ្ឈត្តារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ ធម៌ជាអជ្ឈត្តារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាអជ្ឈត្តារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៨៤៥ ] ធម៌ជាអជ្ឈត្តារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាអជ្ឈត្តារម្មណ៍ ជាហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៨៤៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៨៤៧ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៨៤៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៨៤៩ ] ធម៌ជាអជ្ឈត្តារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌ជាអជ្ឈត្តារម្មណ៍ ជាហេតុ ដោយហេតុប្បច្ច័យ ។

[ ៨៥០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨៥១ ] ធម៌ជាអជ្ឈត្តារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌ជាអជ្ឈត្តារម្មណ៍ ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៨៥២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៨៥៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៨៥៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកអជ្ឈត្តារម្មណត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៨៥៥ ] ធម៌ជាពហិទ្ធារម្មណ៍ ជាហេតុ អាស្រ័យនូវធម៌ជាពហិទ្ធារម្មណ៍ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៥៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨៥៧ ] ធម៌ជាពហិទ្ធារម្មណ៍ មិនមែនជាហេតុ អាស្រ័យនូវធម៌ជា

ពហិទ្ធារម្មណ៍ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៨៥៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៨៥៩ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៨៦០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៨៦១ ] ធម៌ជាពហិទ្ធារម្មណ៍ ( ធម៌មានអារម្មណ៍ខាងក្រៅ ) ជាហេតុ ជាបច្ច័យនៃធម៌ជាពហិទ្ធារម្មណ៍ ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៨៦២ ] ធម៌ជាពហិទ្ធារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌ជាពហិទ្ធារម្មណ៍ ជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៨៦៣ ] ធម៌ជាពហិទ្ធារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌ជាពហិទ្ធារម្មណ៍ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ មានវារៈ

៣ ។ ធម៌ជាពហិទ្ធារម្មណ៍ មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាពហិទ្ធារម្មណ៍ មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ មានវារៈ ៣ ។

[ ៨៦៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨៦៥ ] ធម៌ជាពហិទ្ធារម្មណ៍ ជាហេតុ ជាបច្ច័យនៃធម៌ជាពហិទ្ធារម្មណ៍ ជាហេតុ ជាបច្ច័យដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៨៦៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៨៦៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៨៦៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកអជ្ឈត្តារម្មណត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ ហេតុទុកអជ្ឈត្តារម្មណត្តិកៈ ។**

# ហេតុទុកសនិទស្សនសប្បដិឃត្តិកៈ

# បដិច្ចវារៈ

[ ៨៦៩ ] ធម៌ជាអនិទស្សនសប្បដិឃៈ ( ធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ) មិនមែនជាហេតុ អាស្រ័យនូវធម៌ជាអនិទស្សនសប្បដិឃៈ មិនមែនជាហេតុ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។ ... ព្រោះអធិបតិប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យនិងអវិគតប្បច្ច័យ ។

[ ៨៧០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ១ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ១ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងឈានប្បច្ច័យ មានវារៈ ១ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ៨៧១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ។ បច្ច័យទាំងអស់ បណ្ឌិតគប្បីធ្វើឲ្យផងចុះ ។បេ។ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

## បញ្ហាវារៈ

[ ៨៧២ ] ធម៌ជាអនិទស្សនសប្បដិឃៈ មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាអនិទស្សនសប្បដិឃៈ មិនមែនជាហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យដោយនិស្សយប្បច្ច័យ ជាបច្ច័យដោយអត្ថិប្បច្ច័យ ជាបច្ច័យដោយអវិគតប្បច្ច័យ ។ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ១ ។

[ ៨៧៣ ] ធម៌ជាអនិទស្សនអប្បដិឃៈ ( ធម៌មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ ) ជាហេតុ អាស្រ័យនូវធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអនិទស្សនអប្បដិឃៈ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាអនិទស្សនអប្បដិឃៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ អាស្រ័យនូវធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុផង នូវធម៌ជាអនិទស្សនអប្បដិឃៈ មិនមែនជាហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៨៧៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨៧៥ ] ធម៌ជាអនិទស្សនអប្បដិឃៈ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាអនិទស្សនអប្បដិឃៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ ធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ អាស្រ័យនូវធម៌ជាអនិ-

ទស្សនេអប្បដិយៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៨៧៦ ] ធម៌ជាអនិទស្សនេអប្បដិយៈ មិនមែនជាហេតុ អាស្រ័យនូវធម៌ជាអនិទស្សនេអប្បដិយៈ មិនមែនជាហេតុ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៨៧៧ ] ធម៌ជាអនិទស្សនេអប្បដិយៈ ជាហេតុ អាស្រ័យនូវធម៌ជាអនិទស្សនេអប្បដិយៈ ជាហេតុ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ ។

[ ៨៧៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៨៧៩ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៨៨០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

# បញ្ហាវារៈ

[ ៨៨១ ] ធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ ជាបច្ច័យនៃធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៨៨២ ] ធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ ជាបច្ច័យនៃធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៨៨៣ ] ធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ ជាបច្ច័យនៃធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌ជាអនិទស្សនអប្បដិឃៈ មិនមែនជាហេតុ ជាបច្ច័យនៃធម៌ជាអនិទស្សនអប្បដិឃៈ មិនមែនជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ និងសហជាតាធិបតិ មានវារៈ ៣ ។ ធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុក្តី ធម៌ជាអនិទស្សនអប្បដិឃៈ មិនមែនជាហេតុក្តី ជាបច្ច័យនៃធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ មានវារៈ ៣ ។

[ ៨៨៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ

មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨៨៥ ] ធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ ជាបច្ច័យនៃធម៌ជាអនិទស្សនអប្បដិឃៈ ជាហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៨៨៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៨៨៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៨៨៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកសនិទស្សនសប្បដិឃត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ ហេតុទុកសនិទស្សនសប្បដិឃត្តិកៈ ។**

# សហេតុទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ៨៨៩ ] កុសលធម៌ជាសហេតុកៈ ( ប្រកបដោយហេតុ ) អាស្រ័យនូវកុសលធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៩០ ] កុសលធម៌ ជាសហេតុកៈ អាស្រ័យនូវកុសលធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះអារម្មណាប្បច្ច័យ ។

[ ៨៩១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណាប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ៨៩២ ] កុសលធម៌ ជាសហេតុកៈ អាស្រ័យនូវកុសលធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៨៩៣ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ។

[ ៨៩៤ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។

[ ៨៩៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ព្រោះនអធិបតិប្បច្ច័យ ។ សហជាតវារៈក្ដី បច្ចយវារៈក្ដី និស្សយវារៈក្ដី សំសដ្ឋវារៈក្ដី សម្បយុត្តវារៈក្ដី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្ដារផងចុះ ។

## បញ្ហាវារៈ

[ ៨៩៦ ] កុសលធម៌ ជាសហេតុកៈ ជាបច្ច័យនៃកុសលធម៌ ជាសហេតុកៈ ដោយហេតុប្បច្ច័យ ។

[ ៨៩៧ ] កុសលធម៌ ជាសហេតុកៈ ជាបច្ច័យនៃកុសលធម៌ ជាសហេតុកៈ ដោយអារម្មណប្បច្ច័យ ។

[ ៨៩៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ១ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងឈានប្បច្ច័យ មានវារៈ ១ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគ-

តប្បច្ច័យ មានវារៈ ១ ។

[ ៨៩៩ ] កុសលធម៌ ជាសហេតុកៈ ជាបច្ច័យនៃកុសលធម៌ ជាសហេតុកៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៩០០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ។

[ ៩០១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។

[ ៩០២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងសហេតុកទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៩០៣ ] អកុសលធម៌ ជាសហេតុកៈ អាស្រ័យនូវអកុសលធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ជាសហេតុកៈ អាស្រ័យនូវអកុសលធម៌ ជាអហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ជាសហេតុកៈ អាស្រ័យនូវអកុសលធម៌ ជាសហេតុកៈផង នូវអកុសលធម៌ ជាអហេតុកៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩០៤ ] អកុសលធម៌ ជាសហេតុកៈ អាស្រ័យនូវអកុសលធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ អកុសលធម៌ ជាអហេតុកៈ អាស្រ័យនូវអកុសលធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ អកុសលធម៌ ជាសហេតុកៈក្តី អកុសលធម៌ ជាអហេតុកៈក្តី អាស្រ័យនូវអកុសលធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អកុសលធម៌ ជាសហេតុកៈ អាស្រ័យនូវអកុសលធម៌ ជាអហេតុកៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អកុសលធម៌ ជាសហេតុកៈ អាស្រ័យនូវអកុសលធម៌ ជាសហេតុកៈផង នូវអកុសលធម៌ ជាអហេតុកៈផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៩០៥ ] អកុសលធម៌ ជាសហេតុកៈ អាស្រ័យនូវអកុសលធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ ។

[ ៩០៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ក្នុងអាហារប្បច្ច័យ មានវារៈ ៥ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៥ ក្នុងឈានប្បច្ច័យ មានវារៈ ៥ ក្នុងមគ្គប្បច្ច័យ មានវារៈ ៥ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ

៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងវិគតប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៩០៧ ] អកុសលធម៌ ជាអហេតុកៈ អាស្រ័យនូវអកុសលធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៩០៨ ] អកុសលធម៌ ជាសហេតុកៈ អាស្រ័យនូវអកុសលធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៩០៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ។

[ ៩១០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៩១១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៩១២ ] អកុសលធម៌ ជាសហេតុកៈ ជាបច្ច័យនៃអកុសលធម៌ ជាសហេតុកៈ ដោយហេតុប្បច្ច័យ មានវារៈ ២ ។

[ ៩១៣ ] អកុសលធម៌ ជាសហេតុកៈ ជាបច្ច័យនៃអកុសលធម៌ ជាសហេតុកៈ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាអហេតុកៈ ជាបច្ច័យនៃអកុសលធម៌ ជាអហេតុកៈ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាសហេតុកៈក្តី អកុសលធម៌ ជាអហេតុកៈក្តី ជាបច្ច័យនៃអកុសលធម៌ ជាសហេតុកៈ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៩១៤ ] អកុសលធម៌ ជាសហេតុកៈ ជាបច្ច័យនៃអកុសលធម៌ ជាសហេតុកៈ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហ-ជាតាធិបតិ ។

[ ៩១៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិ-យប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ក្នុងអវិគ-តប្បច្ច័យ មានវារៈ ៥ ។

[ ៩១៦ ] អកុសលធម៌ ជាសហេតុកៈ ជាបច្ច័យនៃអកុសលធម៌ ជាសហេតុកៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៩១៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៩១៨ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។

[ ៩១៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងសហេតុកទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៩២០ ] អព្យាកតធម៌ ជាសហេតុកៈ អាស្រ័យនូវអព្យាកតធម៌ ជាសហេតុកៈ ទើបកើតឡើងព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាអហេតុកៈ អាស្រ័យនូវអព្យាកតធម៌ ជាអហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាសហេតុកៈ អាស្រ័យនូវអព្យាកតធម៌ ជាសហេតុកៈផង នូវអព្យាកតធម៌ ជាអហេតុកៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩២១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ។បេ។ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបា-កប្បច្ច័យ មានវារៈ ៩ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩២២ ] អព្យាកតធម៌ ជាអហេតុកៈ អាស្រ័យនូវអព្យាកតធម៌ ជាអហេតុកៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៩២៣ ] អព្យាកតធម៌ ជាអហេតុកៈ អាស្រ័យនូវអព្យាកតធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ អព្យាកតធម៌ ជាអហេតុកៈ អាស្រ័យនូវអព្យាកតធម៌ ជាអហេតុកៈ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ អព្យាកតធម៌ ជាអហេតុកៈ អាស្រ័យនូវអព្យាកតធម៌ ជាសហេតុកៈផង នូវអព្យាកតធម៌ ជាអហេតុកៈផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។

[ ៩២៤ ] អព្យាកតធម៌ ជាសហេតុកៈ អាស្រ័យនូវអព្យាកតធម៌ ជាសហេតុកៈ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៩២៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មាន

វារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងអាហារប្បច្ច័យ មានវារៈ ១ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងឈានប្បច្ច័យ មានវារៈ ១ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៩២៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៩២៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៩២៨ ] អព្យាកតធម៌ ជាសហេតុកៈ ជាបច្ច័យនៃអព្យាកតធម៌ ជាសហេតុកៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩២៩ ] អព្យាកតធម៌ ជាសហេតុកៈ ជាបច្ច័យនៃអព្យាកតធម៌ ជាសហេតុកៈ ដោយអារម្មណប្បច្ច័យ ។

[ ៩៣០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤

ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ៩៣១ ] អព្យាកតធម៌ ជាសហេតុកៈ ជាបច្ច័យនៃអព្យាកតធម៌ ជាសហេតុកៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៩៣២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ។

[ ៩៣៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៩៣៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងសហេតុកទុកកុសលត្តិកៈ ) បណ្ឌិតគប្បី

រាប់យ៉ាងនោះដែរ ។

ចប់ សហេតុកទុកកុសលត្តិកៈ ។

# ហេតុសម្បយុត្តទុកកុសលត្តិកៈ
# បដិច្ចវារៈ

[ ៩៣៥ ] កុសលធម៌ប្រកបដោយហេតុ អាស្រ័យនូវកុសលធម៌ប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៣៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ៩៣៧ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ។

[ ៩៣៨ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។

[ ៩៣៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៩៤០ ] កុសលធម៌ប្រកបដោយហេតុ ជាបច្ច័យនៃកុសលធម៌ប្រកបដោយហេតុ ដោយហេតុប្បច្ច័យ ។

[ ៩៤១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ៩៤២ ] កុសលធម៌ប្រកបដោយហេតុ ជាបច្ច័យនៃកុសលធម៌ប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៩៤៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ។

[ ៩៤៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។

[ ៩៤៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុសម្បយុត្តទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៩៤៦ ] អកុសលធម៌ ប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌

ប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ប្រកបដោយហេតុ អាស្រ័យនូវអកុ-សលធម៌ ប្រកបដោយហេតុផង នូវអកុសលធម៌ប្រាសចាកហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៤៧ ] អកុសលធម៌ប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ ប្រាសចាកហេតុ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អកុសលធម៌ ប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ ប្រកបដោយហេតុផង នូវអកុសលធម៌ ប្រាសចាកហេតុផង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៩៤៨ ] អកុសលធម៌ ប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ប្រកបដោយហេតុ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ ។

[ ៩៤៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ក្នុងអាហា-

បច្ចប្ប័យ មានវារៈ ៥ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៥ ក្នុងឈានប្បច្ច័យ មានវារៈ ៥ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៩៥០ ] អកុសលធម៌ ប្រាសចាកហេតុ អាស្រ័យនូវអកុសលធម៌ ប្រកបដោយហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៩៥១ ] អកុសលធម៌ ប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ ប្រកបដោយហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៩៥២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ។

[ ៩៥៣ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៩៥៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៩៥៥ ] អកុសលធម៌ ប្រកបដោយហេតុ ជាបច្ច័យនៃអកុសលធម៌

ប្រកបដោយហេតុ ដោយហេតុប្បច្ច័យ មានវារៈ ២ ។

[ ៩៥៦ ] អកុសលធម៌ ប្រកបដោយហេតុ ជាបច្ច័យនៃអកុសលធម៌ ប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រាសចាកហេតុ ជាបច្ច័យនៃអកុសលធម៌ ប្រាសចាកហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រកបដោយហេតុក្តី អកុសលធម៌ប្រាសចាកហេតុក្តី ជាបច្ច័យនៃអកុសលធម៌ ប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៩៥៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៩៥៨ ] អកុសលធម៌ ប្រកបដោយហេតុ ជាបច្ច័យនៃអកុសលធម៌ ប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៩៥៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៩៦០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។

[ ៩៦១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុទុកសម្បយុត្តទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៩៦២ ] អព្យាកតធម៌ប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌ប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រាសចាកហេតុ អាស្រ័យនូវអព្យាកតធម៌ ប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌ ប្រកបដោយហេតុផង នូវអព្យាកតធម៌ ប្រាសចាកហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៦៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុង

អញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩៦៤ ] អព្យាកតធម៌ ប្រាសចាកហេតុ អាស្រ័យនូវអព្យាកតធម៌ ប្រាសចាកហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៩៦៥ ] អព្យាកតធម៌ ប្រាសចាកហេតុ អាស្រ័យនូវអព្យាកតធម៌ ប្រកបដោយហេតុ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។

[ ៩៦៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៩៦៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៩៦៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៩៦៩ ] អព្យាកតធម៌ ប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៧០ ] អព្យាកតធម៌ ប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ។

[ ៩៧១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ៩៧២ ] អព្យាកតធម៌ ប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៩៧៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ។

[ ៩៧៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៩៧៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយា-
នុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយ
យ៉ាងណា ( ក្នុងហេតុសម្បយុត្តទុកកុសលត្តិកៈ ) បណ្ឌិត
គប្បីរាប់យ៉ាងនោះដែរ ។

**ចប់ ហេតុសម្បយុត្តទុកកុសលត្តិកៈ ។**

# ហេតុសហេតុកទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ៩៧៦ ] កុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើងព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ កុសលធម៌ប្រកបដោយហេតុ តែមិនមែនជាហេតុ អាស្រ័យនូវកុសលធម៌ប្រកបដោយហេតុ តែមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ កុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុផង នូវកុសលធម៌ប្រកបដោយហេតុ តែមិនមែនជាហេតុផង ទើបកើតឡើងព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៧៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុង

អវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩៧៨ ] កុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៩៧៩ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៩៨០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៩៨១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៩៨២ ] កុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយហេតុប្បច្ច័យ ។

[ ៩៨៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុង

អញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩៨៤ ] កុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៩៨៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៩៨៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៩៨៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុសហេតុកទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៩៨៨ ] អកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៨៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩៩០ ] អកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ មានវារៈ ៩ ។

[ ៩៩១ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៩៩២ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៩៩៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៩៩៤ ] អកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយហេតុប្បច្ច័យ ។

[ ៩៩៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩៩៦ ] អកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ៩៩៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៩៩៨ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៩៩៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុសហេតុកទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ១០០០ ] អព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០០១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុង

អវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០០២ ] អព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ១០០៣ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ១០០៤ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ១០០៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១០០៦ ] អព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយហេតុប្បច្ច័យ ។

[ ១០០៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុង

អញ្ញមញ្ញប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០០៨ ] អព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១០០៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១០១០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ១០១១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុសហេតុកទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ ហេតុសហេតុកទុកកុសលត្តិកៈ ។**

# ហេតុហេតុសម្បយុត្តទុកកុសលត្តិកៈ
# បដិច្ចវារៈ

[ ១០១២ ] កុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើងព្រោះហេតុប្បច្ច័យ កុសលធម៌ប្រកបដោយហេតុ តែមិនមែនជាហេតុ អាស្រ័យនូវកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០១៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០១៤ ] កុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ១០១៥ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ១០១៦ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ១០១៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ព្រោនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

# បញ្ហាវារៈ

[ ១០១៨ ] កុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយហេតុប្បច្ច័យ ។

[ ១០១៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០២០ ] កុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១០២១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១០២២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ១០២៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុហេតុសម្បយុត្តទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

# បដិច្ចវារៈ

[ ១០២៤ ] អកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០២៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០២៦ ] អកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ១០២៧ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ នបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ១០២៨ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ១០២៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១០៣០ ] អកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយហេតុប្បច្ច័យ ។

[ ១០៣១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០៣២ ] អកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអកុសលធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១០៣៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១០៣៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ១០៣៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុហេតុសម្បយុត្តទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ១០៣៦ ] អព្យាកតធម៌ជាហេតុទាំងប្រកបដោយហេតុ អាស្រ័យនូវអព្យា-

កតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។

[ ១០៣៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០៣៨ ] អព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ១០៣៩ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ១០៤០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ១០៤១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១០៤២ ] អព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយហេតុប្បច្ច័យ ។

[ ១០៤៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០៤៤ ] អព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១០៤៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១០៤៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ១០៤៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងហេតុហេតុសម្បយុត្តទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ ហេតុហេតុសម្បយុត្តទុកកុសលត្តិកៈ ។**

## នហេតុសហេតុកទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១០៤៨ ] កុសលធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវកុសលធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០៤៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ១០៥០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ។

ឯក្នុងបញ្ហាវារៈ បច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

## បដិច្ចវារៈ

[ ១០៥១ ] អកុសលធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០៥២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ហេតុប្បច្ច័យ មិនមានទេ ។ ឯក្នុងបញ្ហាវារៈ បច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។ ឯក្នុងបញ្ហាវារៈ ហេតុប្បច្ច័យនៃធម៌ទាំង ៣ នេះ មិនមានទេ ។

# បដិច្ចវារៈ

[ ១០៥៣ ] អព្យាកតធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌មិនមែនជាហេតុ តែប្រកបដោយហេតុក្តី អព្យាកតធម៌មិនមែនជាហេតុ ទាំងមិនមានហេតុក្តី អាស្រ័យនូវអព្យាកតធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌មិនមែនជាហេតុ តែប្រកបដោយហេតុផង នូវអព្យាកតធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ១០៥៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុង

វិបាកប្បច្ច័យ មានវារៈ ៩ ក្នុងវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០៥៥ ] អព្យាកតធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ១០៥៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១០៥៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ១០៥៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

# បញ្ហាវារៈ

[ ១០៥៩ ] អព្យាកតធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ។

[ ១០៦០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ១០៦១ ] អព្យាកតធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១០៦២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ

មានវារៈ ៧ ។

[ ១០៦៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ព្រោះអារម្មណប្បច្ច័យ ។

[ ១០៦៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងនហេតុសហេតុកទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ នហេតុសហេតុកទុកកុសលត្តិកៈ ។**

**ចប់ ហេតុគោច្ឆកទុកត្តិកៈ ។**

# សប្បច្ចយទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១០៦៥ ] កុសលធម៌ ប្រកបដោយបច្ច័យ អាស្រ័យនូវកុសលធម៌ ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០៦៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ១០៦៧ ] កុសលធម៌ ប្រកបដោយបច្ច័យ អាស្រ័យនូវកុសលធម៌ ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ១០៦៨ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១០៦៩ ] កុសលធម៌ ប្រកបដោយបច្ច័យ ជាបច្ច័យនៃកុសលធម៌ ប្រកបដោយបច្ច័យ ដោយហេតុប្បច្ច័យ ។

[ ១០៧០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

## បដិច្ចវារៈ

[ ១០៧១ ] អកុសលធម៌ ប្រកបដោយបច្ច័យ អាស្រ័យនូវអកុសលធម៌ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០៧២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ឯក្នុងបញ្ហាវារៈ បច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

## បដិច្ចវារៈ

[ ១០៧៣ ] អព្យាកតធម៌ប្រកបដោយបច្ច័យ អាស្រ័យនូវអព្យាកតធម៌ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០៧៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ១០៧៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

## បញ្ហាវារៈ

[ ១០៧៦ ] អព្យាកតធម៌ ប្រកបដោយបច្ច័យ ជាបច្ច័យនៃអព្យាកតធម៌ប្រកបដោយបច្ច័យ ដោយហេតុប្បច្ច័យ ។

[ ១០៧៧ ] អព្យាកតធម៌ប្រកបដោយបច្ច័យ ជាបច្ច័យនៃអព្យាកតធម៌ប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ ។ អព្យាកតធម៌ មិនប្រកបដោយបច្ច័យ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ ។

[ ១០៧៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ។ អព្យាកតធម៌ ប្រកបដោយបច្ច័យ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយបច្ច័យ ដោយឧបនិស្សយប្បច្ច័យ អព្យាកតធម៌មិនប្រកបដោយបច្ច័យ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយបច្ច័យ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ ។ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ១០៧៩ ] អព្យាកតធម៌ប្រកបដោយបច្ច័យ ជាបច្ច័យនៃអព្យាកតធម៌ប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ អព្យាកតធម៌ មិនប្រកបដោយបច្ច័យ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១០៨០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ។

[ ១០៨១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។

[ ១០៨២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

ចប់ សប្បច្ចយទុកកុសលត្តិកៈ ។

## សង្ខតទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១០៨៣ ] កុសលធម៌ ដែលបច្ច័យតាក់តែងហើយ អាស្រ័យនូវកុសលធម៌ដែលបច្ច័យតាក់តែងហើយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ដូចគ្នានឹងសប្បច្ចយទុកកុសលត្តិកៈដែរ ។

ចប់ សង្ខតទុកកុសលត្តិកៈ ។

## សនិទស្សនទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១០៨៤ ] កុសលធម៌ ជាអនិទស្សនៈ ( កុសលធម៌មិនប្រកបដោយការឃើញ ) អាស្រ័យនូវកុសលធម៌ ជាអនិទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០៨៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ឯបញ្ហាវារៈ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

## បដិច្ចវារៈ

[ ១០៨៦ ] អកុសលធម៌ ជាអនិទស្សនៈ អាស្រ័យនូវអកុសលធម៌ ជាអនិទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០៨៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ឯបញ្ហាវារៈ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

## បដិច្ចវារៈ

[ ១០៨៨ ] អព្យាកតធម៌ ជាអនិទស្សនៈ អាស្រ័យនូវអព្យាកតធម៌ ជាអនិទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០៨៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១០៩០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនអាហារប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យ

ពិស្តារផងចុះ ។

# បញ្ហាវារៈ

[ ១០៩១ ] អព្យាកតធម៌ ជាអនិទស្សនៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអនិទស្សនៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ១០៩២ ] អព្យាកតធម៌ ជាសនិទស្សនៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអនិទស្សនៈ ដោយអារម្មណប្បច្ច័យ អព្យាកតធម៌ ជាអនិទស្សនៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអនិទស្សនៈ ដោយអារម្មណប្បច្ច័យ ។

[ ១០៩៣ ] អព្យាកតធម៌ ជាសនិទស្សនៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអនិទស្សនៈ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហ-ជាតាធិបតិ ។ អព្យាកតធម៌ ជាអនិទស្សនៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអនិទស្សនៈផង នៃអព្យាកតធម៌ ជាសនិទស្សនៈផង ដោយអធិបតិប្បច្ច័យ បានដល់ សហជាតាធិបតិ មានវារៈ ៣ ។

[ ១០៩៤ ] ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ។បេ។ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ។

[ ១០៩៥ ] អព្យាកតធម៌ ជាសនិទស្សនៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអនិទស្សនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ បកតូបនិស្ស័យ ។ អព្យាកតធម៌ ជាអនិទស្សនៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអនិទស្សនៈ ដោយឧបនិស្សយប្បច្ច័យ បានដល់ អារម្មណូបនិស្ស័យ អនន្តរូបនិស្ស័យ

និងបកតូបនិស្ស័យ ។បេ។

[ ១០៩៦ ] ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១ ។

ចប់ សនិទស្សនទុកកុសលត្តិកៈ ។

អប្បច្ចយធម៌ក្តី អសង្ខតធម៌ក្តី សនិទស្សនធម៌ក្តី មិនបាច់និយាយឡើយ ។

## អប្បដិឃទុកកុសលត្តិកៈ
## បដិច្ចវារៈ

[ ១០៩៧ ] កុសលធម៌ជាអប្បដិឃៈ ( មិនប្រកបដោយការប៉ះពាល់ ) អាស្រ័យនូវកុសលធម៌ ជាអប្បដិឃៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០៩៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ឯក្នុងបញ្ហាវារៈ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

## បដិច្ចវារៈ

[ ១០៩៩ ] អកុសលធម៌ ជាអប្បដិឃៈ អាស្រ័យនូវអកុសលធម៌ ជាអប្បដិឃៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១០០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ឯក្នុងបញ្ហាវារៈ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

## បដិច្ចវារៈ

[ ១១០១ ] អព្យាកតធម៌ ជាសប្បដិឃៈ អាស្រ័យនូវអព្យាកតធម៌ ជាសប្បដិឃៈ ទើបកើតឡើងព្រោះហេតុប្បច្ច័យ អព្យាកតធម៌ ជាអប្បដិឃៈ អាស្រ័យនូវអព្យាកតធម៌ជាសប្បដិឃៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាសប្បដិឃៈក្តី អព្យាកតធម៌ ជាអប្បដិឃៈក្តី អាស្រ័យនូវអព្យាកតធម៌ជាសប្បដិឃៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៩ ។

[ ១១០២ ] អព្យាកតធម៌ ជាអប្បដិឃៈ អាស្រ័យនូវអព្យាកតធម៌ ជាអប្បដិឃៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ១១០៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១០៤ ] អព្យាកតធម៌ ជាសប្បដិឃៈ អាស្រ័យនូវអព្យាកតធម៌ ជាសប្បដិឃៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ១១០៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៩ ។

## បញ្ហាវារៈ

[ ១១០៦ ] អព្យាកតធម៌ ជាអប្បដិឃៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអប្បដិឃៈ ដោយហេតុប្បច្ច័យ ។

[ ១១០៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៥ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១០៨ ] អព្យាកតធម៌ ជាសប្បដិឃៈ ជាបច្ច័យនៃអព្យាកតធម៌ ជាសប្បដិឃៈ ដោយសហជាតប្បច្ច័យ ។បេ។

[ ១១០៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១១១០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ១១១១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងសប្បដិឃទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ អប្បដិឃទុកកុសលត្តិកៈ ។**

# រូបីទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១១១២ ] កុសលធម៌ មិនមានរូប អាស្រ័យនូវកុសលធម៌ មិនមានរូប ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១១៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ។

ក្នុងសហជាតវារៈក្តី ។បេ។ ក្នុងបញ្ហាវារៈក្តី ក្នុងបច្ច័យទាំង អស់ សុទ្ធតែមានវារៈ ១ ។

## បដិច្ចវារៈ

[ ១១១៤ ] អកុសលធម៌មិនមានរូប អាស្រ័យនូវអកុសលធម៌ មិនមានរូប ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១១៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មាន វារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងសហជាតវារៈក្តី ។បេ។ ក្នុងបញ្ហាវារៈក្តី ក្នុងបច្ច័យទាំង អស់ សុទ្ធតែមានវារៈ ១ ។

## បដិច្ចវារៈ

[ ១១១៦ ] អព្យាកតធម៌ មានរូប អាស្រ័យនូវអព្យាកតធម៌ មានរូប ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមាន រូប អាស្រ័យនូវអព្យាកតធម៌មិនមានរូប ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌មានរូប អាស្រ័យនូវអព្យាកតធម៌ មានរូបផង នូវអព្យាកតធម៌ មិនមានរូបផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មាន វារៈ ៣ ។

[ ១១១៧ ] អព្យាកតធម៌ មិនមានរូប អាស្រ័យនូវអព្យាកតធម៌ មិន មានរូប ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ១១១៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១១៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ២ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

## បញ្ហាវារៈ

[ ១១២០ ] អព្យាកតធម៌ មិនមានរូប ជាបច្ច័យនៃអព្យាកតធម៌ មិនមានរូប ដោយហេតុប្បច្ច័យ ។

[ ១១២១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ៧

ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៦ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។បេ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ១១២២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ។

[ ១១២៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ១១២៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងរូបីទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ រូបីទុកកុសលត្តិកៈ ។**

# លោកិយទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១១២៥ ] កុសលធម៌ ជាលោកិយ អាស្រ័យនូវកុសលធម៌ ជាលោកិយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ ជាលោកុត្តរៈ អាស្រ័យនូវកុសលធម៌ ជាលោកុត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១២៦ ] កុសលធម៌ ជាលោកិយ អាស្រ័យនូវកុសលធម៌ ជាលោកិយ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ កុសលធម៌ ជាលោកុត្តរៈ អាស្រ័យនូវកុសលធម៌ ជាលោកុត្តរៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ១១២៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ១១២៨ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១១២៩ ] កុសលធម៌ជាលោកិយ ជាបច្ច័យនៃកុសលធម៌ជាលោកិយ

ដោយហេតុប្បច្ច័យ ។ កុសលធម៌ជាលោកុត្តរៈ ជាបច្ច័យនៃកុសលធម៌ជាលោកុត្តរៈ ដោយហេតុប្បច្ច័យ មានវារៈ ២ ។

[ ១១៣០ ] កុសលធម៌ជាលោកិយ ជាបច្ច័យនៃកុសលធម៌ជាលោកិយ ដោយអារម្មណប្បច្ច័យ ។ កុសលធម៌ជាលោកុត្តរៈ ជាបច្ច័យនៃកុសលធម៌ជាលោកិយ ដោយអារម្មណប្បច្ច័យ ។

[ ១១៣១ ] កុសលធម៌ជាលោកិយ ជាបច្ច័យនៃកុសលធម៌ជាលោកិយ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ កុសលធម៌ជាលោកុត្តរៈ ជាបច្ច័យនៃកុសលធម៌ជាលោកុត្តរៈ ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ ។ កុសលធម៌ ជាលោកុត្តរៈ ជាបច្ច័យនៃកុសលធម៌ ជាលោកិយ ដោយអធិបតិប្បច្ច័យ បានដល់ អារម្មណាធិបតិ ។

[ ១១៣២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ២ ។បេ។ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងអាហារប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

## បដិច្ចវារៈ

[ ១១៣៣ ] អកុសលធម៌ ជាលោកិយ អាស្រ័យនូវអកុសលធម៌ជា

លោកិយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៣៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈក្តី ។បេ។ បញ្ហាវារៈក្តី ដូចគ្នាក្នុងបច្ច័យទាំងអស់ ។

## បដិច្ចវារៈ

[ ១១៣៥ ] អព្យាកតធម៌ ជាលោកិយ អាស្រ័យនូវអព្យាកតធម៌ ជាលោកិយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាលោកុត្តរៈ អាស្រ័យនូវអព្យាកតធម៌ ជាលោកុត្តរៈ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។

[ ១១៣៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ១១៣៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ។បេ។ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ។បេ។ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ។បេ។ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី

សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១១៣៨ ] អព្យាកតធម៌ ជាលោកិយ ជាបច្ច័យនៃអព្យាកតធម៌ ជាលោកិយ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាលោកុត្តរៈ ជាបច្ច័យនៃអព្យាកតធម៌ ជាលោកុត្តរៈ ដោយហេតុប្បច្ច័យ ។

[ ១១៣៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ។បេ។ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងលោកិយទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់

យ៉ាងនោះដែរ ។

ចប់ លោកិយទុកកុសលត្តិកៈ ។

# កេនចិវិញ្ញេយ្យទុកកុសលត្តិកៈ
# បដិច្ចវារៈ

[ ១១៨០ ] កុសលធម៌ ដែលគួរដឹងដោយវិញ្ញាណណាមួយ អាស្រ័យនូវកុសលធម៌ ដែលគួរដឹងដោយវិញ្ញាណណាមួយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ កុសលធម៌ ដែលមិនគួរដឹងដោយវិញ្ញាណណាមួយ អាស្រ័យនូវកុសលធម៌ ដែលគួរដឹងដោយវិញ្ញាណណាមួយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ កុសលធម៌ ដែលគួរដឹងដោយវិញ្ញាណណាមួយក្តី កុសលធម៌ ដែលមិនគួរដឹងដោយវិញ្ញាណណាមួយក្តី អាស្រ័យនូវកុសលធម៌ ដែលគួរដឹងដោយវិញ្ញាណណាមួយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៨១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១៨២ ] កុសលធម៌ ដែលគួរដឹងដោយវិញ្ញាណណាមួយ អាស្រ័យនូវកុសលធម៌ ដែលគួរដឹងដោយវិញ្ញាណណាមួយ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ១១៨៣ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ

មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៩ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១១៨៤ ] កុសលធម៌ ដែលគួរដឹងដោយវិញ្ញាណណាមួយ ជាបច្ច័យនៃកុសលធម៌ ដែលគួរដឹងដោយវិញ្ញាណណាមួយ ដោយហេតុប្បច្ច័យ ។

[ ១១៨៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១៨៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១១៨៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ១១៨៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈ ដែលលោករាប់

ហើយយ៉ាងណា ( ក្នុងកេនចិវិញ្ញេយ្យទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

កេនចិវិញ្ញេយ្យអកុសលត្តិ កេនចិវិញ្ញេយ្យអព្យាកតៈត្តិ ដូចគ្នានឹងកេនចិវិញ្ញេយ្យកុសលដែរ បណ្ឌិតគប្បីឲ្យពិស្តារ ផងចុះ ។

**ចប់ កេនចិវិញ្ញេយ្យទុកកុសលត្តិកៈ ។**

**ចប់ ចូឡន្តរទុកកុសលត្តិកៈ ។**

# អាសវទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១១៤៩ ] កុសលធម៌ មិនមែនជាអាសវៈ អាស្រ័យនូវកុសលធម៌ មិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៥០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងសហជាតវារៈក្តី ។បេ។ ក្នុងបញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

[ ១១៥១ ] អកុសលធម៌ ជាអាសវៈ អាស្រ័យនូវកុសលធម៌ ជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៥២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១៥៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បច្ចយវារៈក្តី ។បេ។ សម្បយុត្តវារៈក្តី គប្បីឲ្យពិស្តារគ្រប់បច្ច័យទាំងអស់ផងចុះ ។

## បញ្ហាវារៈ

[ ១១៥៤ ] អកុសលធម៌ ជាអាសវៈ ជាបច្ច័យនៃអកុសលធម៌ ជា

អាសវៈ ដោយហេតុប្បច្ច័យ ។

[ ១១៥៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ឯសហជាតាធិបតិនៃវារៈទាំង ៣ លោកសំដៅយកត្រង់បទកណ្តាល ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ។បេ។ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ។

## បដិច្ចវារៈ

[ ១១៥៦ ] អព្យាកតធម៌មិនមែនជាអាសវៈ អាស្រ័យនូវអព្យាកតធម៌មិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៥៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈក្តី បច្ចយវារៈក្តី ។បេ។ ក្នុងបញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

ចប់ អាសវទុកកុសលត្តិកៈ ។

## សាសវទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១១៥៨ ] កុសលធម៌ប្រកបដោយអាសវៈ អាស្រ័យនូវកុសលធម៌

ប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ មិនមានអាសវៈ អាស្រ័យនូវកុសលធម៌មិនមានអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៥៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ១១៦០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី ក្នុងសម្បយុត្តវារៈក្តី ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ២ ។

## បញ្ហាវារៈ

[ ១១៦១ ] កុសលធម៌ ប្រកបដោយអាសវៈ ជាបច្ច័យនៃកុសលធម៌ ប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ ។ កុសលធម៌ មិនមានអាសវៈ ជាបច្ច័យនៃកុសលធម៌ មិនមានអាសវៈ ដោយហេតុប្បច្ច័យ ។

[ ១១៦២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងសាសវទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់

យ៉ាងនោះដែរ ។

# បដិច្ចវារៈ

[ ១១៦៣ ] អកុសលធម៌ប្រកបដោយអាសវៈ អាស្រ័យនូវអកុសល-ធម៌ប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៦៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ១ ។

# បដិច្ចវារៈ

[ ១១៦៥ ] អព្យាកតធម៌ប្រកបដោយអាសវៈ អាស្រ័យនូវអព្យាកត-ធម៌ប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌មិនមានអាសវៈ អាស្រ័យនូវអព្យាកតធម៌ មិនមានអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ ប្រកបដោយអាសវៈ អាស្រ័យនូវអព្យា-កតធម៌ មិនមានអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ប្រកបដោយអាសវៈក្តី អព្យាកតធម៌មិនមានអាសវៈក្តី អាស្រ័យនូវអព្យា-កតធម៌មិនមានអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ប្រកបដោយអាសវៈ អាស្រ័យនូវអព្យាកតធម៌ប្រកបដោយអាសវៈផង នូវអព្យាកតធម៌មិនមានអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៦៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ១១៦៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី ។បេ។ ក្នុងសម្បយុត្តវារៈក្តី បណ្ឌិតគប្បី ឲ្យពិស្តារគ្រប់បច្ច័យទាំងអស់ផងចុះ ។

## បញ្ហាវារៈ

[ ១១៦៨ ] អព្យាកតធម៌ប្រកបដោយអាសវៈ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមានអាសវៈ ជាបច្ច័យនៃអព្យាកតធម៌ មិនមានអាសវៈ ដោយហេតុប្បច្ច័យ ។

[ ១១៦៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងសាសវទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

ចប់ សាសវទុកកុសលត្តិកៈ ។

# អាសវសម្បយុត្តទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១១៧០ ] កុសលធម៌ដែលប្រាសចាកអាសវៈ អាស្រ័យនូវកុសលធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៧១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ១ ។ ការកំណត់នូវកុសលទុកៈ ឯអកុសលទុកៈ តើដូចម្តេច ។

[ ១១៧២ ] អកុសលធម៌ប្រកបដោយអាសវៈ អាស្រ័យនូវអកុសលធម៌ប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រកបដោយអាសវៈ អាស្រ័យនូវអកុសលធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៧៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

ក្នុងសហជាតវារៈក្តី ក្នុងសម្បយុត្តវារៈក្តី ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ៥ ។

[ ១១៧៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ។បេ។ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មាន

វារៈ ៥ ។បេ។

## បញ្ហាវារៈ

[ ១១៧៥ ] អកុសលធម៌ប្រកបដោយអាសវៈ ជាបច្ច័យនៃអកុសលធម៌ប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ប្រាសចាកអាសវៈ ជាបច្ច័យនៃអកុសលធម៌ ប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ ។

[ ១១៧៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងអាសវសម្បយុត្តទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ១១៧៧ ] អព្យាកតធម៌ប្រាសចាកអាសវៈ អាស្រ័យនូវអព្យាកតធម៌ប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៧៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ១១៧៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ

មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ។

ក្នុងសហជាតវារៈក្តី ក្នុងសម្បយុត្តវារៈក្តី ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

## បញ្ហាវារៈ

[ ១១៨០ ] អព្យាកតធម៌ប្រាសចាកអាសវៈ ជាបច្ច័យនៃអព្យាកតធម៌ប្រាសចាកអាសវៈ ដោយហេតុប្បច្ច័យ ។

[ ១១៨១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងអាសវសម្បយុត្តទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ អាសវសម្បយុត្តទុកកុសលត្តិកៈ ។**

## អាសវសាសវទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១១៨២ ] កុសលធម៌ ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ អាស្រ័យនូវកុសលធម៌ ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ទើប

កើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៨៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ១ ។

## បដិច្ចវារៈ

[ ១១៨៤ ] អកុសលធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យនូវអកុសលធម៌ ជាអាសវៈ ទាំងប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ អាស្រ័យនូវអកុសលធម៌ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យនូវអកុសលធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នូវអកុសលធម៌ប្រកបដោយអាសវៈ ទាំងមិនមែនជាអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ១១៨៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១៨៦ ] អកុសលធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ អា-

ស្រ័យនូវអកុសលធម៌ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ១១៨៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១១៨៨ ] អកុសលធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ជាបច្ច័យនៃអកុសលធម៌ ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ ។

[ ១១៨៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១៩០ ] អកុសលធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ជាបច្ច័យនៃអកុសលធម៌ ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។

[ ១១៩១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១១៩២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ។

[ ១១៩៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយា-នុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយ យ៉ាងណា ( ក្នុងអាសវសាសវទុកកុសលត្តិកៈ ) បណ្ឌិត គប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ១១៩៤ ] អព្យាកតធម៌ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ អាស្រ័យនូវអព្យាកតធម៌ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៩៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់សុទ្ធតែមានវារៈ ១ ។

ចប់ អាសវសាសវទុកកុសលត្តិកៈ ។

# អាសវអាសវសម្បយុត្តទុកកុសលត្តិកៈ
# បដិច្ចវារៈ

[ ១១៩៦ ] អកុសលធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យនូវអកុសលធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ អាស្រ័យនូវអកុសលធម៌ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យនូវអកុសលធម៌ ជាអាសវៈ ទាំងប្រកបដោយអាសវៈផង នូវអកុសលធម៌ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ១១៩៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១៩៨ ] អកុសលធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យនូវអកុសលធម៌ ជាអាសវៈ ទាំងប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ១១៩៩ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

ក្នុងសហជាតវារៈក្តី ក្នុងសម្បយុត្តវារៈក្តី ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៩ ។

## បញ្ហាវារៈ

[ ១២០០ ] អកុសលធម៌ ជាអាសវៈ ទាំងប្រកបដោយអាសវៈ ជាបច្ច័យនៃអកុសលធម៌ ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ ។

[ ១២០១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១២០២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១២០៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ។

[ ១២០៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( ក្នុងអាសវអាសវសម្បយុត្តទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

ចប់ អាសវអាសវសម្បយុត្តទុកកុសលត្តិកៈ ។

# អាសវវិប្បយុត្តសាសវទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១២០៥ ] កុសលធម៌ដែលប្រាសចាកអាសវៈ ប្រកបដោយអាសវៈ អាស្រ័យនូវកុសលធម៌ ប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ អាស្រ័យនូវកុសលធម៌ ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១២០៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីធ្វើឲ្យពិស្តារផងចុះ ។

## បដិច្ចវារៈ

[ ១២០៧ ] អព្យាកតធម៌ ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ អាស្រ័យនូវអព្យាកតធម៌ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ អាស្រ័យនូវអព្យាកតធម៌ ដែលប្រាសចាកអាសវៈទាំងមិនមានអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ អាស្រ័យនូវអព្យាកតធម៌ដែលប្រាសចាកអាសវៈ **ទាំងមិនមានអាសវៈ** ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ដែលប្រាសចាកអាសវៈ តែប្រកបដោយ

អាសវៈក្តី អព្យាកតធម៌ ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈក្តី អាស្រ័យនូវអព្យាកតធម៌ ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ អាស្រ័យនូវអព្យាកតធម៌ ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈផង នូវអព្យាកតធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១២០៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ១២០៩ ] អព្យាកតធម៌ ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ អាស្រ័យនូវអព្យាកតធម៌ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ១២១០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

# បញ្ហាវារៈ

[ ១២១១ ] អព្យាកតធម៌ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ ជាបច្ច័យនៃអព្យាកតធម៌ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យនៃអព្យាកតធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយហេតុប្បច្ច័យ អព្យាកតធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យនៃអព្យាកតធម៌ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ ដោយហេតុប្បច្ច័យ អព្យាកតធម៌ ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យនៃអព្យាកតធម៌ ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈផង នៃអព្យាកតធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈផង ដោយហេតុប្បច្ច័យ ។

[ ១២១២ ] អព្យាកតធម៌ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ ជាបច្ច័យនៃអព្យាកតធម៌ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ ។ អព្យាកតធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យនៃអព្យាកតធម៌ ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយអារម្មណប្បច្ច័យ ។

[ ១២១៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤

ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ១២១៤ ] អព្យាកតធម៌ ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ ជាបច្ច័យនៃអព្យាកតធម៌ដែលប្រាសចាកអាសវៈ តែប្រកបដោយអាសវៈ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិយប្បច្ច័យ ។

[ ១២១៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ។

[ ១២១៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ។

[ ១២១៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយា-

នុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈដែលលោករាប់ហើយ យ៉ាងណា ( ក្នុងអាសវវិប្បយុត្តសាសវទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ អាសវវិប្បយុត្តសាសវទុកកុសលត្តិកៈ ។**

**ចប់ អាសវគោច្ឆកទុកកុសលត្តិកៈ ។**

# អភិធម្មបិដក

## បដ្ឋាន តេរសមភាគ

## សញ្ញោជនទុកកុសលត្តិកៈ

### បដិច្ចវារៈ

[ ១ ] នោសញ្ញោជនកុសលធម៌ ( កុសលធម៌មិនមែនជាសញ្ញោជនៈ ) អាស្រ័យនូវនោសញ្ញោជនកុសលធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់ មានវារៈតែ ១ ។

### បដិច្ចវារៈ

[ ៣ ] សញ្ញោជនអកុសលធម៌ អាស្រ័យនូវសញ្ញោជនអកុសលធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នោសញ្ញោជនអកុសលធម៌ អាស្រ័យនូវសញ្ញោជនអកុសលធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ សញ្ញោជនអកុសលធម៌ក្តី នោសញ្ញោជនអកុសលធម៌ក្តី អាស្រ័យនូវសញ្ញោជនអកុសលធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ

៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី ។បេ។ សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈ

ដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៦ ] សញ្ញោជនអកុសលធម៌ ជាបច្ច័យនៃសញ្ញោជនអកុសលធម៌ ដោយហេតុប្បច្ច័យ ។

[ ៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៩ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ១០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។ អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ ដែលបណ្ឌិតរាប់ហើយយ៉ាងណា ( សញ្ញោជនទុកកុសលត្តិកៈ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ១១ ] នោសញ្ញោជនអព្យាកតធម៌ អាស្រ័យនូវនោសញ្ញោជនអព្យាកតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់ មានវារៈតែ ១ ។

ចប់ សញ្ញោជនទុកកុសលត្តិកៈ ។

## សញ្ញោជនិយទុកកុសលត្តិកៈ
## បដិច្ចវារៈ

[ ១៣ ] សញ្ញោជនិយកុសលធម៌ ( កុសលធម៌ ជាប្រយោជន៍ដល់សញ្ញោជនៈ ) អាស្រ័យនូវសញ្ញោជនិយកុសលធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អសញ្ញោជនិយកុសលធម៌ អាស្រ័យនូវអសញ្ញោជនិយ-កុសលធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ។

ដំណើរនៃលោកិយលោកុត្តរទុកៈ ក្នុងចូឡន្តរទុកៈ យ៉ាងណា សញ្ញោជនិយទុកកុសលត្តិកៈនេះ បណ្ឌិតគប្បីដឹង យ៉ាងនោះដែរ ។ សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បដិច្ចវារៈ

[ ១៥ ] សញ្ញោជនិយអកុសលធម៌ អាស្រ័យនូវសញ្ញោជនិយអកុសលធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់ មានវារៈតែ ១ ។

## បដិច្ចវារៈ

[ ១៧ ] សញ្ញោជនិយអព្យាកតធម៌ អាស្រ័យនូវសញ្ញោជនិយអព្យាកតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អសញ្ញោជនិយអព្យាកតធម៌ អាស្រ័យនូវអសញ្ញោជនិយអព្យាកតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ សញ្ញោជនិយអព្យាកតធម៌ អាស្រ័យនូវអសញ្ញោជនិយអព្យាកតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ សញ្ញោជនិយអព្យាកតធម៌ក្តី អសញ្ញោជនិយអព្យាកតធម៌ក្តី អាស្រ័យនូវអសញ្ញោជនិយអព្យាកតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ សញ្ញោជនិយអព្យាកតធម៌ អាស្រ័យនូវសញ្ញោជនិយអព្យាកតធម៌ផង នូវអសញ្ញោជនិយអព្យាកតធម៌ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សញ្ញោជនិយទុកកុសលត្តិកៈ ដូចគ្នានឹងលោកិយលោកុត្តរ-ទុកៈក្នុងចូឡន្តរទុកៈដែរ ឯសហជាតវារៈក្តី ។បេ។ សម្បយុត្តវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១៩ ] សញ្ញោជនិយអព្យាកតធម៌ ជាបច្ច័យនៃសញ្ញោជនិយអព្យា-កតធម៌ ដោយហេតុប្បច្ច័យ ។ អសញ្ញោជនិយអព្យាកតធម៌ ជាបច្ច័យនៃអសញ្ញោជនិយអព្យាកតធម៌ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ២០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ២១ ] សញ្ញោជនិយអព្យាកតធម៌ ជាបច្ច័យនៃសញ្ញោជនិយអព្យា-កតធម៌ ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យដោយបុរេជាតប្បច្ច័យ ជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យដោយអាហារប្បច្ច័យ ជាបច្ច័យដោយឥន្ទ្រិ-យប្បច្ច័យ ។

[ ២២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ។

[ ២៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ។

[ ២៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយា-
នុលោមក្តី នៃបញ្ហាវារៈ ក្នុងកុសលត្តិកៈ ដែលលោករាប់
ហើយយ៉ាងណា បទនេះ បណ្ឌិតត្រូវរាប់យ៉ាងនោះដែរ ។

**ចប់ សញ្ញោជនិយទុកកុសលត្តិកៈ ។**

## សញ្ញោជនសម្បយុត្តទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ២៥ ] សញ្ញោជនវិប្បយុត្តកុសលធម៌ ( កុសលធម៌ដែលប្រាសចាក
សញ្ញោជនៈ ) អាស្រ័យនូវសញ្ញោជនវិប្បយុត្តកុសលធម៌ ( កុសលធម៌
ដែលប្រាសចាកសញ្ញោជនៈ ) ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ
១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី មានវារៈតែ ១ ។

## បដិច្ចវារៈ

[ ២៧ ] សញ្ញោជនសម្បយុត្តអកុសលធម៌ ( អកុសលធម៌ ប្រកប
ដោយសញ្ញោជនៈ ) អាស្រ័យនូវសញ្ញោជនសម្បយុត្តអកុសលធម៌ ( អ-
កុសលធម៌ប្រកបដោយសញ្ញោជនៈ ) ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២៨ ] សញ្ញោជនសម្បយុត្តអកុសលធម៌ អាស្រ័យនូវសញ្ញោជន-

សម្បយុត្តអកុសលធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ២៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៣០ ] សញ្ញោជនសម្បយុត្តអកុសលធម៌ អាស្រ័យនូវសញ្ញោជនសម្បយុត្តអកុសលធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺមោហៈដែលប្រកបដោយវិចិកិច្ឆា អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ។

[ ៣១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៥ ។បេ។ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ។បេ។ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ។

## បញ្ហាវារៈ

[ ៣២ ] សញ្ញោជនសម្បយុត្តអកុសលធម៌ ជាបច្ច័យនៃសញ្ញោជនសម្បយុត្តអកុសលធម៌ ដោយហេតុប្បច្ច័យ ។ សញ្ញោជនវិប្បយុត្តអកុសលធម៌ ជាបច្ច័យនៃសញ្ញោជនវិប្បយុត្តអកុសលធម៌ ដោយហេតុប្បច្ច័យ ។

[ ៣៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ សញ្ញោជនសម្បយុត្តអកុសលធម៌ ជាបច្ច័យ នៃសញ្ញោជនសម្បយុត្តអកុសលធម៌ ដោយអធិបតិប្បច្ច័យ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងសហជាតប្បច្ច័យ មានវារៈ ៥ ។បេ។ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មាន

ភារៈ ៩ ក្នុងកម្មប្បច្ច័យ មានភារៈ ៣ ។បេ។ ក្នុងមគ្គប្បច្ច័យ មានភារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានភារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានភារៈ ៥ ។

## បដិច្ចវារៈ

[ ៣៤ ] សញ្ញោជនវិប្បយុត្តអព្យាកតធម៌ អាស្រ័យនូវសញ្ញោជន-វិប្បយុត្តអព្យាកតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣៥ ] ក្នុងហេតុប្បច្ច័យ មានភារៈ ១ ក្នុងអារម្មណប្បច្ច័យ មានភារៈ ១ ក្នុងអវិគតប្បច្ច័យ មានភារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតភារៈក្តី ក្នុងបញ្ហាភារៈក្តី មានភារៈតែ ១ ។

**ចប់ សញ្ញោជនសម្បយុត្តទុកកុសលត្តិកៈ ។**

## សញ្ញោជនសញ្ញោជនិយទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ៣៦ ] កុសលធម៌ ជាសញ្ញោជនិយៈផង មិនមែនជាសញ្ញោជនៈផង អាស្រ័យនូវកុសលធម៌ ជាសញ្ញោជនិយៈផង មិនមែនជាសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣៧ ] ក្នុងហេតុប្បច្ច័យ មានភារៈ ១ ក្នុងអារម្មណប្បច្ច័យ មានភារៈ ១ ក្នុងអវិគតប្បច្ច័យ មានភារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតភារៈក្តី ក្នុងបញ្ហាភារៈក្តី មានភារៈតែ ១ ។

## បដិច្ចវារៈ

[ ៣៨ ] អកុសលធម៌ជាសញ្ញោជនៈផង ជាសញ្ញោជនិយៈផង អាស្រ័យនូវអកុសលធម៌ ជាសញ្ញោជនៈផង ជាសញ្ញោជនិយៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៣៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៤០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

## បញ្ហាវារៈ

[ ៤១ ] អកុសលធម៌ ជាសញ្ញោជនៈផង ជាសញ្ញោជនិយៈផង ជាបច្ច័យនៃអកុសលធម៌ ជាសញ្ញោជនៈផង ជាសញ្ញោជនិយៈផង ដោយហេតុប្បច្ច័យ ។

[ ៤២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៤៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៤៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៤៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយា-
នុលោមក្តី របស់បញ្ហាវារៈ ក្នុងកុសលត្តិកៈ ដែលលោករាប់
ហើយយ៉ាងណា បទនេះ បណ្ឌិតគប្បីរាប់យ៉ាងនោះផងចុះ ។

## បដិច្ចវារៈ

[ ៤៦ ] អព្យាកតធម៌ ជាសញ្ញោជនិយៈផង ជានោសញ្ញោជនៈផង អាស្រ័យនូវអព្យាកតធម៌ជាសញ្ញោជនិយៈផង ជានោសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី មានវារៈតែ ១ ។

**ចប់ សញ្ញោជនសញ្ញោជនិយទុកកុសលត្តិកៈ ។**

# សញ្ញោជនសញ្ញោជនសម្បយុត្តទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ៤៨ ] អកុសលធម៌ ជាសញ្ញោជនៈផង ជាសញ្ញោជនសម្បយុត្តផង អាស្រ័យនូវអកុសលធម៌ ជាសញ្ញោជនៈផង ជាសញ្ញោជនសម្បយុត្តផង

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៤៩ ] អកុសលធម៌ ជាសញ្ញោជនសម្បយុត្តផង ជានោសញ្ញោជនៈផង អាស្រ័យនូវអកុសលធម៌ ជាសញ្ញោជនសម្បយុត្តផង ជានោសញ្ញោជនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៥១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៥២ ] អកុសលធម៌ ជាសញ្ញោជនៈផង ជាសញ្ញោជនសម្បយុត្តផង ជាបច្ច័យនៃអកុសលធម៌ ជាសញ្ញោជនៈផង ជាសញ្ញោជនសម្បយុត្តផង ដោយហេតុប្បច្ច័យ ។

[ ៥៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៥៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។

[ ៥៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៥៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈ ក្នុងកុសលត្តិកៈ ដែលលោករាប់ហើយយ៉ាងណា បទនេះ បណ្ឌិតគប្បីរាប់យ៉ាងនោះផងចុះ ។

**ចប់ សញ្ញោជនសញ្ញោជនសម្បយុត្តទុកកុសលត្តិកៈ ។**

## សញ្ញោជនវិប្បយុត្តសញ្ញោជនិយទុកកុសលត្តិកៈ
## បដិច្ចវារៈ

[ ៥៧ ] កុសលធម៌ជាសញ្ញោជនវិប្បយុត្ត និងជាសញ្ញោជនិយៈ អាស្រ័យនូវកុសលធម៌ជាសញ្ញោជនវិប្បយុត្ត និងជាសញ្ញោជនិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ ជាសញ្ញោជនវិប្បយុត្ត និងជាអសញ្ញោជនិយៈ អាស្រ័យនូវកុសលធម៌ ជាសញ្ញោជនវិប្បយុត្ត និងជាអសញ្ញោជនិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

( សញ្ញោជនវិប្បយុត្តសញ្ញោជនិយទុកកុសលត្តិកៈ ) ដូចគ្នា នឹងលោកិយលោកុត្តរទុកៈ ក្នុងចូឡន្តរទុកៈដែរ យ៉ាងណា សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារ គ្រប់ អន្ទើ យ៉ាងនោះផងចុះ ។

## បញ្ហាវារៈ

[ ៥៩ ] អកុសលធម៌ ជាសញ្ញោជនវិប្បយុត្ត និងជាសញ្ញោជនិយៈ ជាបច្ច័យនៃអកុសលធម៌ ជាសញ្ញោជនវិប្បយុត្តនិងជាសញ្ញោជនិយៈ ដោយ អារម្មណប្បច្ច័យ ។

[ ៦០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធ តែមានវារៈ ១ ។

## បដិច្ចវារៈ

[ ៦១ ] អព្យាកតធម៌ ជាសញ្ញោជនវិប្បយុត្ត និងជាសញ្ញោជនិយៈ អាស្រ័យនូវអព្យាកតធម៌ ជាសញ្ញោជនវិប្បយុត្តនិងជាសញ្ញោជនិយៈ ទើប កើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ជាសញ្ញោជនវិប្បយុត្ត និង ជាអសញ្ញោជនិយៈ អាស្រ័យនូវអព្យាកតធម៌ ជាសញ្ញោជនវិប្បយុត្ត និង ជាអសញ្ញោជនិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ ជា សញ្ញោជនវិប្បយុត្ត និងជាសញ្ញោជនិយៈ អាស្រ័យនូវអព្យាកតធម៌ ជា សញ្ញោជនវិប្បយុត្ត និងជាអសញ្ញោជនិយៈ ទើបកើតឡើង ព្រោះហេ-

តុប្បច្ច័យ អព្យាកតធម៌ ជាសញ្ញោជនវិប្បយុត្ត និងជាសញ្ញោជនិយៈក្តី អព្យាកតធម៌ ជាសញ្ញោជនវិប្បយុត្ត និងជាអសញ្ញោជនិយៈក្តី អាស្រ័យនូវអព្យាកតធម៌ ជាសញ្ញោជនវិប្បយុត្ត និងជាអសញ្ញោជនិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាសញ្ញោជនវិប្បយុត្ត និងជាសញ្ញោជនិយៈ អាស្រ័យនូវអព្យាកតធម៌ ជាសញ្ញោជនវិប្បយុត្ត និងជាសញ្ញោជនិយៈផង នូវអព្យាកតធម៌ជាសញ្ញោជនវិប្បយុត្ត និងជាអសញ្ញោ-ជនិយៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងកម្មប្បច្ច័យ មានវារៈ ៥ ក្នុងវិបា-កប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៦៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៤ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៥ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៥ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ១ ក្នុងនវិប្ប-យុត្តប្បច្ច័យ មានវារៈ ២ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

## បញ្ហាវារៈ

[ ៦៤ ] អព្យាកតធម៌ ជាសញ្ញោជនវិប្បយុត្ត និងជាសញ្ញោជនិយៈ

ជាបច្ច័យនៃអព្យាកតធម៌ ជាសញ្ញោជនវិប្បយុត្តនិងជាសញ្ញោជនិយៈ ដោយហេតុប្បច្ច័យ ។

[ ៦៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ៦៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ។

[ ៦៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ។

[ ៦៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈ ក្នុងកុសលត្តិកៈ ដែលលោករាប់ហើយយ៉ាងណា ( បទនេះ ) បណ្ឌិត គប្បីរាប់យ៉ាងនោះដែរ ។

**ចប់ សញ្ញោជនវិប្បយុត្តសញ្ញោជនិយទុកកុសលត្តិកៈ ។**

**ចប់ សញ្ញោជនគោច្ឆកទុកកុសលត្តិកៈ ។**

# គន្ថទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ៦៩ ] កុសលធម៌មិនមែនជាគន្ថៈ អាស្រ័យនូវកុសលធម៌ មិនមែនជាគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី មានវារៈតែ ១ ។

## បដិច្ចវារៈ

[ ៧១ ] អកុសលធម៌ជាគន្ថៈ អាស្រ័យនូវអកុសលធម៌ជាគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អកុសលធម៌ មិនមែនជាគន្ថៈ អាស្រ័យនូវអកុសលធម៌ជាគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អកុសលធម៌ ជាគន្ថៈក្តី អកុសលធម៌ មិនមែនជាគន្ថៈក្តី អាស្រ័យនូវអកុសលធម៌ជាគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ មិនមែនជាគន្ថៈ អាស្រ័យនូវអកុសលធម៌ មិនមែនជាគន្ថៈ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។

[ ៧២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣

ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី ។បេ។ សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ
បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៧៤ ] អកុសលធម៌ជាគន្ថៈ ជាបច្ច័យនៃអកុសលធម៌ជាគន្ថៈ ដោយហេតុប្បច្ច័យ ។

[ ៧៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៧៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈ ក្នុងកុសលត្តិកៈ ដែលលោករាប់ហើយយ៉ាងណា ( បទនេះ ) បណ្ឌិត គប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ៧៩ ] អព្យាកតធម៌ មិនមែនជាគន្ថៈ អាស្រ័យនូវអព្យាកតធម៌ មិន

មែនជាគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។ ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី មានវារៈតែ ១ ។

ចប់ គន្ថទុកកុសលត្តិកៈ ។

# គន្ថនិយទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ៨១ ] កុសលធម៌ ជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវកុសលធម៌ ជាប្រយោជន៍ដល់គន្ថៈ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។ កុសលធម៌មិនមែនជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវកុសលធម៌ មិនមែនជាប្រយោជន៍ដល់គន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ។

( គន្ថនិយទុកកុសលត្តិកៈនេះ ) ដូចគ្នានឹងលោកិយលោកុត្តរគមនៈដែរ សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បដិច្ចវារៈ

[ ៨៣ ] អកុសលធម៌ជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវអកុសលធម៌ជាប្រយោជន៍ដល់គន្ថ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី មានវារៈតែ ១ ។

## បដិច្ចវារៈ

[ ៨៥ ] អព្យាកតធម៌ជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវអព្យាកតធម៌ជាប្រយោជន៍ដល់គន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌មិនមែនជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវអព្យាកតធម៌ មិនមែនជាប្រយោជន៍ដល់គន្ថៈ ទើបកើតឡើងព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវអព្យាកតធម៌ ជាប្រយោជន៍ដល់គន្ថៈផង នូវអព្យាកតធម៌ មិនមែនជាប្រយោជន៍ដល់គន្ថៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

( គន្ថនិយទុកកុសលត្តិកៈនេះ ) ដូចគ្នានឹងលោកិយលោកុត្តរគមនៈដែរ សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

**ចប់ គន្ថនិយទុកកុសលត្តិកៈ ។**

# គន្ថសម្បយុត្តទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ៨៧ ] កុសលធម៌ ប្រាសចាកគន្ថៈ អាស្រ័យនូវកុសលធម៌ ប្រាសចាកគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី មានវារៈតែ ១ ។

## បដិច្ចវារៈ

[ ៨៩ ] អកុសលធម៌ ប្រកបដោយគន្ថៈ អាស្រ័យនូវអកុសលធម៌ ប្រកបដោយគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៦ ។

[ ៩១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៦ ។បេ។ ក្នុងនកម្មប្បច្ច័យ មានវារៈ ៤ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៦ ។បេ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ៩២ ] អកុសលធម៌ ប្រកបដោយគន្ថៈ ជាបច្ច័យនៃអកុសលធម៌

ប្រកបដោយគន្ថៈ ដោយហេតុប្បច្ច័យ ។

[ ៩៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៦ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៩ ក្នុងសហជាតប្បច្ច័យ មានវារៈ ៦ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៤ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៦ ។

## បដិច្ចវារៈ

[ ៩៤ ] អព្យាកតធម៌ប្រាសចាកគន្ថៈ អាស្រ័យនូវអព្យាកតធម៌ ប្រាសចាកគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

**ចប់ គន្ថសម្បយុត្តទុកកុសលត្តិកៈ ។**

## គន្ថគន្ថនិយទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ៩៦ ] កុសលធម៌ជាប្រយោជន៍ដល់គន្ថៈ មិនមែនទាំងជាគន្ថៈ អា-

ស្រ័យនូវកុសលធម៌ជាប្រយោជន៍ដល់គន្ថៈនិងមិនមែនជាគន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

# បដិច្ចវារៈ

[ ៩៨ ] អកុសលធម៌ ជាគន្ថៈផង ជាប្រយោជន៍ដល់គន្ថៈផង អាស្រ័យនូវអកុសលធម៌ ជាគន្ថៈផង ជាប្រយោជន៍ដល់គន្ថៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាប្រយោជន៍ដល់គន្ថៈផង មិនមែនជាគន្ថៈផង អាស្រ័យនូវអកុសលធម៌ ជាប្រយោជន៍ដល់គន្ថៈផង មិនមែនជាគន្ថៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១០១ ] អកុសលធម៌ជាគន្ថៈផង ជាប្រយោជន៍ដល់គន្ថៈផង ជាបច្ច័យនៃអកុសលធម៌ជាគន្ថៈផង ជាប្រយោជន៍ដល់គន្ថៈផង ដោយហេតុប្បច្ច័យ ។

[ ១០២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១០៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១០៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ១០៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈ ដែលលោករាប់ហើយយ៉ាងណា ( បទនេះ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ១០៦ ] អព្យាកតធម៌ ជាប្រយោជន៍ដល់គន្ថៈផង មិនមែនជាគន្ថៈផង អាស្រ័យនូវអព្យាកតធម៌ ជាប្រយោជន៍ដល់គន្ថៈផង មិនមែនជាគន្ថៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

**ចប់ គន្ថគន្ថនិយទុកកុសលត្តិកៈ ។**

# គន្ថគន្ថសម្បយុត្តទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១០៨ ] អកុសលធម៌ ជាគន្ថៈផង ប្រកបដោយគន្ថៈផង អាស្រ័យនូវអកុសលធម៌ ជាគន្ថៈផង ប្រកបដោយគន្ថៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១០៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី ។បេ។ សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១១១ ] អកុសលធម៌ ជាគន្ថៈផង ជាគន្ថសម្បយុត្តផង ជាបច្ច័យនៃអកុសលធម៌ ជាគន្ថៈផង ជាគន្ថសម្បយុត្តផង ដោយហេតុប្បច្ច័យ ។

[ ១១២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១១៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១១៤ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ១១៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។ អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុ-លោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈ ដែលលោករាប់ហើយយ៉ាងណា ( បទនេះ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ គន្ថគន្ថសម្បយុត្តទុកកុសលត្តិកៈ ។**

# គន្ថវិប្បយុត្តគន្ថនិយទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១១៦ ] កុសលធម៌ ដែលប្រាសចាកគន្ថៈ និងជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវកុសលធម៌ ដែលប្រាសចាកគន្ថៈ និងជាប្រយោជន៍ដល់គន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ដែលប្រាសចាកគន្ថៈ និងមិនជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវកុសលធម៌ដែលប្រាសចាកគន្ថៈ និងមិនជាប្រយោជន៍ដល់គន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី ។បេ។ បញ្ហាវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារគ្រប់បទទាំងអស់ផងចុះ ។

## បដិច្ចវារៈ

[ ១១៨ ] អកុសលធម៌ ដែលប្រាសចាកគន្ថៈ និងជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវអកុសលធម៌ដែលប្រាសចាកគន្ថៈ និងជាប្រយោជន៍ដល់គន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១១៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

## បដិច្ចវារៈ

[ ១២០ ] អព្យាកតធម៌ ដែលប្រាសចាកគន្ថៈ និងជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវអព្យាកតធម៌ដែលប្រាសចាកគន្ថៈ និងជាប្រយោជន៍ដល់គន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលប្រាសចាកគន្ថៈ និងមិនជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវអព្យាកតធម៌ ដែលប្រាសចាកគន្ថៈ និងមិនជាប្រយោជន៍ដល់គន្ថៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ដែលប្រាសចាកគន្ថៈ និងមិនជាប្រយោជន៍ដល់គន្ថៈ អាស្រ័យនូវអព្យាកតធម៌ ដែលប្រាសចាកគន្ថៈ និងជាប្រយោជន៍ដល់គន្ថៈផង នូវអព្យាកតធម៌ដែលប្រាសចាកគន្ថៈ និងមិនជាប្រយោជន៍ដល់គន្ថៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១២១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី ។បេ។ សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

## បញ្ហាវារៈ

[ ១២២ ] អព្យាកតធម៌ ដែលប្រាសចាកគន្ថៈ និងជាប្រយោជន៍ដល់គន្ថៈ ជាបច្ច័យនៃអព្យាកតធម៌ ដែលប្រាសចាកគន្ថៈ និងជាប្រយោជន៍ដល់គន្ថៈ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ដែលប្រាសចាកគន្ថៈ និងជាប្រ-យោជន៍ដល់គន្ថៈ ជាបច្ច័យនៃអព្យាកតធម៌ ដែលប្រាសចាកគន្ថៈ និងមិនជាប្រយោជន៍ដល់គន្ថៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ១២៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ១២៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ។

[ ១២៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ។

[ ១២៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុ-លោមក្តី នៃបញ្ហាវារៈក្តីក្នុងកុសលត្តិកៈដែលលោករាប់ហើយយ៉ាងណា ( បទនេះ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

**ចប់ គន្ថវិប្បយុត្តគន្ថនិយទុកកុសលត្តិកៈ ។**

**ចប់ គន្ថគោច្ឆកទុកកុសលត្តិកៈ ។**

ឱឃគោច្ឆកៈក្តី យោគគោច្ឆកៈក្តី ដូចអាសវគោច្ឆកទុកកុសលត្តិកៈដែរ ។

# នីវរណទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១២៧ ] កុសលធម៌ ជានោនីវរណៈ អាស្រ័យនូវកុសលធម៌ ជានីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១២៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

## បដិច្ចវារៈ

[ ១២៩ ] អកុសលធម៌ ជានីវរណៈ អាស្រ័យនូវអកុសលធម៌ ជានីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អកុសលធម៌ ជានោនីវរណៈ អាស្រ័យនូវអកុសលធម៌ ជានីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អកុសលធម៌ ជានីវរណៈក្តី ជានោនីវរណៈក្តី អាស្រ័យនូវអកុសលធម៌ ជានីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៣០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១៣១ ] អកុសលធម៌ ជានីវរណៈ អាស្រ័យនូវអកុសលធម៌ ជានីវរណៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យ

នូវវិចិកិច្ឆានីវរណៈ និងឧទ្ធច្ចនីវរណៈ ។ អកុសលធម៌ជានីវរណៈ អាស្រ័យនូវអកុសលធម៌ ជានោនីវរណៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ អកុសលធម៌ជានីវរណៈ អាស្រ័យនូវអកុសលធម៌ ជានីវរណៈផង នូវអកុសលធម៌ជានោនីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺអវិជ្ជានីវរណៈ អាស្រ័យនូវវិចិកិច្ឆានីវរណៈផង នូវឧទ្ធច្ចនីវរណៈផង នូវពួកសម្បយុត្តកក្ខន្ធផង ។

[ ១៣២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី សម្បយុត្តវារៈក្តី មានវារៈ ៩ ។

## បញ្ហាវារៈ

[ ១៣៣ ] អកុសលធម៌ ជានីវរណៈ ជាបច្ច័យនៃអកុសលធម៌ ជានីវរណៈ ដោយហេតុប្បច្ច័យ ។

[ ១៣៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ១៣៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១៣៦ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ១៣៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុ-លោមក្តី នៃបញ្ហាវារៈ ក្នុងកុសលត្តិកៈដែលលោករាប់ហើយ យ៉ាងណា ( បទនេះ ) បណ្ឌិតគប្បីរាប់យ៉ាងនោះដែរ ។

## បដិច្ចវារៈ

[ ១៣៨ ] អព្យាកតធម៌ ជានីវរណៈ អាស្រ័យនូវអព្យាកតធម៌ ជានោនីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៣៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

**ចប់ នីវរណទុកកុសលត្តិកៈ ។**

## នីវរណិយទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១៤០ ] កុសលធម៌ ជាប្រយោជន៍ដល់នីវរណៈ អាស្រ័យនូវកុសលធម៌ជាប្រយោជន៍ដល់នីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ មិនជាប្រយោជន៍ដល់នីវរណៈ អាស្រ័យនូវកុសលធម៌ មិនជា

ប្រយោជន៍ដល់នីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៨១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ១៨២ ] អកុសលធម៌ ជាប្រយោជន៍ដល់នីវរណៈ អាស្រ័យនូវអកុសលធម៌ជាប្រយោជន៍ដល់នីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៨៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

## បដិច្ចវារៈ

[ ១៨៤ ] អព្យាកតធម៌ជាប្រយោជន៍ដល់នីវរណៈ អាស្រ័យនូវអព្យាកតធម៌ ជាប្រយោជន៍ដល់នីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនជាប្រយោជន៍ដល់នីវរណៈ អាស្រ័យនូវអព្យាកតធម៌ មិនជាប្រយោជន៍ដល់នីវរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាប្រយោជន៍ដល់នីវរណៈ អាស្រ័យនូវអព្យាកតធម៌ជាប្រយោជន៍ដល់នីវរណៈផង នូវអព្យាកតធម៌មិនជាប្រយោជន៍ដល់នីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៨៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអារម្មណប្បច្ច័យ មាន

វារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

**ចប់ នីវរណិយទុកកុសលត្តិកៈ ។**

# នីវរណសម្បយុត្តទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១៨៦ ] កុសលធម៌ជានីវរណវិប្បយុត្ត អាស្រ័យនូវកុសលធម៌ ជានីវរណវិប្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៨៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

## បដិច្ចវារៈ

[ ១៨៨ ] អកុសលធម៌ជានីវរណសម្បយុត្ត អាស្រ័យនូវអកុសល-ធម៌ ជានីវរណសម្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៨៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

## បដិច្ចវារៈ

[ ១៥០ ] អព្យាកតធម៌ ជានីវរណវិប្បយុត្ត អាស្រ័យនូវអព្យាកតធម៌ ជានីវរណវិប្បយុត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៥១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

ចប់ នីវរណសម្បយុត្តទុកកុសលត្តិកៈ ។

## នីវរណនីវរណិយទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១៥២ ] កុសលធម៌ ជានីវរណិយៈផង ជានោនីវរណៈផង អាស្រ័យនូវកុសលធម៌ ជានីវរណិយៈផង ជានោនីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៥៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

## បដិច្ចវារៈ

[ ១៥៤ ] អកុសលធម៌ ជានីវរណៈផង ជានីវរណិយៈផង អាស្រ័យ

នូវអកុសលធម៌ ជានីវរណៈផង ជានីវរណិយៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ជានីវរណិយៈផង ជានោនីវរណៈផង អាស្រ័យនូវអកុសលធម៌ជានីវរណិយៈផង ជានោនីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៥៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ។បេ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ៩ ។

## បដិច្ចវារៈ

[ ១៥៦ ] អព្យាកតធម៌ជានីវរណិយៈផង ជានោនីវរណៈផង អាស្រ័យនូវអព្យាកតធម៌ ជានីវរណិយៈផង ជានោនីវរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៥៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

**ចប់ នីវរណនីវរណិយទុកកុសលត្តិកៈ ។**

# នីវរណនីវរណសម្បយុត្តទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១៥៨ ] អកុសលធម៌ជានីវរណៈផង ជានីវរណសម្បយុត្តផង អាស្រ័យនូវអកុសលធម៌ ជានីវរណៈផង ជានីវរណសម្បយុត្តផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៥៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី មានវារៈតែ ៩ ។

ចប់ នីវរណនីវរណសម្បយុត្តទុកកុសលត្តិកៈ ។

# នីវរណវិប្បយុត្តនីវរណិយទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១៦០ ] កុសលធម៌ជានីវរណវិប្បយុត្ត និងជានីវរណិយៈ អាស្រ័យនូវកុសលធម៌ ជានីវរណវិប្បយុត្ត និងជានីវរណិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ជានីវរណវិប្បយុត្ត និងជាអនីវរណិយៈ អាស្រ័យនូវកុសលធម៌ ជានីវរណវិប្បយុត្តនិងជាអនីវរណិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៦១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

# បដិច្ចវារៈ

[ ១៦២ ] អព្យាកតធម៌ជានីវរណវិប្បយុត្ត និងជានីវរណិយៈ អាស្រ័យនូវអព្យាកតធម៌ ជានីវរណវិប្បយុត្ត និងជានីវរណិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជានីវរណវិប្បយុត្តនិងជាអនីវរណិយៈ អាស្រ័យនូវអព្យាកតធម៌ ជានីវរណវិប្បយុត្តនិងជាអនីវរណិយៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ជានីវរណវិប្បយុត្ត និងជានីវរណិយៈ អាស្រ័យនូវអព្យាកតធម៌ ជានីវរណវិប្បយុត្តនិងជានីវរណិយៈផង នូវអព្យាកតធម៌ ជានីវរណវិប្បយុត្ត និងជាអនីវរណិយៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៦៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ៥ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

**ចប់ នីវរណវិប្បយុត្តនីវរណិយទុកកុសលត្តិកៈ ។**

**ចប់ នីវរណគោច្ឆកទុកកុសលត្តិកៈ ។**

## បរាមាសទុកកុសលត្តិកៈ

## បដិច្ចវារៈ

[ ១៦៤ ] កុសលធម៌ ជានោបរាមាសៈ ( មិនស្ទាបអង្អែល ) អាស្រ័យនូវកុសលធម៌ជានោបរាមាសៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៦៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
មានវារៈតែ ១ ។

## បដិច្ចវារៈ

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៥៥៥ ] អកុសលធម៌ជានិយតៈ អាស្រ័យនូវអកុសលធម៌ជានិយតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ជាអនិយតៈ អាស្រ័យនូវអកុសលធម៌ជាអនិយតនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៥៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងបច្ច័យទាំងអស់ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ៥៥៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ។បេ។ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈជាដើម បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៥៥៨ ] អកុសលធម៌ជានិយតៈ ជាបច្ច័យនៃអកុសលធម៌ ជានិយតៈ

ដោយហេតុប្បច្ច័យ ។ អកុសលធម៌ជាអនិយតៈ ជាបច្ច័យនៃអកុសលធម៌ជាអនិយតៈ ដោយហេតុប្បច្ច័យ ។

[ ៥៥៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ។ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ គឺក្នុងនិយតៈ ( ទី ១ ) បានដល់ សហជាតាធិបតិ ក្នុងនិយតៈទី ២ បានដល់ អារម្មណាធិបតិនិងសហជាតាធិបតិ ។ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ។បេ។ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។បេ។

[ ៥៦០ ] អព្យាកតធម៌ជាអនិយតៈ អាស្រ័យនូវអព្យាកតធម៌ ជាអនិយតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៦១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

**ចប់ និយតទុកកុសលត្តិកៈ ។**

## សឧត្តរទុកកុសលត្តិកៈ

[ ៥៦២ ] សឧត្តរកុសលធម៌ អាស្រ័យនូវសឧត្តរកុសលធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អនុត្តរកុសលធម៌ អាស្រ័យនូវអនុត្តរកុ-

សលធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៦៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៥៦៤ ] សឧត្តរអកុសលធម៌ អាស្រ័យនូវសឧត្តរអកុសលធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៦៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៥៦៦ ] សឧត្តរអព្យាកតធម៌ អាស្រ័យនូវសឧត្តរអព្យាកតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អនុត្តរអព្យាកតធម៌ អាស្រ័យនូវអនុត្តរ-អព្យាកតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៦៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

( ទុកៈនេះ ) ប្រហែលគ្នានឹងលោកិយលោកុត្តរទុកអព្យាកតៈដែរ ។

**ចប់ សឧត្តរទុកកុសលត្តិកៈ ។**

## សរណាទុកកុសលត្តិកៈ

[ ៥៦៨ ] កុសលធម៌ជាអរណៈ ( កុសលធម៌ដែលមិនមានសេចក្តីសៅហ្មង ) អាស្រ័យនូវកុសលធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៦៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៥៧០ ] អកុសលធម៌ជាសរណៈ ( អកុសលធម៌ ដែលប្រកបដោយគ្រឿងសៅហ្មង ) អាស្រ័យនូវអកុសលធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៧១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

[ ៥៧២ ] អព្យាកតធម៌ជាអរណៈ អាស្រ័យនូវអព្យាកតធម៌ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៧៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី សម្បយុត្តវារៈក្តី មានតែវារៈ ១ ។

[ ៥៧៤ ] អព្យាកតធម៌ជាអរណៈ ជាបច្ច័យនៃអព្យាកតធម៌ជាអរណៈ

ដោយហេតុប្បច្ច័យ ។

[ ៥៧៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

បញ្ហាវារៈក្នុងកុសលត្តិកៈយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ
យ៉ាងនោះចុះ ។

**ចប់ សរណទុកកុសលត្តិកៈ ។**

## សរណទុកវេទនាត្តិកៈ

[ ៥៧៦ ] ធម៌ជាសរណៈ សម្បយុត្តដោយសុខវេទនា អាស្រ័យនូវធម៌ជាសរណៈ សម្បយុត្តដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអរណៈ សម្បយុត្តដោយសុខវេទនា អាស្រ័យនូវធម៌ជាអរណៈ សម្បយុត្តដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៧៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់ បណ្ឌិត
គប្បីឲ្យពិស្តារផងចុះ ។

[ ៥៧៨ ] ធម៌ជាសរណៈ សម្បយុត្តដោយទុក្ខវេទនា អាស្រ័យនូវធម៌ជាសរណៈ សម្បយុត្តដោយទុក្ខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៧៩ ] ធម៌ជាសរណៈ សម្បយុត្តដោយទុក្ខវេទនា អាស្រ័យនូវធម៌ជាសរណៈ សម្បយុត្តដោយទុក្ខវេទនា ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៥៨០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់ បណ្ឌិត
គប្បីឲ្យពិស្តារផងចុះ ។

[ ៥៨១ ] ធម៌ជាសរណៈ សម្បយុត្តដោយអទុក្ខមសុខវេទនា អាស្រ័យនូវធម៌ជាសរណៈ សម្បយុត្តដោយអទុក្ខមសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអរណៈ សម្បយុត្តដោយអទុក្ខមសុខវេទនា អាស្រ័យនូវធម៌ជាអរណៈ សម្បយុត្តដោយអទុក្ខមសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៨២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់ បណ្ឌិត
គប្បីឲ្យពិស្តារផងចុះ ។

**ចប់ សរណទុកវេទនាត្តិកៈ ។**

# សរណទុកវិបាកត្តិកៈ

[ ៥៨៣ ] វិបាកធម៌ជាអរណៈ អាស្រ័យនូវធម៌ជាអរណៈ ជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៨៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

[ ៥៨៥ ] ធម៌មានវិបាកជាប្រក្រតី ជាសរណៈ អាស្រ័យនូវធម៌មានវិបាកជាប្រក្រតី ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មានវិបាកជាប្រក្រតី ជាអរណៈ អាស្រ័យនូវធម៌មានវិបាកជាប្រក្រតី ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៨៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៥៨៧ ] ធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ជាអរណៈ អាស្រ័យនូវធម៌មិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៨៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

**ចប់ សរណទុកវិបាកត្តិកៈ ។**

# សរណទុកឧបាទិន្នត្តិកៈ

[ ៥៨៩ ] ឧបាទិន្នុបាទានិយធម៌ ( ធម៌ដែលកម្មគឺកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ធម៌មានកម្ម គឺកិលេស មានតណ្ហាជាដើមកាន់យក ) ជាអរណៈ អាស្រ័យនូវឧបាទិន្នុបាទានិយធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៩០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៥៩១ ] អនុបាទិន្នុបាទានិយធម៌ ( ធម៌មានកម្ម គឺកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ធម៌មានកម្ម គឺកិលេសមានតណ្ហាជាដើមកាន់យក ) ជាសរណៈ អាស្រ័យនូវអនុបាទិន្នុបាទានិយធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អនុបាទិន្នុបាទានិយធម៌ ជាអរណៈ អាស្រ័យនូវអនុបាទិន្នុបាទានិយធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៩២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី ក្នុងបច្ច័យទាំងអស់ បណ្ឌិត
គប្បីឲ្យពិស្តារផងចុះ ។

[ ៥៩៣ ] អនុបាទិន្នអនុបាទានិយធម៌ ( ធម៌មានកម្មគឺកិលេស មាន

តណ្ហាជាដើមមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ធម៌មានកម្ម គឺកិលេសមានតណ្ហាជាដើមមិនកាន់យក ) ជាអរណៈ អាស្រ័យនូវអនុបាទិន្នអនុបាទានិយធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៩៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

ចប់ សរណទុកឧបាទិន្នត្តិកៈ ។

## សរណទុកសង្កិលិដ្ឋត្តិកៈ

[ ៥៩៥ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ( ធម៌ដែលសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មង ) ជាសរណៈ អាស្រ័យនូវសង្កិលិដ្ឋសង្កិលេសិកធម៌ ( ធម៌ដែលសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មង ) ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៩៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៥៩៧ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ( ធម៌ដែលមិនសៅហ្មងតែគួរដល់សេចក្តីសៅហ្មង ) ជាអរណៈ អាស្រ័យនូវអសង្កិលិដ្ឋសង្កិលេសិក

ធម៌ ( ធម៌ដែលមិនសៅហ្មងតែគួរដល់សេចក្ដីសៅហ្មង ) ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៩៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្ដី បញ្ហាវារៈក្ដី មានតែវារៈ ១ ។

[ ៥៩៩ ] អសង្កិលិដ្ឋអសង្កិលេសិកធម៌ ( ធម៌ដែលមិនសៅហ្មងទាំងមិនគួរដល់សេចក្ដីសៅហ្មង ) ជាអរណៈ អាស្រ័យនូវអសង្កិលិដ្ឋអសង្កិ-លេសិកធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦០០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្ដី បញ្ហាវារៈក្ដី មានតែវារៈ ១ ។

**ចប់ សរណទុកសង្កិលិដ្ឋត្តិកៈ ។**

## សរណទុកវិតក្កត្តិកៈ

[ ៦០១ ] សវិតក្កសវិចារធម៌ ( ធម៌ប្រកបដោយការត្រិះរិះ ប្រកបដោយការពិចារណា ) ជាសរណៈ អាស្រ័យនូវសវិតក្កសវិចារធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ សវិតក្កសវិចារធម៌ ជាអរណៈ អា-ស្រ័យនូវសវិតក្កសវិចារធម៌ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦០២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៦០៣ ] អវិតក្កវិចារមត្តធម៌ ( ធម៌មិនមានវិតក្កៈគ្រាន់តែមានវិចារៈ ) ជាអរណៈ អាស្រ័យនូវអវិតក្កវិចារមត្តធម៌ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦០៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

[ ៦០៥ ] អវិតក្កអវិចារធម៌ ( ធម៌មិនប្រកបដោយសេចក្តីត្រិះរិះទាំងមិនប្រកបដោយការពាវរក ) ជាអរណៈ អាស្រ័យនូវអវិតក្កអវិចារធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦០៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

**ចប់ សរណទុកវិតក្កត្តិកៈ ។**

## សរណទុកបីតិត្តិកៈ

[ ៦០៧ ] បីតិសហគតធម៌ ( ធម៌ប្រកបដោយបីតិ ) ជាសរណៈ អា-

ស្រ័យនូវបីតិសហគតធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បីតិសហគតធម៌ ជាអរណៈ អាស្រ័យនូវបីតិសហគតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦០៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងបច្ច័យទាំងអស់ សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៦០៩ ] សុខសហគតធម៌ ( ធម៌ប្រកបដោយសុខ ) ជាសរណៈ អាស្រ័យនូវសុខសហគតធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ សុខសហគតធម៌ ជាអរណៈ អាស្រ័យនូវសុខសហគតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦១០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៦១១ ] ឧបេក្ខាសហគតធម៌ ( ធម៌ប្រកបដោយឧបេក្ខា ) ជាសរណៈ អាស្រ័យនូវឧបេក្ខាសហគតធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ឧបេក្ខាសហគតធម៌ ជាអរណៈ អាស្រ័យនូវឧបេក្ខាសហគតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦១២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងបច្ច័យទាំងអស់ សហជាតវារៈក្តី បញ្ហាវារៈក្តី

បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

**ចប់ សរណទុកបីតិត្តិកៈ ។**

## សរណទុកទស្សនត្តិកៈ

[ ៦១៣ ] ទស្សនេនបហាតព្វធម៌ ( ធម៌ដែលត្រូវលះដោយទស្សនៈ ) ជាសរណៈ អាស្រ័យនូវទស្សនេនបហាតព្វធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦១៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦១៥ ] ភាវនាយបហាតព្វធម៌ ជាសរណៈ អាស្រ័យនូវភាវនាយ-បហាតព្វធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦១៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦១៧ ] នេវទស្សនេនភាវនាយបហាតព្វធម៌ ( ធម៌ដែលមិនត្រូវ

លះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា ) ជាអរណៈ អាស្រ័យនូវនៅទស្សនេននភាវនាយបហាតព្វធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦១៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ដែរ ។

ចប់ សរណទុកទស្សនត្តិកៈ ។

## សរណទុកទស្សនេនបហាតព្វហេតុកត្តិកៈ

[ ៦១៩ ] ទស្សនេនបហាតព្វហេតុកធម៌ ( ធម៌មានហេតុដែលត្រូវលះដោយទស្សនៈ ) ជាសរណៈ អាស្រ័យនូវទស្សនេនបហាតព្វហេតុកធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦២០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦២១ ] ភាវនាយបហាតព្វហេតុកធម៌ ( ធម៌មានហេតុដែលត្រូវលះដោយភាវនា ) ជាសរណៈ អាស្រ័យនូវភាវនាយបហាតព្វហេតុកធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦២២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

[ ៦២៣ ] នេវទស្សនេនភាវនាយបហាតព្វហេតុកធម៌ ( ធម៌មានហេតុដែលមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ) ជាអរណៈ អាស្រ័យនូវនេវទស្សនេនភាវនាយបហាតព្វហេតុកធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦២៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

បណ្ឌិតគប្បីឲ្យពិស្តារ គ្រប់បច្ច័យទាំងអស់ចុះ ។

**ចប់ សរណទុកទស្សនេនបហាតព្វហេតុកត្តិកៈ ។**

# សរណទុកអាចយគាមិត្តិកៈ

[ ៦២៥ ] អាចយគាមិធម៌ ( ធម៌ដល់នូវការសន្សំកពូនឡើង ) ជាសរណៈ អាស្រ័យនូវអាចយគាមិធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អាចយគាមិធម៌ ជាអរណៈ អាស្រ័យនូវអាចយគាមិធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦២៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សឹងមាន
សេចក្តីពិស្តារ ។

[ ៦២៧ ] អបចយគាមិធម៌ ( ធម៌មិនដល់នូវការសន្សំកពូនឡើង ) ជាអរណៈ អាស្រ័យនូវអបចយគាមិធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦២៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

[ ៦២៩ ] នេវាចយគាមិនាបចយគាមិធម៌ ( ធម៌មិនមែនដល់នូវការសន្សំកពូនឡើង ទាំងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង ) ជាអរណៈ អាស្រ័យនូវនេវាចយគាមិនាបចយគាមិធម៌ ជាអរណៈ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។

[ ៦៣០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

**ចប់ សរណទុកអាចយគាមិត្តិកៈ ។**

# សរណទុកសេក្ខត្តិកៈ

[ ៦៣១ ] សេក្ខធម៌ ( ធម៌របស់សេក្ខបុគ្គល ) ជាអរណៈ អាស្រ័យនូវសេក្ខធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៣២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦៣៣ ] អសេក្ខធម៌ ( ធម៌របស់អសេក្ខបុគ្គល ) ជាអរណៈ អាស្រ័យនូវអសេក្ខធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៣៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦៣៥ ] នេវសេក្ខានាសេក្ខធម៌ ជាសរណៈ អាស្រ័យនូវនេវសេក្ខានាសេក្ខធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៣៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សឹងមាន
សេចក្តីពិស្តារ ។

**ចប់ សរណទុកសេក្ខត្តិកៈ ។**

# សរណទុកបរិត្តត្តិកៈ

[ ៦៣៧ ] បរិត្តធម៌ ( ធម៌ដែលមានសភាពតូចឆ្មារ ) ជាសរណៈ អាស្រ័យនូវបរិត្តធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៣៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សឹងមាន សេចក្តីពិស្តារ ។

[ ៦៣៩ ] មហគ្គតធម៌ ( ធម៌ដល់នូវសភាពធំ ) ជាអរណៈ អាស្រ័យនូវមហគ្គតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៤០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦៤១ ] អប្បមាណធម៌ ជាអរណៈ អាស្រ័យនូវអប្បមាណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៤២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានវារៈតែ ១ ។

**ចប់ សរណទុកបរិត្តត្តិកៈ ។**

# សរណទុកបរិត្តារម្មណត្តិកៈ

[ ៦៤៣ ] បរិត្តារម្មណធម៌ ( ធម៌មានអារម្មណ៍តូចឆ្មារ ) ជាសរណៈ អាស្រ័យនូវបរិត្តារម្មណធម៌ ជាសរណៈ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។

[ ៦៤៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សឹងមាន សេចក្តីពិស្តារ ។

[ ៦៤៥ ] មហគ្គតារម្មណធម៌ ជាសរណៈ អាស្រ័យនូវមហគ្គតារម្មណធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៤៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៦៤៧ ] អប្បមាណារម្មណធម៌ ជាអរណៈ អាស្រ័យនូវអប្បមាណារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៤៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

**ចប់ សរណទុកបរិត្តារម្មណត្តិកៈ ។**

# សរណទុកហីនត្តិកៈ

[ ៦៤៩ ] ហីនធម៌ ( ធម៌ដ៏ថោកទាប ) ជាសរណៈ អាស្រ័យនូវហីនធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៥០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦៥១ ] មជ្ឈិមធម៌ ( ធម៌ជាកណ្តាល ) ជាអរណៈ អាស្រ័យនូវមជ្ឈិមធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៥២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦៥៣ ] បណីតធម៌ ( ធម៌ដ៏ឧត្តម ) ជាអរណៈ អាស្រ័យនូវបណីតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៥៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

**ចប់ សរណទុកហីនត្តិកៈ ។**

# សរណាទុកមិច្ឆត្តត្តិកៈ

[ ៦៥៥ ] មិច្ឆត្តនិយតធម៌ ( ធម៌មានសភាពខុសនិងទៀង ) ជាសរណៈ អាស្រ័យនូវមិច្ឆត្តនិយតធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៥៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦៥៧ ] សម្មត្តនិយតធម៌ ( ធម៌មានសភាពត្រូវនិងទៀង ) ជាអរណៈ អាស្រ័យនូវសម្មត្តនិយតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៥៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦៥៩ ] អនិយតធម៌ ( ធម៌មានសភាពមិនទៀង ) ជាសរណៈ អាស្រ័យនូវអនិយតធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៦០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សឹងមាន
សេចក្តីពិស្តារ ។

**ចប់ សរណទុកមិច្ឆត្តត្តិកៈ ។**

# សរណទុកមគ្គារម្មណត្តិកៈ

[ ៦៦១ ] មគ្គារម្មណធម៌ ជាអរណៈ អាស្រ័យនូវមគ្គារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៦២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦៦៣ ] មគ្គហេតុកធម៌ ជាអរណៈ អាស្រ័យនូវមគ្គហេតុកធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៦៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦៦៥ ] មគ្គាធិបតិធម៌ ( ធម៌ដែលមានមគ្គជាអធិបតិ ) ជាអរណៈ អាស្រ័យនូវមគ្គាធិបតិធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៦៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

ចប់ សរណទុកមគ្គារម្មណត្តិកៈ ។

## សរណទុកឧប្បន្នត្តិកៈ

[ ៦៦៧ ] ឧប្បន្នធម៌ ជាសរណៈ ជាបច្ច័យនៃឧប្បន្នធម៌ ជាសរណៈ ដោយហេតុប្បច្ច័យ ឧប្បន្នធម៌ ជាសរណៈ ជាបច្ច័យនៃឧប្បន្នធម៌ជាអរណៈ ដោយហេតុប្បច្ច័យ ឧប្បន្នធម៌ ជាសរណៈ ជាបច្ច័យនៃឧប្បន្នធម៌ជាសរណៈផង នៃឧប្បន្នធម៌ជាអរណៈផង ដោយហេតុប្បច្ច័យ ។ ឧប្បន្នធម៌ជាអរណៈ ជាបច្ច័យនៃឧប្បន្នធម៌ជាអរណៈ ដោយហេតុប្បច្ច័យ ។

[ ៦៦៨ ] ឧប្បន្នធម៌ជាអរណៈ ជាបច្ច័យនៃឧប្បន្នធម៌ជាអរណៈ ដោយអារម្មណប្បច្ច័យ ។

[ ៦៦៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

បញ្ហាវារៈក្នុងកុសលត្តិកៈយ៉ាងណា បណ្ឌិត គប្បីឲ្យពិស្តារ
យ៉ាងនោះចុះ ។

**ចប់ សរណទុកឧប្បន្នត្តិកៈ ។**

## សរណទុកអតីតត្តិកៈ

[ ៦៧០ ] បច្ចុប្បន្នធម៌ជាសរណៈ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ជាសរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ បច្ចុប្បន្នធម៌ជាអរណៈ ជាបច្ច័យនៃបច្ចុប្បន្នធម៌ជាអរណៈ ដោយហេតុប្បច្ច័យ ។

[ ៦៧១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

បញ្ហាវារៈក្នុងកុសលត្តិកៈយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ សរណទុកអតីតត្តិកៈ ។**

## សរណទុកអតីតារម្មណត្តិកៈ

[ ៦៧២ ] អតីតារម្មណធម៌ជាសរណៈ អាស្រ័យនូវអតីតារម្មណធម៌ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អតីតារម្មណធម៌ ជាអរណៈ អាស្រ័យនូវអតីតារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៧៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សឹងមានសេចក្តីពិស្តារ ។

[ ៦៧៤ ] អនាគតារម្មណធម៌ជាសរណៈ អាស្រ័យនូវអនាគតារម្មណធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អនាគតារម្មណធម៌ជាអរណៈ អាស្រ័យនូវអនាគតារម្មណធម៌ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៧៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សឹងមាន
សេចក្តីពិស្តារ ។

[ ៦៧៦ ] បច្ចុប្បន្នារម្មណធម៌ ជាសរណៈ អាស្រ័យនូវបច្ចុប្បន្នារម្មណធម៌ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បច្ចុប្បន្នារម្មណធម៌ ជាអរណៈ អាស្រ័យនូវបច្ចុប្បន្នារម្មណធម៌ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៧៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សឹងមាន
សេចក្តីពិស្តារ ។

**ចប់ សរណទុកអតីតារម្មណត្តិកៈ ។**

# សរណទុកអជ្ឈត្តត្តិកៈ

[ ៦៧៨ ] អជ្ឈត្តធម៌ជាសរណៈ អាស្រ័យនូវអជ្ឈត្តធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អជ្ឈត្តធម៌ ជាអរណៈ អាស្រ័យនូវអជ្ឈត្តធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៧៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សឹងមាន
សេចក្តីពិស្តារ ។

[ ៦៨០ ] ពហិទ្ធាធម៌ជាសរណៈ អាស្រ័យនូវពហិទ្ធាធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ពហិទ្ធាធម៌ ជាអរណៈ អាស្រ័យនូវពហិទ្ធាធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៨១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
សឹងមានសេចក្តីពិស្តារ ។

**ចប់ សរណទុកអជ្ឈត្តត្តិកៈ ។**

## សរណទុកអជ្ឈត្តារម្មណត្តិកៈ

[ ៦៨២ ] អជ្ឈត្តារម្មណធម៌ជាសរណៈ អាស្រ័យនូវអជ្ឈត្តារម្មណធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អជ្ឈត្តារម្មណធម៌ ជាអរណៈ អាស្រ័យនូវអជ្ឈត្តារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៨៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី សឹងមានសេចក្តីពិស្តារ ។

[ ៦៨៤ ] ពហិទ្ធារម្មណធម៌ជាសរណៈ អាស្រ័យនូវពហិទ្ធារម្មណធម៌ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ពហិទ្ធារម្មណធម៌ ជាអរណៈ អាស្រ័យនូវពហិទ្ធារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៨៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី សឹងមានសេចក្តីពិស្តារ ។

**ចប់ សរណទុកអជ្ឈត្តារម្មណត្តិកៈ ។**

## សរណទុកសនិទស្សនត្តិកៈ

[ ៦៨៦ ] អនិទស្សនសប្បដិឃធម៌ជាអរណៈ អាស្រ័យនូវអនិទស្សនសប្បដិឃធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៨៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ

១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦៨៨ ] អនិទស្សនអប្បដិឃធម៌ជាសរណៈ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អនិទស្សនអប្បដិឃធម៌ជាអរណៈ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អនិទស្សនអប្បដិឃធម៌ ជាអរណៈ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ជាសរណៈផង នូវអនិទស្សនអប្បដិឃធម៌ ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៨៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៦៩០ ] អនិទស្សនអប្បដិឃធម៌ជាសរណៈ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ជាសរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អនិទស្សនអប្បដិឃធម៌ ជាអរណៈ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ ។

[ ៦៩១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

[ ៦៩២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ។

[ ៦៩៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះហេតុប្បច្ច័យ ។

[ ៦៩៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុលោមក្តី នៃបញ្ហាវារៈក្នុងកុសលត្តិកៈ ដែលយើងបានរាប់ហើយយ៉ាងណា បណ្ឌិតគប្បីរាប់យ៉ាងនោះចុះ ។

**ចប់ សរណទុកសនិទស្សនត្តិកៈ ។**

**ចប់ បិដិទុកត្តិកៈ ។**

**ចប់ អនុលោមទុកត្តិកប្បដ្ឋាន ។**

# អនុលោមត្តិកទុកប្បដ្ឋាន

# កុសលត្តិកហេតុទុកៈ

[ ៦៩៥ ] ហេតុធម៌ជាកុសល អាស្រ័យនូវហេតុធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុធម៌ជាអកុសល អាស្រ័យនូវហេតុធម៌ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវហេតុធម៌ជាអព្យាក្រឹត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៩៦ ] ហេតុធម៌ជាកុសល អាស្រ័យនូវហេតុធម៌ជាកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ ហេតុធម៌ជាអកុសល អាស្រ័យនូវហេតុធម៌ជាអកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ ហេតុធម៌ជាអព្យាក្រឹតអាស្រ័យនូវហេតុធម៌ ជាអព្យាក្រឹត ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៦៩៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៦៩៨ ] ហេតុធម៌ជាកុសល អាស្រ័យនូវហេតុធម៌ជាកុសល ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។ ហេតុធម៌ជាអកុសល អាស្រ័យនូវហេតុធម៌ជាអកុសល ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។ ហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវហេតុធម៌ជាអព្យាក្រឹត ទើបកើតឡើង ព្រោះនអធិ-បតិប្បច្ច័យ ។

[ ៦៩៩ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

[ ៧០០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧០១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ព្រោះនអធិបតិប្បច្ច័យ ។

ក្នុងសហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តីសម្បយុត្តវារៈក្តី សុទ្ធតែមានវារៈ ៣ គ្រប់បទទាំងអស់ ។

[ ៧០២ ] ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ ជាកុសល ដោយហេតុប្បច្ច័យ ។ ហេតុធម៌ជាអកុសល ជាបច្ច័យនៃហេតុធម៌ ជាអកុសល ដោយហេតុប្បច្ច័យ ។ ហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃហេតុធម៌ជាអព្យា-ក្រឹត ដោយហេតុប្បច្ច័យ ។

[ ៧០៣ ] ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ជាកុសល ដោយអារម្មណប្បច្ច័យ ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ ជាអកុសល

ដោយអារម្មណប្បច្ច័យ ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ ជាអព្យាក្រឹត ដោយអារម្មណប្បច្ច័យ ។ ហេតុធម៌ជាអកុសល ជាបច្ច័យនៃហេតុធម៌ជាអកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ ហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃហេតុធម៌ ជាអព្យាក្រឹត ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៧០៤ ] ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ជាកុសល ដោយអធិបតិប្បច្ច័យ ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ ជាអកុសល ដោយអធិបតិប្បច្ច័យ ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ជាអព្យាក្រឹត ដោយអធិបតិប្បច្ច័យ មានវារៈ ៣ ។ ហេតុធម៌ជាអកុសល ជាបច្ច័យនៃហេតុធម៌ជាអកុសល ដោយអធិបតិប្បច្ច័យ ។ ហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃហេតុធម៌ ជាអព្យាក្រឹត ដោយអធិបតិប្បច្ច័យ ។បេ។ ហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃហេតុធម៌ជាអកុសល ដោយអធិបតិប្បច្ច័យ មានវារៈ ៣ ។

[ ៧០៥ ] ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ជាកុសល ដោយអនន្តរប្បច្ច័យ មានវារៈ ២ ។ ហេតុធម៌ជាអកុសល ជាបច្ច័យនៃហេតុធម៌ជាអកុសល ដោយអនន្តរប្បច្ច័យ មានវារៈ ២ ។ ហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃហេតុធម៌ជាអព្យាក្រឹត ដោយអនន្តរប្បច្ច័យ ។

[ ៧០៦ ] ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ជាកុសល ដោយសហជាតប្បច្ច័យ ។ ហេតុធម៌ជាអកុសល ជាបច្ច័យនៃហេតុធម៌ជាអកុសល ដោយសហជាតប្បច្ច័យ ។ ហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃហេតុធម៌ ជា

អព្យាក្រឹត ដោយសហជាតប្បច្ច័យ ។

អញ្ញមញ្ញនិស្សយប្បច្ច័យ ប្រហែលគ្នានឹងសហជាតប្បច្ច័យដែរ ។

[ ៧០៧ ] ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ជាកុសល ដោយឧបនិស្សយប្បច្ច័យ ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ ជាអកុសលដោយឧបនិស្សយប្បច្ច័យ ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ ជាអព្យាក្រឹត ដោយឧបនិស្សយប្បច្ច័យ ។ ហេតុធម៌ជាអកុសល ជាបច្ច័យនៃហេតុធម៌ជាអកុសល ដោយឧបនិស្សយប្បច្ច័យ ហេតុធម៌ជាអកុសល ជាបច្ច័យនៃហេតុធម៌ជាកុសល ដោយឧបនិស្សយប្បច្ច័យ ហេតុធម៌ជាអកុសល ជាបច្ច័យនៃហេតុធម៌ជាអព្យាក្រឹត ដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។ ហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃហេតុធម៌ជាអព្យាក្រឹត ដោយឧបនិស្សយប្បច្ច័យ ហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃហេតុធម៌ជាកុសល ដោយឧបនិស្សយប្បច្ច័យ ហេតុធម៌ជាអព្យាក្រឹតជាបច្ច័យនៃហេតុធម៌ ជាអកុសលដោយឧបនិស្សយប្បច្ច័យ ។

[ ៧០៨ ] ហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃហេតុធម៌ ជាអព្យាក្រឹតដោយវិបាកប្បច្ច័យ ។

[ ៧០៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុង

ឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ២ ក្នុងមគ្គប្បច្ច័យ មានវារៈ ២ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងវិគតប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៧១០ ] ហេតុធម៌ជាកុសល ជាបច្ច័យនៃហេតុធម៌ជាកុសល ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ហេតុធម៌ជាកុសលជាបច្ច័យនៃហេតុធម៌ជាអកុសល ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ហេតុធម៌ជាកុសលជាបច្ច័យនៃហេតុធម៌ជាអព្យាក្រឹត ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ហេតុធម៌ជាអកុសល ជាបច្ច័យនៃហេតុធម៌ជាអកុសល ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ហេតុធម៌ជាអកុសល ជាបច្ច័យនៃហេតុធម៌ ជាកុសល ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ហេតុធម៌ជាអកុសល ជាបច្ច័យនៃហេតុធម៌ ជាអព្យាក្រឹត ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ។ ហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃហេតុធម៌ជាអព្យាក្រឹត ដោយអារម្មណប្បច្ច័យ ជាបច្ច័យដោយសហជាតប្បច្ច័យ ជាបច្ច័យដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។

[ ៧១១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មាន

វារៈ ៩ ។

[ ៧១២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧១៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

អនុលោមក្តី បច្ចនីយៈក្តី អនុលោមប្បច្ចនីយៈក្តី បច្ចនីយានុ-លោមក្តី នៃបញ្ហាវារៈ ក្នុងកុសលត្តិកៈ ដែលយើងរាប់ហើយយ៉ាងណា បណ្ឌិតគប្បីរាប់យ៉ាងនោះចុះ ។

[ ៧១៤ ] នហេតុធម៌ជាកុសល អាស្រ័យនូវនហេតុធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ជាកុសលក្តី នហេតុធម៌ជាអព្យាក្រឹតក្តី អាស្រ័យនូវនហេតុធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ជាអកុសល អាស្រ័យនូវនហេតុធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ជាអកុសលក្តី នហេតុធម៌ជាអព្យាក្រឹតក្តី អាស្រ័យនូវនហេតុធម៌ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ជាអព្យាក្រឹត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ ជាកុសលផង នូវនហេតុធម៌ជាអព្យាក្រឹតផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ ជាអកុសលផង នូវ

នហេតុធម៌ជាអព្យាក្រឹតផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧១៥ ] នហេតុធម៌ជាកុសល អាស្រ័យនូវនហេតុធម៌ ជាកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ នហេតុធម៌ជាអកុសល អាស្រ័យនូវនហេតុធម៌ជាអកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ នហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ជាអព្យាក្រឹត ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៧១៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៩ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៩ ក្នុងមគ្គប្បច្ច័យ មានវារៈ ៩ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៩ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងវិគតប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៧១៧ ] នហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ជាអព្យាក្រឹត

ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៧១៨ ] នហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ជាកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ នហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ជាអកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ នហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ជាអព្យាក្រឹត ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ នហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ជាកុសលផង នូវនហេតុធម៌ជាអព្យាក្រឹតផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ នហេតុធម៌ជាអព្យាក្រឹត អាស្រ័យនូវនហេតុធម៌ជាកុសលផង នូវនហេតុធម៌ជាអព្យាក្រឹតផង ទើបកើតឡើងព្រោះនអារម្មណប្បច្ច័យ ។

[ ៧១៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៧ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៩ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៩ ក្នុងនអាហារប្បច្ច័យ មានវារៈ ១ ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ១ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៧២០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ។

[ ៧២១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។ សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារ ដូចបដិច្ចវារៈដែរ ។

[ ៧២២ ] នហេតុធម៌ជាកុសល ជាបច្ច័យនៃនហេតុធម៌ ជាកុសល ដោយអារម្មណប្បច្ច័យ នហេតុធម៌ជាកុសល ជាបច្ច័យនៃនហេតុធម៌ ជាអកុសល ដោយអារម្មណប្បច្ច័យ នហេតុធម៌ជាកុសល ជាបច្ច័យនៃនហេតុធម៌ជាអព្យាក្រឹត ដោយអារម្មណប្បច្ច័យ ។ នហេតុធម៌ជាអកុសល ជាបច្ច័យនៃនហេតុធម៌ ជាអកុសល ដោយអារម្មណប្បច្ច័យ នហេតុធម៌ ជាអកុសល ជាបច្ច័យនៃនហេតុធម៌ជាកុសល ដោយអារម្មណប្បច្ច័យ នហេតុធម៌ជាអកុសល ជាបច្ច័យនៃនហេតុធម៌ ជាអព្យាក្រឹត ដោយអារម្មណប្បច្ច័យ ។ នហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃនហេតុធម៌ជាអព្យាក្រឹត ដោយអារម្មណប្បច្ច័យ នហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃនហេតុធម៌ ជាកុសល ដោយអារម្មណប្បច្ច័យ នហេតុធម៌ ជាអព្យាក្រឹត ជាបច្ច័យនៃនហេតុធម៌ជាអកុសល ដោយអារម្មណប្បច្ច័យ ។

[ ៧២៣ ] នហេតុធម៌ជាកុសល ជាបច្ច័យនៃនហេតុធម៌ ជាកុសល ដោយអធិបតិប្បច្ច័យ នហេតុធម៌ជាកុសល ជាបច្ច័យនៃនហេតុធម៌ជាអកុសល ដោយអធិបតិប្បច្ច័យ មានវារៈ ៤ ។ នហេតុធម៌ជាអកុសល ជាបច្ច័យនៃនហេតុធម៌ជាអកុសល ដោយអធិបតិប្បច្ច័យ មានវារៈ ៣ ។ នហេតុធម៌

ជាអព្យាក្រឹត ជាបច្ច័យនៃនហេតុធម៌ ជាអព្យាក្រឹត ដោយអធិបតិប្បច្ច័យ នហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃនហេតុធម៌ជាកុសល ដោយអធិប-តិប្បច្ច័យ មានវារៈ ៣ ។

[ ៧២៤ ] នហេតុធម៌ជាកុសល ជាបច្ច័យនៃនហេតុធម៌ជាកុសល ដោយអនន្តរប្បច្ច័យ នហេតុធម៌ជាកុសល ជាបច្ច័យនៃនហេតុធម៌ ជាអព្យាក្រឹត ដោយអនន្តរប្បច្ច័យ ។ នហេតុធម៌ជាអកុសល ជាបច្ច័យនៃនហេតុធម៌ ជាអកុសល ដោយអនន្តរប្បច្ច័យ នហេតុធម៌ជាអកុសល ជាបច្ច័យនៃនហេតុ-ធម៌ជាអព្យាក្រឹត ដោយអនន្តរប្បច្ច័យ ។ នហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃនហេតុធម៌ជាអព្យាក្រឹត ដោយអនន្តរប្បច្ច័យ មានវារៈ ៣ ។

[ ៧២៥ ] នហេតុធម៌ជាកុសល ជាបច្ច័យនៃនហេតុធម៌ ជាកុសល ដោយឧបនិស្សយប្បច្ច័យ នហេតុធម៌ជាកុសល ជាបច្ច័យនៃនហេតុធម៌ ជាអកុសល ដោយឧបនិស្សយប្បច្ច័យ នហេតុធម៌ជាកុសល ជាបច្ច័យនៃន-ហេតុធម៌ជាអព្យាក្រឹត ដោយឧបនិស្សយប្បច្ច័យ ។ នហេតុធម៌ជាអកុសល ជាបច្ច័យនៃនហេតុធម៌ជាអកុសល ដោយឧបនិស្សយប្បច្ច័យ នហេតុធម៌ជាអកុសល ជាបច្ច័យនៃនហេតុធម៌ ជាកុសល ដោយឧបនិស្សយប្បច្ច័យ នហេតុធម៌ជាអកុសល ជាបច្ច័យនៃនហេតុធម៌ជាអព្យាក្រឹត ដោយឧបនិស្ស-យប្បច្ច័យ ។ នហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃនហេតុធម៌ ជាអព្យាក្រឹត ដោយឧបនិស្សយប្បច្ច័យ នហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យនៃនហេតុធម៌ ជាកុសល ដោយឧបនិស្សយប្បច្ច័យ នហេតុធម៌ជាអព្យាក្រឹត ជាបច្ច័យ

នៃនហេតុធម៌ជាអកុសល ដោយឧបនិស្សយប្បច្ច័យ ។

[ ៧២៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៧ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៧ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

[ ៧២៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៥ ។

[ ៧២៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ព្រោះអារម្មណប្បច្ច័យ ។

[ ៧២៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

បញ្ហាវារៈក្នុងកុសលត្តិកៈយ៉ាងណា បណ្ឌិត

គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ កុសលត្តិកហេតុទុកៈ ។**

# វេទនាត្តិកហេតុទុកៈ

[ ៧៣០ ] ហេតុធម៌ប្រកបដោយសុខវេទនា អាស្រ័យនូវហេតុធម៌ប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុធម៌ប្រកបដោយទុក្ខវេទនា អាស្រ័យនូវហេតុធម៌ ប្រកបដោយទុក្ខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា អាស្រ័យនូវហេតុធម៌ ប្រកបដោយអទុក្ខមសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៣១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៧៣២ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

[ ៧៣៣ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧៣៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី ។បេ។ សម្បយុត្តវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៧៣៥ ] ហេតុធម៌ប្រកបដោយសុខវេទនា ជាបច្ច័យនៃហេតុធម៌ប្រកបដោយសុខវេទនា ដោយហេតុប្បច្ច័យ ។ ហេតុធម៌ប្រកបដោយទុក្ខវេទនា

ជាបច្ច័យនៃហេតុធម៌ប្រកបដោយទុក្ខវេទនា ដោយហេតុប្បច្ច័យ ។ ហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា ដោយហេតុប្បច្ច័យ ។

[ ៧៣៦ ] ហេតុធម៌ប្រកបដោយសុខវេទនា ជាបច្ច័យនៃហេតុធម៌ប្រកបដោយសុខវេទនា ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ ហេតុធម៌ប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃហេតុធម៌ប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ ហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃហេតុធម៌ ប្រកបដោយអទុក្ខមសុខវេទនា ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៧៣៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ២ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ២ ក្នុងមគ្គប្បច្ច័យ មានវារៈ ២ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៦ ក្នុងវិគតប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៧៣៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មាន

វារៈ ៩ ។

[ ៧៣៩ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧៤០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

បញ្ហាវារៈក្នុងកុសលត្តិកៈយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៧៤១ ] នហេតុធម៌ប្រកបដោយសុខវេទនា អាស្រ័យនូវនហេតុធម៌ប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ប្រកបដោយទុក្ខវេទនា អាស្រ័យនូវនហេតុធម៌ប្រកបដោយទុក្ខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា អាស្រ័យនូវនហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៤២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៧៤៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៧៤៤ ] នហេតុធម៌ប្រកបដោយសុខវេទនា ជាបច្ច័យនៃនហេតុធម៌

ប្រកបដោយសុខវេទនា ដោយអារម្មណប្បច្ច័យ នហេតុធម៌ប្រកបដោយសុខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ នហេតុធម៌ប្រកបដោយសុខវេទនា ជាបច្ច័យនៃនហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា ដោយអារម្មណប្បច្ច័យ ។ នហេតុធម៌ប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ នហេតុធម៌ប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយសុខវេទនា ដោយអារម្មណប្បច្ច័យ នហេតុធម៌ប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយអទុក្ខមសុខវេទនា ដោយអារម្មណប្បច្ច័យ ។ នហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃនហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា ដោយអារម្មណប្បច្ច័យ នហេតុធម៌ ប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយសុខវេទនា ដោយអារម្មណប្បច្ច័យ នហេតុធម៌ ប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃនហេតុធម៌ប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ ។

[ ៧៤៥ ] នហេតុធម៌ប្រកបដោយសុខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយសុខវេទនា ដោយអធិបតិប្បច្ច័យ នហេតុធម៌ប្រកបដោយសុខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយអទុក្ខមសុខវេទនា ដោយអធិបតិប្បច្ច័យ ។ នហេតុធម៌ប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយទុក្ខវេទនា ដោយអធិបតិប្បច្ច័យ ។ នហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយអទុក្ខមសុខវេទនា

ដោយអធិបតិប្បច្ច័យ នហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយសុខវេទនា ដោយអធិបតិប្បច្ច័យ ។

[ ៧៤៦ ] នហេតុធម៌ប្រកបដោយសុខវេទនា ជាបច្ច័យនៃនហេតុធម៌ប្រកបដោយសុខវេទនា ដោយអនន្តរប្បច្ច័យ មានវារៈ ២ ។ នហេតុធម៌ប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃនហេតុធម៌ប្រកបដោយទុក្ខវេទនា ដោយអនន្តរប្បច្ច័យ មានវារៈ ២ ។ នហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយអទុក្ខមសុខវេទនា ដោយអនន្តរប្បច្ច័យ មានវារៈ ៣ ។

[ ៧៤៧ ] នហេតុធម៌ប្រកបដោយសុខវេទនា ជាបច្ច័យនៃនហេតុធម៌ប្រកបដោយសុខវេទនា ដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។ នហេតុធម៌ប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយទុក្ខវេទនា ដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។ នហេតុធម៌ប្រកបដោយអទុក្ខមសុខវេទនា ជាបច្ច័យនៃនហេតុធម៌ ប្រកបដោយអទុក្ខមសុខវេទនា ដោយឧបនិស្សយប្បច្ច័យ មានវារៈ ៣ ។

[ ៧៤៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងកម្មប្បច្ច័យ មានវារៈ ៨ ក្នុងវិបា-

កប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៣ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងវិគតប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៧៤៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧៥០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៧៥១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

បញ្ហាវារៈក្នុងកុសលត្តិកៈយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះ ។

**ចប់ វេទនាត្តិកហេតុទុកៈ ។**

# វិបាកត្តិកហេតុទុកៈ

[ ៧៥២ ] ហេតុធម៌ជាវិបាក អាស្រ័យនូវហេតុធម៌ជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុធម៌ជាធម៌មានវិបាកជាប្រកតី អាស្រ័យនូវហេតុធម៌ជាធម៌មានវិបាកជាប្រកតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រកតី អាស្រ័យនូវហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជា

ប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៥៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៧៥៤ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីឲ្យ
ពិស្តារប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៧៥៥ ] ហេតុធម៌ជាវិបាក ជាបច្ច័យនៃហេតុធម៌ជាវិបាក ដោយហេតុប្បច្ច័យ ។ ហេតុធម៌ជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃហេតុធម៌ជាធម៌មានវិបាកជាប្រក្រតី ដោយហេតុប្បច្ច័យ ។ ហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃហេតុធម៌ ជាធម៌មិនមែនជាវិបាកនិងមិនមែនជាធម៌មានវិបាកជាប្រក្រតី ដោយហេតុប្បច្ច័យ ។

[ ៧៥៦ ] ហេតុធម៌ជាវិបាក ជាបច្ច័យនៃហេតុធម៌ ជាវិបាក ដោយអារម្មណប្បច្ច័យ ហេតុធម៌ជាវិបាក ជាបច្ច័យនៃហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ ហេតុធម៌ជាវិបាក ជាបច្ច័យនៃហេតុធម៌ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី ដោយអា-

រម្មណប្បច្ច័យ ។ ហេតុធម៌ជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃហេតុធម៌ជាធម៌មានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ ហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃហេតុធម៌ជាវិបាក ដោយអារម្មណប្បច្ច័យ ហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ ។ ហេតុធម៌ ជាធម៌មិនមែនជាវិបាកនិងមិនមែនជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៧៥៧ ] ហេតុធម៌ជាវិបាក ជាបច្ច័យនៃហេតុធម៌ជាវិបាក ដោយអធិបតិប្បច្ច័យ ហេតុធម៌ជាវិបាក ជាបច្ច័យនៃហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ដោយអធិបតិប្បច្ច័យ ហេតុធម៌ជាវិបាក ជាបច្ច័យនៃហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី ដោយអធិបតិប្បច្ច័យ ។ ហេតុធម៌ជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ដោយអធិបតិប្បច្ច័យ មានវារៈ ២ ។ ហេតុធម៌ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី ដោយអធិបតិប្បច្ច័យ ។

[ ៧៥៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៦ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥

ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៧៥៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ៧៦០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ៧៦១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៧៦២ ] នហេតុធម៌ជាវិបាក អាស្រ័យនូវនហេតុធម៌ជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី អាស្រ័យនូវនហេតុធម៌ ជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ជាវិបាកក្តី នហេតុធម៌ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី អាស្រ័យនូវនហេតុធម៌ជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី អាស្រ័យនូវនហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ជាធម៌មិនមែនជាវិបាកនិងមិនមែនជាធម៌មានវិបាកជាប្រក្រតី អាស្រ័យនូវនហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតីក្តី នហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតីក្តី អាស្រ័យនូវនហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី អាស្រ័យនូវនហេតុធម៌ ជាធម៌មិនមែនជាវិបាកនិងមិនមែនជាធម៌មានវិបាកជាប្រក្រតី ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ នហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី អាស្រ័យនូវនហេតុធម៌ ជាវិបាកផង នូវនហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាក ជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ នហេតុធម៌ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី អាស្រ័យនូវនហេតុធម៌ជាធម៌មានវិបាកជាប្រក្រតីផង នូវនហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតីផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៦៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ១៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ១៣ ក្នុងវិបា-

កប្បច្ច័យ មានវារៈ ៩ ក្នុងអាហារប្បច្ច័យ មានវារៈ ១៣ ។បេ។ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

[ ៧៦៤ ] នហេតុធម៌ជាវិបាក អាស្រ័យនូវនហេតុធម៌ជាវិបាក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៩ ។

[ ៧៦៥ ] នហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី អាស្រ័យនូវនហេតុធម៌ជាវិបាក ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។

[ ៧៦៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៥ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៥ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ១២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ១៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ១៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៥ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារប្រហែលគ្នានឹងបដិច្ចវារៈ ។

[ ៧៦៧ ] នហេតុធម៌ជាវិបាក ជាបច្ច័យនៃនហេតុធម៌ជាវិបាក ដោយអារម្មណប្បច្ច័យ នហេតុធម៌ជាវិបាក ជាបច្ច័យនៃនហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ នហេតុធម៌ជាវិបាក ជាបច្ច័យនៃ

នហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ ។ នហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃនហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ នហេតុធម៌ជាធម៌មិនមែនជាវិបាកនិងមិនមែនជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃនហេតុធម៌ ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៧៦៨ ] នហេតុធម៌ជាវិបាក ជាបច្ច័យនៃនហេតុធម៌ជាវិបាក ដោយអធិបតិប្បច្ច័យ មានវារៈ ៤ ។ នហេតុធម៌ជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃនហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ដោយអធិបតិប្បច្ច័យ មានវារៈ ៣ ។ នហេតុធម៌ ជាធម៌មិនមែនជាវិបាកនិងមិនមែនជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃនហេតុធម៌ ជាធម៌មិនមែនជាវិបាកនិងមិនមែនជាធម៌មានវិបាកជាប្រក្រតី ដោយអធិបតិប្បច្ច័យ នហេតុធម៌ជាធម៌មិនមែនជាវិបាកនិងមិនមែនជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃនហេតុធម៌ជាវិបាក ដោយអធិបតិប្បច្ច័យ មានវារៈ ៣ ។

[ ៧៦៩ ] នហេតុធម៌ជាវិបាក ជាបច្ច័យនៃនហេតុធម៌ជាវិបាក ដោយអនន្តរប្បច្ច័យ មានវារៈ ២ ។ នហេតុធម៌ជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃនហេតុធម៌ ជាធម៌មានវិបាកជាប្រក្រតី ដោយអនន្តរប្បច្ច័យ មានវារៈ ២ ។ នហេតុធម៌ជាធម៌មិនមែនជាវិបាក និងមិនមែនជាធម៌មានវិបាកជាប្រក្រតី ជាបច្ច័យនៃនហេតុធម៌ ជាធម៌មិនមែនជាវិបាកនិងមិនមែនជាធម៌

មានវិបាកជាប្រក្រតី ដោយអនន្តរប្បច្ច័យ មានវារៈ ៣ ។

[ ៧៧០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ១១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៧ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៩ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងអាហារប្បច្ច័យ មានវារៈ ៧ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៩ ក្នុងឈានប្បច្ច័យ មានវារៈ ៧ ក្នុងមគ្គប្បច្ច័យ មានវារៈ ៧ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

[ ៧៧១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១៦ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៦ ។

[ ៧៧២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ។

[ ៧៧៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ វិបាកត្តិកហេតុទុកៈ ។**

# ឧបាទិន្នត្តិកហេតុទុកៈ

[ ១៣០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងសហជាតប្បច្ច័យ មានវារៈ ១ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ២ ក្នុងវិបាកប្បច្ច័យមានវារៈ ១ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ១ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងអត្ថិប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ១៣១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ១៣២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ព្រោះអារម្មណប្បច្ច័យ ។

[ ១៣៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះនហេតុប្បច្ច័យ ។

**ចប់ អតីតត្តិកហេតុទុកៈ ។**

## អតីតារម្មណត្តិកហេតុទុកៈ

[ ១៣៤ ] ហេតុធម៌មានអារម្មណ៍ជាអតីត អាស្រ័យនូវហេតុធម៌ មានអារម្មណ៍ជាអតីត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុធម៌ មានអារម្មណ៍ជាអនាគត អាស្រ័យនូវហេតុធម៌ មានអារម្មណ៍ជាអនាគត ទើប

កើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុធម៌មានអារម្មណ៍ជាបច្ចុប្បន្ន អាស្រ័យនូវហេតុធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៣៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៣៦ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ១៣៧ ] ហេតុធម៌ មានអារម្មណ៍ជាអតីត ជាបច្ច័យនៃហេតុធម៌ មានអារម្មណ៍ជាអតីត ដោយហេតុប្បច្ច័យ ។ ហេតុធម៌មានអារម្មណ៍ជាអនាគត ជាបច្ច័យនៃហេតុធម៌ មានអារម្មណ៍ជាអនាគត ដោយហេតុប្បច្ច័យ ។ ហេតុធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ជាបច្ច័យនៃហេតុធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ដោយហេតុប្បច្ច័យ ។

[ ១៣៨ ] ហេតុធម៌ មានអារម្មណ៍ជាអតីត ជាបច្ច័យនៃហេតុធម៌ មានអារម្មណ៍ជាអតីត ដោយអារម្មណប្បច្ច័យ ហេតុធម៌ មានអារម្មណ៍ជាអតីត ជាបច្ច័យនៃហេតុធម៌មានអារម្មណ៍ជាអនាគត ដោយអារម្មណប្បច្ច័យ ហេតុធម៌ មានអារម្មណ៍ជាអតីត ជាបច្ច័យនៃហេតុធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ដោយអារម្មណប្បច្ច័យ ។ ហេតុធម៌ មានអារម្មណ៍ជាអនាគត ជាបច្ច័យនៃ

ហេតុធម៌ មានអារម្មណ៍ជាអនាគត ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ ហេតុធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ជាបច្ច័យនៃហេតុធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ១៣៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៤០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១៤១ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ១៤២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈយ៉ាងណា ( អតីតារម្មណត្តិកហេតុទុកៈ )
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ១៤៣ ] នហេតុធម៌ មានអារម្មណ៍ជាអតីត អាស្រ័យនូវនហេតុធម៌ មានអារម្មណ៍ជាអតីត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ មានអារម្មណ៍ជាអនាគត អាស្រ័យនូវនហេតុធម៌ មានអារម្មណ៍ជាអនាគត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន អាស្រ័យនូវនហេតុធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ទើបកើតឡើង ព្រោះហេ-

តុប្បច្ច័យ ។

[ ១៨៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៨៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ១ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ១៨៦ ] នហេតុធម៌ មានអារម្មណ៍ជាអតីត ជាបច្ច័យនៃនហេតុធម៌ មានអារម្មណ៍ជាអតីត ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ នហេតុធម៌ មានអារម្មណ៍ជាអនាគត ជាបច្ច័យនៃនហេតុធម៌ មានអារម្មណ៍ជាអនាគត ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ នហេតុធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ជាបច្ច័យនៃនហេតុធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ១៨៧ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ១៨៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ១៤៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ព្រោះអារម្មណប្បច្ច័យ ។

[ ១៥០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈយ៉ាងណា ( អតីតារម្មណត្តិកហេតុទុកៈ ) បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ អតីតារម្មណត្តិកហេតុទុកៈ ។**

# អជ្ឈត្តត្តិកហេតុទុកៈ

[ ១៥១ ] ហេតុធម៌ខាងក្នុង អាស្រ័យនូវហេតុធម៌ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុធម៌ខាងក្រៅ អាស្រ័យនូវហេតុធម៌ ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៥២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៥៣ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ១៥៤ ] ហេតុធម៌ខាងក្នុង ជាបច្ច័យនៃហេតុធម៌ខាងក្នុង ដោយហេ-

តុប្បច្ច័យ ។ ហេតុធម៌ខាងក្រៅ ជាបច្ច័យនៃហេតុធម៌ខាងក្រៅ ដោយហេ-តុប្បច្ច័យ ។

[ ១៥៥ ] ហេតុធម៌ខាងក្នុង ជាបច្ច័យនៃហេតុធម៌ខាងក្នុង ដោយអា-រម្មណប្បច្ច័យ ហេតុធម៌ខាងក្នុង ជាបច្ច័យនៃហេតុធម៌ខាងក្រៅ ដោយអា-រម្មណប្បច្ច័យ ។ ហេតុធម៌ខាងក្រៅ ជាបច្ច័យនៃហេតុធម៌ខាងក្រៅ ដោយ អារម្មណប្បច្ច័យ ហេតុធម៌ខាងក្រៅ ជាបច្ច័យនៃហេតុធម៌ខាងក្នុង ដោយ អារម្មណប្បច្ច័យ ។

[ ១៥៦ ] ហេតុធម៌ខាងក្នុង ជាបច្ច័យនៃហេតុធម៌ខាងក្នុង ដោយអធិ-បតិប្បច្ច័យ ។ ហេតុធម៌ខាងក្រៅ ជាបច្ច័យនៃហេតុធម៌ ខាងក្រៅ ដោយ អធិបតិប្បច្ច័យ ។

[ ១៥៧ ] ហេតុធម៌ខាងក្នុង ជាបច្ច័យនៃហេតុធម៌ខាងក្នុង ដោយ អនន្តរប្បច្ច័យ ។ ហេតុធម៌ខាងក្រៅ ជាបច្ច័យនៃហេតុធម៌ខាងក្រៅ ដោយ អនន្តរប្បច្ច័យ ។

[ ១៥៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មាន វារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ២ ក្នុង អញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ២ ក្នុង ឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៥៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មាន

វារៈ ៤ ។

[ ១៦០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។

[ ១៦១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈយ៉ាងណា ( អជ្ឈត្តិកហេតុទុកៈ )

បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ១៦២ ] នហេតុធម៌ខាងក្នុង អាស្រ័យនូវនហេតុធម៌ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ខាងក្រៅ អាស្រ័យនូវនហេតុ-ធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៦៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៦៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ១៦៥ ] នហេតុធម៌ខាងក្នុង ជាបច្ច័យនៃនហេតុធម៌ ខាងក្នុង ដោយអារម្មណប្បច្ច័យ នហេតុធម៌ខាងក្នុង ជាបច្ច័យនៃហេតុធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ ។ នហេតុធម៌ខាងក្រៅ ជាបច្ច័យនៃនហេតុធម៌ខាងក្រៅ ដោយអារម្មណប្បច្ច័យ នហេតុធម៌ខាងក្រៅ ជាបច្ច័យនៃនហេតុធម៌ ខាងក្នុង ដោយអារម្មណប្បច្ច័យ ។

[ ១៦៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មាន

វារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៦៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ។

[ ១៦៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ព្រោះអារម្មណប្បច្ច័យ ។

[ ១៦៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈយ៉ាងណា ( អជ្ឈត្តត្តិកហេតុទុកៈ )
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ អជ្ឈត្តត្តិកហេតុទុកៈ ។**

## អជ្ឈត្តារម្មណត្តិកហេតុទុកៈ

[ ១៧០ ] ហេតុធម៌ មានអារម្មណ៍ខាងក្នុង អាស្រ័យនូវហេតុធម៌ មានអារម្មណ៍ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុធម៌ មានអារម្មណ៍ខាងក្រៅ អាស្រ័យនូវហេតុធម៌ មានអារម្មណ៍ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៧១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៧២ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មាន

វារៈ ២ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងនវិបាកប្បច្ច័យ មានវារៈ ២ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ១៧៣ ] ហេតុធម៌មានអារម្មណ៍ខាងក្នុង ជាបច្ច័យនៃហេតុធម៌ មានអារម្មណ៍ខាងក្នុង ដោយហេតុប្បច្ច័យ ។ ហេតុធម៌ មានអារម្មណ៍ខាងក្រៅ ជាបច្ច័យនៃហេតុធម៌ មានអារម្មណ៍ខាងក្រៅ ដោយហេតុប្បច្ច័យ ។

[ ១៧៤ ] ហេតុធម៌ មានអារម្មណ៍ខាងក្នុង ជាបច្ច័យនៃហេតុធម៌ មានអារម្មណ៍ខាងក្នុង ដោយអារម្មណប្បច្ច័យ ហេតុធម៌ មានអារម្មណ៍ខាងក្នុង ជាបច្ច័យនៃហេតុធម៌មានអារម្មណ៍ខាងក្រៅ ដោយអារម្មណប្បច្ច័យ ។ ហេតុធម៌ មានអារម្មណ៍ខាងក្រៅ ជាបច្ច័យនៃហេតុធម៌ មានអារម្មណ៍ខាងក្រៅ ដោយអារម្មណប្បច្ច័យ ហេតុធម៌មានអារម្មណ៍ខាងក្រៅ ជាបច្ច័យនៃហេតុធម៌ មានអារម្មណ៍ខាងក្នុង ដោយអារម្មណប្បច្ច័យ ។

[ ១៧៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៧៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ។

[ ១៧៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះហេតុប្បច្ច័យ ។
[ ១៧៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ។
បញ្ហាវារៈ ក្នុងកុសលត្តិកៈយ៉ាងណា ( អជ្ឈត្តារម្មណត្តិកហេតុទុកៈ ) បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ១៧៩ ] នហេតុធម៌ មានអារម្មណ៍ខាងក្នុង អាស្រ័យនូវនហេតុធម៌ មានអារម្មណ៍ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នហេតុធម៌ មានអារម្មណ៍ខាងក្រៅ អាស្រ័យនូវនហេតុធម៌ មានអារម្មណ៍ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៨០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ១៨១ ] នហេតុធម៌ មានអារម្មណ៍ខាងក្នុង ជាបច្ច័យនៃនហេតុធម៌ មានអារម្មណ៍ខាងក្នុង ដោយអារម្មណប្បច្ច័យ ។

[ ១៨២ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ១៨៣ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៤ ។

[ ១៨៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៤ ព្រោះអារម្មណប្បច្ច័យ ។

[ ១៨៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ។ ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈយ៉ាងណា ( អជ្ឈត្តារម្មណត្តិកហេតុទុកៈ ) បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ អជ្ឈត្តារម្មណត្តិកហេតុទុកៈ ។**

## សនិទស្សនត្តិកហេតុទុកៈ

[ ១៨៦ ] ហេតុធម៌ មិនប្រកបដោយការឃើញនិងមិនប្រកបដោយការប៉ះពាល់ អាស្រ័យនូវហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ១៨៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ១៨៨ ] ហេតុធម៌ មិនប្រកបដោយការឃើញនិងមិនប្រកបដោយការប៉ះពាល់ ជាបច្ច័យនៃហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ ដោយហេតុប្បច្ច័យ ។

[ ១៨៩ ] ហេតុធម៌ មិនប្រកបដោយការឃើញនិងមិនប្រកបដោយការប៉ះពាល់ ជាបច្ច័យនៃហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ ដោយអារម្មណប្បច្ច័យ ។

[ ១៩០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។
ក្នុងបច្ច័យទាំងអស់ មានវារៈ ១ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈយ៉ាងណា ( សនិទស្សនហេតុទុកៈ )
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

[ ១៩១ ] នហេតុធម៌ មិនប្រកបដោយការឃើញតែប្រកបដោយការប៉ះពាល់ អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយ

ការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៧ ។ នហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញនិងមិនប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ តែ

ប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញនិងមិនប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញនិងមិនប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៧ ។ នហេតុធម៌ ប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ផង នហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ផង នហេតុធម៌ មិនប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ផង ទើប

កើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ មិនប្រកបដោយការឃើញ និង មិនប្រកបដោយការប៉ះពាល់ អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការ ឃើញ តែប្រកបដោយការប៉ះពាល់ផង នហេតុធម៌ មិនប្រកបដោយការ ឃើញនិងមិនប្រកបដោយការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវ នហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ផង ន-ហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ និង មិនប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការ ឃើញតែប្រកបដោយការប៉ះពាល់ផង នហេតុធម៌មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ប្រកបដោយការឃើញនិងប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវន-ហេតុធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ផង ន-ហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នហេតុធម៌ ប្រកបដោយការឃើញ និង ប្រកបដោយការប៉ះពាល់ក្តី នហេតុធម៌មិនប្រកបដោយការឃើញ តែប្រកប

ដោយការប៉ះពាល់ក្តី នហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវនហេតុធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ផង នហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៧ ។

[ ១៩២ ] នហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ អាស្រ័យនូវនហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ១៩៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២១ ។

[ ១៩៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២១ ។

[ ១៩៥ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២១ ព្រោះហេតុប្បច្ច័យ ។

[ ១៩៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ១៩៧ ] នហេតុធម៌ ប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ ជាបច្ច័យនៃហេតុធម៌ មិនប្រកបដោយការឃើញ និងមិនប្រកបដោយការប៉ះពាល់ ដោយអារម្មណប្បច្ច័យ ។

[ ១៩៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ២១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៥ ។

[ ១៩៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ២១ ។

[ ២០០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ព្រោះអធិបតិប្បច្ច័យ ។

[ ២០១ ] ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា ( សនិទស្សនត្តិក-ហេតុទុកៈ ) បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ សនិទស្សនត្តិកហេតុទុកៈ ។**

# កុសលត្តិកសហេតុកទុកៈ

[ ២០២ ] សហេតុកធម៌ ( ធម៌ប្រព្រឹត្តទៅមួយអន្លើដោយហេតុ ) ជាកុសល អាស្រ័យនូវសហេតុកធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ សហេតុកធម៌ ជាអកុសល អាស្រ័យនូវសហេតុកធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ សហេតុកធម៌ជាអព្យាកតៈ អាស្រ័យនូវសហេតុកធម៌ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២០៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២០៤ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

[ ២០៥ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ២០៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ២០៧ ] សហេតុកធម៌ ជាកុសល ជាបច្ច័យនៃសហេតុកធម៌ ជាកុសល ដោយហេតុប្បច្ច័យ ។ សហេតុកធម៌ ជាអកុសល ជាបច្ច័យនៃសហេតុកធម៌ជាអកុសល ដោយហេតុប្បច្ច័យ ។ សហេតុកធម៌ ជាអព្យាកតៈ ជាបច្ច័យនៃសហេតុកធម៌ ជាអព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ២០៨ ] សហេតុកធម៌ជាកុសល ជាបច្ច័យនៃសហេតុកធម៌ជាកុសល ដោយអារម្មណប្បច្ច័យ សហេតុកធម៌ ជាកុសល ជាបច្ច័យនៃសហេតុកធម៌ ជាអកុសល ដោយអារម្មណប្បច្ច័យ សហេតុកធម៌ ជាកុសល ជាបច្ច័យនៃសហេតុកធម៌ ជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ ។ សហេតុកធម៌ ជាអកុសល ជាបច្ច័យនៃសហេតុកធម៌ ជាអកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ សហេតុកធម៌ជាអព្យាកត ជាបច្ច័យនៃសហេតុកធម៌ ជា

អព្យាកត ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ២០៩ ] សហេតុកធម៌ ជាកុសល ជាបច្ច័យនៃសហេតុកធម៌ ជាកុសល ដោយអធិបតិប្បច្ច័យ ។

[ ២១០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២១១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ។

[ ២១២ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ២១៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ២១៤ ] អហេតុកធម៌ ជាអព្យាកតៈ អាស្រ័យនូវអហេតុកធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អហេតុកធម៌ ជាអព្យាកតៈ អាស្រ័យនូវអហេតុកធម៌ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អហេតុកធម៌ ជាអព្យាកតៈ អាស្រ័យនូវអហេតុកធម៌ ជាអកុសលផង នូវអហេតុកធម៌ ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២១៥ ] អហេតុកធម៌ ជាអព្យាកតៈ អាស្រ័យនូវអហេតុកធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ២១៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២១៧ ] អហេតុកធម៌ ជាអព្យាកតៈ អាស្រ័យនូវអហេតុកធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ២១៨ ] អហេតុកធម៌ ជាអព្យាកតៈ អាស្រ័យនូវអហេតុកធម៌ ជាអកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ អហេតុកធម៌ ជាអព្យាកតៈ អាស្រ័យនូវអហេតុកធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ អហេតុកធម៌ ជាអព្យាកតៈ អាស្រ័យនូវអហេតុកធម៌ ជាអកុសលផង នូវអហេតុកធម៌ ជាអព្យាកតៈផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។

[ ២១៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២២០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ២២១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ២២២ ] អហេតុកធម៌ ជាអកុសល ជាបច្ច័យនៃអហេតុកធម៌ ជា

អព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ២២៣ ] អហេតុកធម៌ ជាអកុសល ជាបច្ច័យនៃអហេតុកធម៌ ជាអកុសល ដោយអារម្មណប្បច្ច័យ អហេតុកធម៌ ជាអកុសល ជាបច្ច័យនៃអហេតុកធម៌ ជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ ។ អហេតុកធម៌ ជាអព្យាកតៈ ជាបច្ច័យនៃអហេតុកធម៌ជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ ។ អហេតុកធម៌ ជាអព្យាកតៈ ជាបច្ច័យនៃអហេតុកធម៌ ជាអកុសល ដោយអារម្មណប្បច្ច័យ ។

[ ២២៤ ] អហេតុកធម៌ ជាអកុសល ជាបច្ច័យនៃអហេតុកធម៌ ជាអកុសល ដោយអនន្តរប្បច្ច័យ អហេតុកធម៌ ជាអកុសល ជាបច្ច័យនៃអហេតុកធម៌ជាអព្យាកតៈ ដោយអនន្តរប្បច្ច័យ ។ អហេតុកធម៌ជាអព្យាកតៈ ជាបច្ច័យនៃអហេតុកធម៌ ជាអព្យាកតៈ ដោយអនន្តរប្បច្ច័យ អហេតុកធម៌ ជាអព្យាកតៈ ជាបច្ច័យនៃអហេតុកធម៌ ជាអកុសល ដោយអនន្តរប្បច្ច័យ ។

[ ២២៥ ] អហេតុកធម៌ ជាអកុសល ជាបច្ច័យនៃអហេតុកធម៌ ជាអកុសល ដោយឧបនិស្សយប្បច្ច័យ ។

[ ២២៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ។

[ ២២៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអារម្មណប្បច្ច័យ មាន

វារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៥ ។

[ ២២៨ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។

[ ២២៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា ( កុសលត្តិកសហេតុក-ទុកៈ ) បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ កុសលត្តិកសហេតុកទុកៈ ។**

## កុសលត្តិកហេតុសម្បយុត្តទុកៈ

[ ២៣០ ] ហេតុសម្បយុត្តធម៌ ជាកុសល អាស្រ័យនូវហេតុសម្បយុត្តធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុសម្បយុត្តធម៌ ជាអកុសល អាស្រ័យនូវហេតុសម្បយុត្តធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុសម្បយុត្តធម៌ជាអព្យាកតៈ អាស្រ័យនូវហេតុសម្បយុត្តធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២៣១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៣២ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ២៣៣ ] ហេតុសម្បយុត្តធម៌ជាកុសល ជាបច្ច័យនៃហេតុសម្បយុត្តធម៌ ជាកុសល ដោយហេតុប្បច្ច័យ ។ ហេតុសម្បយុត្តធម៌ ជាអកុសល ជាបច្ច័យនៃហេតុសម្បយុត្តធម៌ ជាអកុសល ដោយហេតុប្បច្ច័យ ។ ហេតុសម្បយុត្តធម៌ ជាអព្យាកតៈ ជាបច្ច័យនៃហេតុសម្បយុត្តធម៌ ជាអព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ២៣៤ ] ហេតុសម្បយុត្តធម៌ ជាកុសល ជាបច្ច័យនៃហេតុសម្បយុត្តធម៌ ជាកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ ហេតុសម្បយុត្តធម៌ ជាអកុសល ជាបច្ច័យនៃហេតុសម្បយុត្តធម៌ ជាអកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ ហេតុសម្បយុត្តធម៌ ជាអព្យាកតៈ ជាបច្ច័យនៃហេតុសម្បយុត្តធម៌ ជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ២៣៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៣៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ២៣៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ២៣៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា ( កុសលត្តិកហេតុ-សម្បយុត្តទុកៈ ) បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ២៣៩ ] ហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ អាស្រ័យនូវហេតុវិប្បយុត្តធម៌ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ អាស្រ័យនូវហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ហេតុវិប្បយុត្តធម៌ជាអព្យាកតៈ អាស្រ័យនូវហេតុវិប្បយុត្តធម៌ ជាអកុសលផង នូវហេតុវិប្បយុត្តធម៌ ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២៤០ ] ហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ អាស្រ័យនូវហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ២៤១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៤២ ] ហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ អាស្រ័យនូវហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ២៤៣ ] ហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ អាស្រ័យនូវហេតុវិប្បយុត្តធម៌ ជាអកុសល ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ ហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ អាស្រ័យនូវហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។ ហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ អាស្រ័យនូវហេតុវិប្បយុត្តធម៌ ជាអកុសលផង នូវហេតុវិប្បយុត្តធម៌ ជា

អព្យាកតៈផង ទើបកើតឡើង ព្រោះនអារម្មណប្បច្ច័យ ។

[ ២៨៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ២៨៥ ] ហេតុវិប្បយុត្តធម៌ ជាអកុសល ជាបច្ច័យ នៃហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ២៨៦ ] ហេតុវិប្បយុត្តធម៌ជាអកុសល ជាបច្ច័យនៃហេតុវិប្បយុត្តធម៌ ជាអកុសល ដោយអារម្មណប្បច្ច័យ ហេតុវិប្បយុត្តធម៌ ជាអកុសល ជាបច្ច័យនៃហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ ។ ហេតុវិប្បយុត្តធម៌ជាអព្យាកតៈ ជាបច្ច័យនៃហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ ហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ ជាបច្ច័យនៃហេតុវិប្បយុត្តធម៌ ជាអកុសល ដោយអារម្មណប្បច្ច័យ ។

[ ២៨៧ ] ហេតុវិប្បយុត្តធម៌ ជាអកុសល ជាបច្ច័យនៃហេតុវិប្បយុត្តធម៌ ជាអកុសល ដោយអនន្តរប្បច្ច័យ ហេតុវិប្បយុត្តធម៌ ជាអកុសល ជាបច្ច័យនៃហេតុវិប្បយុត្តធម៌ ជាអព្យាកតៈ ដោយអនន្តរប្បច្ច័យ ។ ហេតុវិប្បយុត្តធម៌ជាអព្យាកតៈ ជាបច្ច័យនៃហេតុវិប្បយុត្តធម៌ជាអព្យាកតៈ ដោយអនន្តរប្បច្ច័យ ហេតុវិប្បយុត្តធម៌ជាអព្យាកតៈ ជាបច្ច័យនៃហេតុវិប្បយុត្តធម៌ ជាអកុសល ដោយអនន្តរប្បច្ច័យ ។

[ ២៤៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤ ។

[ ២៤៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ។

[ ២៥០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ ។

[ ២៥១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា ( កុសលត្តិកហេតុសម្បយុត្តទុកៈនេះ ) បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ កុសលត្តិកហេតុសម្បយុត្តទុកៈ ។**

## កុសលត្តិកហេតុសហេតុកទុកៈ

[ ២៥២ ] កុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវកុសលធម៌ ជាហេតុទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេ-

តុប្បច្ច័យ ។ អព្យាកតធម៌ ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២៥៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៥៤ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ២៥៥ ] កុសលធម៌ ជាហេតុទាំងប្រកបដោយហេតុ ជាបច្ច័យនៃកុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ដោយហេតុប្បច្ច័យ ។ អកុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអកុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាហេតុទាំងប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ ជាហេតុទាំងប្រកបដោយហេតុ ដោយហេតុប្បច្ច័យ ។

[ ២៥៦ ] កុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃកុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ កុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអកុសលធម៌ ជា

ហេតុ ទាំងប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ កុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ។ អកុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ជាបច្ច័យនៃអកុសលធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាហេតុទាំងប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ ជាហេតុ ទាំងប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ២៥៧ ] កុសលធម៌ ជាហេតុទាំងប្រកបដោយហេតុ ជាបច្ច័យនៃកុសលធម៌ ជាហេតុទាំងប្រកបដោយហេតុ ដោយអធិបតិប្បច្ច័យ មានវារៈ ៣ ។

[ ២៥៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៥៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ២៦០ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ២៦១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណាបណ្ឌិត គប្បីឲ្យពិស្តារ

យ៉ាងនោះផងចុះ ។

[ ២៦២ ] កុសលធម៌ប្រកបដោយហេតុទាំងមិនមែនជាហេតុ អាស្រ័យនូវកុសលធម៌ ប្រកបដោយហេតុទាំងមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ប្រកបដោយហេតុ ទាំងមិនមែនជាហេតុ អាស្រ័យនូវអកុសលធម៌ ប្រកបដោយហេតុ ទាំងមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រកបដោយហេតុ ទាំងមិនមែនជាហេតុ អាស្រ័យនូវអព្យាកតធម៌ ប្រកបដោយហេតុ ទាំងមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២៦៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៦៤ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ២៦៥ ] កុសលធម៌ ប្រកបដោយហេតុ ទាំងមិនមែនជាហេតុ ជាបច្ច័យនៃកុសលធម៌ ប្រកបដោយហេតុ ទាំងមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រកបដោយហេតុ ទាំងមិនមែនជាហេតុ ជាបច្ច័យនៃអកុសលធម៌ ប្រកបដោយហេតុ ទាំងមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រកបដោយហេតុ ទាំងមិនមែនជាហេតុ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយហេតុ ទាំងមិន

មែនជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ២៦៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៦៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ២៦៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ព្រោះអារម្មណប្បច្ច័យ ។

[ ២៦៩ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណាបណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ កុសលត្តិកហេតុសហេតុកទុកៈ ។**

# កុសលត្តិកហេតុហេតុសម្បយុត្តទុកៈ

[ ២៧០ ] កុសលធម៌ ជាហេតុទាំងសម្បយុត្តដោយហេតុ អាស្រ័យនូវកុសលធម៌ ជាហេតុ ទាំងសម្បយុត្តដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ជាហេតុទាំងសម្បយុត្តដោយហេតុ អាស្រ័យនូវអកុសលធម៌ ជាហេតុទាំងសម្បយុត្តដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាហេតុទាំងសម្បយុត្តដោយហេតុ អាស្រ័យ

នូវអព្យាកតធម៌ ជាហេតុ ទាំងសម្បយុត្តដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២៧១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៧២ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ។

[ ២៧៣ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ២៧៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ២៧៥ ] កុសលធម៌ ជាហេតុទាំងសម្បយុត្តដោយហេតុ ជាបច្ច័យនៃកុសលធម៌ ជាហេតុ ទាំងសម្បយុត្តដោយហេតុ ដោយហេតុប្បច្ច័យ ។ អកុសលធម៌ ជាហេតុទាំងសម្បយុត្តដោយហេតុ ជាបច្ច័យនៃអកុសលធម៌ ជាហេតុទាំងសម្បយុត្តដោយហេតុ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាហេតុ ទាំងសម្បយុត្តដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ ជាហេតុ ទាំងសម្បយុត្តដោយហេតុ ដោយហេតុប្បច្ច័យ ។

[ ២៧៦ ] កុសលធម៌ ជាហេតុទាំងសម្បយុត្តដោយហេតុ ជាបច្ច័យនៃកុសលធម៌ ជាហេតុទាំងសម្បយុត្តដោយហេតុ ដោយអារម្មណប្បច្ច័យ ។

[ ២៧៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៧៨ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ២៧៩ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ ។

[ ២៨០ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណាបណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

[ ២៨១ ] កុសលធម៌ សម្បយុត្តដោយហេតុ ទាំងមិនមែនជាហេតុ អាស្រ័យនូវកុសលធម៌ សម្បយុត្តដោយហេតុ ទាំងមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ សម្បយុត្តដោយហេតុ ទាំងមិនមែនជាហេតុ អាស្រ័យនូវអកុសលធម៌ សម្បយុត្តដោយហេតុ ទាំងមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ សម្បយុត្តដោយហេតុ ទាំងមិនមែនជាហេតុ អាស្រ័យនូវអព្យាកតធម៌ សម្បយុត្តដោយហេតុទាំងមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២៨២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៨៣ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ២៨៤ ] កុសលធម៌ សម្បយុត្តដោយហេតុ ទាំងមិនមែនជាហេតុ ជាបច្ច័យនៃកុសលធម៌ សម្បយុត្តដោយហេតុ ទាំងមិនមែនជាហេតុ ដោយ

អារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ សម្បយុត្តដោយហេតុទាំង មិនមែនជាហេតុ ជាបច្ច័យនៃអកុសលធម៌ សម្បយុត្តដោយហេតុ ទាំងមិន មែនជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ សម្ប-យុត្តដោយហេតុ ទាំងមិនមែនជាហេតុ ជាបច្ច័យនៃអព្យាកតធម៌ សម្បយុត្ត ដោយហេតុ ទាំងមិនមែនជាហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ២៨៥ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មាន វារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៨៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មាន វារៈ ៩ ។

[ ២៨៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ព្រោះអារម្មណប្បច្ច័យ ។

[ ២៨៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ កុសលត្តិកហេតុហេតុសម្បយុត្តទុកៈ ។**

## កុសលត្តិកនហេតុសហេតុកទុកៈ

[ ២៨៩ ] កុសលធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យ

នូវកុសលធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវអកុសលធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌ មិនមែនជាហេតុតែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២៩០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៩១ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ២៩២ ] កុសលធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃកុសលធម៌ មិនមែនជាហេតុតែប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃអកុសលធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌មិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ២៩៣ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ

៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ២៩៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

[ ២៩៥ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ព្រោះអារម្មណប្បច្ច័យ ។

[ ២៩៦ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ព្រោះនហេតុប្បច្ច័យ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

[ ២៩៧ ] អព្យាកតធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ អាស្រ័យនូវអព្យាកតធម៌ មិនមែនជាហេតុ តែប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ២៩៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ២៩៩ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៣០០ ] អព្យាកតធម៌ មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យនៃអព្យាកតធម៌ មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ។

[ ៣០១ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មាន

វារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ កុសលត្តិកនហេតុសហេតុកទុកៈ ។**

# កុសលត្តិកសប្បច្ចយទុកៈ

[ ៣០២ ] កុសលធម៌ ប្រកបដោយបច្ច័យ អាស្រ័យនូវកុសលធម៌ ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ប្រកបដោយបច្ច័យ អាស្រ័យនូវកុសលធម៌ ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ កុសលធម៌ ប្រកបដោយបច្ច័យក្តី អព្យាកតធម៌ ប្រកបដោយបច្ច័យក្តី អាស្រ័យនូវកុសលធម៌ ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ប្រកបដោយបច្ច័យ អាស្រ័យនូវអកុសលធម៌ ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រកបដោយបច្ច័យ អាស្រ័យនូវអព្យាកតធម៌ ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រកបដោយបច្ច័យ អាស្រ័យនូវកុសលធម៌ ប្រកបដោយបច្ច័យផង នូវអព្យាកតធម៌ ប្រកបដោយបច្ច័យផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រកបដោយបច្ច័យ អាស្រ័យនូវអកុសលធម៌ ប្រកបដោយ

បច្ច័យផង នូវអព្យាកតធម៌ ប្រកបដោយបច្ច័យផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣០៣ ] កុសលធម៌ ប្រកបដោយបច្ច័យ អាស្រ័យនូវកុសលធម៌ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អកុសលធម៌ប្រកបដោយបច្ច័យ អាស្រ័យនូវអកុសលធម៌ ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អព្យាកតធម៌ប្រកបដោយបច្ច័យ អាស្រ័យនូវអព្យាកតធម៌ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៣០៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៣០៥ ] អកុសលធម៌ ប្រកបដោយបច្ច័យ អាស្រ័យនូវអកុសលធម៌ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ អព្យាកតធម៌ប្រកបដោយបច្ច័យ អាស្រ័យនូវអព្យាកតធម៌ ប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៣០៦ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។

[ ៣០៧ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ព្រោះហេតុប្បច្ច័យ ។

[ ៣០៨ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៣០៩ ] កុសលធម៌ ប្រកបដោយបច្ច័យ ជាបច្ច័យនៃកុសលធម៌ ប្រកបដោយបច្ច័យ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រកបដោយបច្ច័យ ជាបច្ច័យនៃអកុសលធម៌ ប្រកបដោយបច្ច័យ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រកបដោយបច្ច័យ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយបច្ច័យ ដោយហេតុប្បច្ច័យ ។

[ ៣១០ ] កុសលធម៌ ប្រកបដោយបច្ច័យ ជាបច្ច័យនៃកុសលធម៌ ប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រកបដោយបច្ច័យ ជាបច្ច័យនៃអកុសលធម៌ ប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រកបដោយបច្ច័យ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៣១១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

[ ៣១២ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១៥ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១៥ ។

[ ៣១៣ ] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ព្រោះហេតុប្បច្ច័យ ។

[ ៣១៤ ] ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ កុសលត្តិកសប្បច្ចយទុកៈ ។**

# កុសលត្តិកសង្ខតទុកៈ

[ ៣១៥ ] កុសលធម៌ ជាសង្ខតៈ អាស្រ័យនូវកុសលធម៌ ជាសង្ខតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ប្រហែលគ្នានឹងសប្បច្ចយទុកៈដែរ ។

**ចប់ កុសលត្តិកសង្ខតទុកៈ ។**

# កុសលត្តិកសនិទស្សនទុកៈ

[ ៣១៦ ] កុសលធម៌ ជាអនិទស្សនៈ អាស្រ័យនូវកុសលធម៌ ជាអនិទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាអនិទស្សនៈ អាស្រ័យនូវអកុសលធម៌ជាអនិទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាអនិទស្សនៈ អាស្រ័យនូវអព្យាកតធម៌ ជាអនិទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាអនិទស្សនៈ អាស្រ័យនូវកុសលធម៌ ជាអនិទស្សនៈផង អព្យាកតធម៌ ជាអនិទស្សនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាអនិទស្សនៈ អាស្រ័យនូវអកុសលធម៌ ជាអនិទស្សនៈផង

អព្យាកតធម៌ ជាអនិទស្សនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣១៧ ] កុសលធម៌ ជាអនិទស្សនៈ អាស្រ័យនូវកុសលធម៌ ជាអនិទស្សនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អកុសលធម៌ ជាអនិទស្សនៈ អាស្រ័យនូវអកុសលធម៌ជាអនិទស្សនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អព្យាកតធម៌ ជាអនិទស្សនៈ អាស្រ័យនូវអព្យាកតធម៌ ជាអនិទស្សនៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៣១៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៣១៩ ] អកុសលធម៌ ជាអនិទស្សនៈ អាស្រ័យនូវអកុសលធម៌ ជាអនិទស្សនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាអនិទស្សនៈ អាស្រ័យនូវអព្យាកតធម៌ ជាអនិទស្សនៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៣២០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៣២១ ] កុសលធម៌ ជាអនិទស្សនៈ ជាបច្ច័យនៃកុសលធម៌ ជាអនិទស្សនៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាអនិទស្សនៈ ជាបច្ច័យនៃអកុសលធម៌ ជាអនិទស្សនៈ ដោយហេតុប្បច្ច័យ មានវារៈ

៣ ។ អព្យាកតធម៌ ជាអនិទស្សនៈ ជាបច្ច័យនៃអព្យាកតធម៌ជាអនិទស្សនៈ ដោយហេតុប្បច្ច័យ ។

[ ៣២២ ] កុសលធម៌ ជាអនិទស្សនៈ ជាបច្ច័យនៃកុសលធម៌ ជាអនិទស្សនៈ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាអនិទស្សនៈ ជាបច្ច័យនៃអកុសលធម៌ ជាអនិទស្សនៈ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាអនិទស្សនៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអនិទស្សនៈ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៣២៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៧ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិត
គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ កុសលត្តិកសនិទស្សនទុកៈ ។**

# កុសលត្តិកសប្បដិឃទុកៈ

[ ៣២៤ ] អព្យាកតធម៌ ជាសប្បដិឃៈ ( ប្រកបដោយការប៉ះពាល់ ) អាស្រ័យនូវអព្យាកតធម៌ជាសប្បដិឃៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣២៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ

១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៣២៦ ] កុសលធម៌ ជាអប្បដិឃៈ ( មិនមានការប៉ះពាល់ ) អាស្រ័យនូវកុសលធម៌ ជាអប្បដិឃៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាអប្បដិឃៈ អាស្រ័យនូវអកុសលធម៌ ជាអប្បដិឃៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាអប្បដិឃៈ អាស្រ័យនូវអព្យាកតធម៌ជាអប្បដិឃៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាអប្បដិឃៈ អាស្រ័យនូវកុសលធម៌ ជាអប្បដិឃៈផង នូវអព្យាកតធម៌ ជាអប្បដិឃៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាអប្បដិឃៈ អាស្រ័យនូវអកុសលធម៌ ជាអប្បដិឃៈផង នូវអព្យាកតធម៌ ជាអប្បដិឃៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣២៧ ] កុសលធម៌ ជាអប្បដិឃៈ អាស្រ័យនូវកុសលធម៌ ជាអប្បដិឃៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អកុសលធម៌ ជាអប្បដិឃៈ អាស្រ័យនូវអកុសលធម៌ ជាអប្បដិឃៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អព្យាកតធម៌ ជាអប្បដិឃៈ អាស្រ័យនូវអព្យាកតធម៌ ជាអប្បដិឃៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៣២៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៣២៩ ] អកុសលធម៌ ជាអប្បដិឃៈ អាស្រ័យនូវអកុសលធម៌ ជាអប្បដិឃៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាអប្បដិឃៈ អាស្រ័យនូវអព្យាកតធម៌ ជាអប្បដិឃៈ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៣៣០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៣៣១ ] កុសលធម៌ ជាអប្បដិឃៈ ជាបច្ច័យនៃកុសលធម៌ ជាអប្បដិឃៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាអប្បដិឃៈ ជាបច្ច័យនៃអកុសលធម៌ ជាអប្បដិឃៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាអប្បដិឃៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអប្បដិឃៈ ដោយហេតុប្បច្ច័យ ។

[ ៣៣២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិត
គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ កុសលត្តិកសប្បដិឃទុកៈ ។**

# កុសលត្តិករូបីទុកៈ

[ ៣៣៣ ] រូបធម៌ជាអព្យាកតៈ អាស្រ័យនូវរូបធម៌ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣៣៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៣៣៥ ] អរូបធម៌ជាកុសល អាស្រ័យនូវអរូបធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អរូបធម៌ជាអកុសល អាស្រ័យនូវអរូបធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អរូបធម៌ ជាអព្យាកតៈ អាស្រ័យនូវអរូបធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣៣៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៣៣៧ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៣៣៨ ] អរូបធម៌ជាកុសល ជាបច្ច័យនៃអរូបធម៌ ជាកុសល ដោយហេតុប្បច្ច័យ ។ អរូបធម៌ ជាអកុសល ជាបច្ច័យនៃអរូបធម៌ ជាអកុសល ដោយហេតុប្បច្ច័យ ។ អរូបធម៌ ជាអព្យាកតៈ ជាបច្ច័យនៃអរូបធម៌ ជា

អព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ៣៣៩ ] អរូបធម៌ជាកុសល ជាបច្ច័យនៃអរូបធម៌ ជាកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អរូបធម៌ជាអកុសល ជាបច្ច័យនៃអរូបធម៌ជាអកុសល ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អរូបធម៌ជាអព្យាកតៈ ជាបច្ច័យនៃអរូបធម៌ ជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៣៤០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

**ចប់ កុសលត្តិករូបីទុកៈ ។**

## កុសលត្តិកលោកិយទុកៈ

[ ៣៤១ ] កុសលធម៌ជាលោកិយ អាស្រ័យនូវកុសលធម៌ជាលោកិយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ ជាលោកិយ អាស្រ័យនូវកុសលធម៌ ជាលោកិយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ កុសលធម៌ជាលោកិយក្តី អព្យាកតធម៌ ជាលោកិយក្តី អាស្រ័យនូវកុសលធម៌ ជាលោកិយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ជាលោកិយ អាស្រ័យនូវអកុសលធម៌ ជាលោកិយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

មានវារៈ ៣ ។ អព្យាកតធម៌ ជាលោកិយ អាស្រ័យនូវអព្យាកតធម៌ ជាលោកិយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាលោកិយ អាស្រ័យនូវកុសលធម៌ ជាលោកិយផង នូវអព្យាកតធម៌ ជាលោកិយផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាលោកិយ អាស្រ័យនូវអកុសលធម៌ ជាលោកិយផង នូវអព្យាកតធម៌ ជាលោកិយផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣៤២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៣៤៣ ] អកុសលធម៌ ជាលោកិយ អាស្រ័យនូវអកុសលធម៌ ជាលោកិយ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។ អព្យាកតធម៌ជាលោកិយ អាស្រ័យនូវអព្យាកតធម៌ជាលោកិយ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៣៤៤ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៣៤៥ ] កុសលធម៌ជាលោកិយ ជាបច្ច័យនៃកុសលធម៌ ជាលោកិយ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាលោកិយ ជាបច្ច័យនៃអកុសលធម៌ ជាលោកិយ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាលោកិយ ជាបច្ច័យនៃអព្យាកតធម៌ ជាលោកិយ ដោយហេ-

តុប្បច្ច័យ ។

[ ៣៤៦ ] កុសលធម៌ជាលោកិយ ជាបច្ច័យនៃកុសលធម៌ ជាលោកិយ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាលោកិយ ជាបច្ច័យនៃអកុសលធម៌ ជាលោកិយ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាលោកិយ ជាបច្ច័យនៃអព្យាកតធម៌ ជាលោកិយ ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៣៤៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

[ ៣៤៨ ] កុសលធម៌ ជាលោកុត្តរៈ អាស្រ័យនូវកុសលធម៌ជាលោកុត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាលោកុត្តរៈ អាស្រ័យនូវអព្យាកតធម៌ជាលោកុត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣៤៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

[ ៣៥០ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៣៥១ ] កុសលធម៌ជាលោកុត្តរៈ ជាបច្ច័យនៃកុសលធម៌ ជាលោកុត្តរៈ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ជាលោកុត្តរៈ ជាបច្ច័យនៃអព្យា-

កតធម៌ ជាលោកុត្តរៈ ដោយហេតុប្បច្ច័យ ។

[ ៣៥២ ] អព្យាកតធម៌ ជាលោកុត្តរៈ ជាបច្ច័យនៃអព្យាកតធម៌ ជាលោកុត្តរៈ ដោយអារម្មណប្បច្ច័យ អព្យាកតធម៌ ជាលោកុត្តរៈ ជាបច្ច័យនៃកុសលធម៌ ជាលោកុត្តរៈ ដោយអារម្មណប្បច្ច័យ ។

[ ៣៥៣ ] កុសលធម៌ ជាលោកុត្តរៈ ជាបច្ច័យនៃកុសលធម៌ ជាលោកុត្តរៈ ដោយអធិបតិប្បច្ច័យ ។ អព្យាកតធម៌ ជាលោកុត្តរៈ ជាបច្ច័យនៃអព្យាកតធម៌ជាលោកុត្តរៈ ដោយអធិបតិប្បច្ច័យ អព្យាកតធម៌ជាលោកុត្តរៈ ជាបច្ច័យនៃកុសលធម៌ ជាលោកុត្តរៈ ដោយអធិបតិប្បច្ច័យ ។

[ ៣៥៤ ] កុសលធម៌ ជាលោកុត្តរៈ ជាបច្ច័យនៃអព្យាកតធម៌ ជាលោកុត្តរៈ ដោយអនន្តរប្បច្ច័យ ។ អព្យាកតធម៌ ជាលោកុត្តរៈ ជាបច្ច័យនៃអព្យាកតធម៌ ជាលោកុត្តរៈ ដោយអនន្តរប្បច្ច័យ ។

[ ៣៥៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ២ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

**ចប់ កុសលត្តិកលោកិយទុកៈ ។**

# កុសលត្តិកកេនចិវិញ្ញេយ្យទុកៈ

[ ៣៥៦ ] កុសលធម៌ ដែលគប្បីដឹងច្បាស់ដោយវិញ្ញាណណានីមួយ អាស្រ័យនូវកុសលធម៌ ដែលគប្បីដឹងច្បាស់ដោយវិញ្ញាណណានីមួយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ អាស្រ័យនូវកុសលធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ កុសលធម៌ ដែលគប្បីដឹងច្បាស់ដោយវិញ្ញាណណានីមួយក្តី អព្យាកតធម៌ដែលគប្បីដឹងច្បាស់ដោយវិញ្ញាណណានីមួយក្តី អាស្រ័យនូវកុសលធម៌ ដែលគប្បីដឹងច្បាស់ដោយវិញ្ញាណណានីមួយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ អាស្រ័យនូវអកុសលធម៌ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ អាស្រ័យនូវអព្យាកតធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ អាស្រ័យនូវកុសលធម៌ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយផង នូវអព្យាកតធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលគប្បីដឹងច្បាស់ដោយវិញ្ញាណណានីមួយ អាស្រ័យនូវអកុសលធម៌ ដែលគប្បីដឹងច្បាស់ដោយវិញ្ញាណណានីមួយផង នូវអព្យា-

កតធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣៥៧ ] កុសលធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ អាស្រ័យនូវកុសលធម៌ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អកុសលធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ អាស្រ័យនូវអកុសលធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អព្យា-កតធម៌ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ អាស្រ័យនូវអព្យា-កតធម៌ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៣៥៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៣៥៩ ] អកុសលធម៌ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ អាស្រ័យនូវអកុសលធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ។

[ ៣៦០ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៣៦១ ] កុសលធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ជាបច្ច័យនៃកុសលធម៌ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ជាបច្ច័យនៃអកុសលធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ជាបច្ច័យនៃអព្យាកតធម៌ ដែលគប្បីដឹងច្បាស់ ដោយវិញ្ញាណណានីមួយ ដោយហេតុប្បច្ច័យ ។

[ ៥៦៤ ] កុសលធម៌ ជាបរិយាបន្នៈ ( ធម៌ដែលរាប់បញ្ចូលក្នុងតេភូមិកវដ្ត ) អាស្រ័យនូវកុសលធម៌ ជាបរិយាបន្នៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាបរិយាបន្នៈ អាស្រ័យនូវអកុសលធម៌ ជាបរិយាបន្នៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាបរិយាបន្នៈ អាស្រ័យនូវអព្យាកតធម៌ ជាបរិយាបន្នៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ជាបរិយាបន្នៈ អាស្រ័យនូវកុសលធម៌ ជាបរិយាបន្នៈផង នូវអព្យាកតធម៌ ជាបរិយាបន្នៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាបរិយាបន្នៈ អាស្រ័យនូវអកុសលធម៌ ជាបរិយាបន្នៈផង នូវអព្យាកតធម៌ ជាបរិយាបន្នៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៦៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៥៦៦ ] កុសលធម៌ ជាបរិយាបន្នៈ ជាបច្ច័យនៃកុសលធម៌ ជា

បរិយាបន្នៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ជាបរិយាបន្នៈ ជាបច្ច័យនៃអកុសលធម៌ ជាបរិយាបន្នៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ជាបរិយាបន្នៈ ជាបច្ច័យនៃអព្យាកតធម៌ ជាបរិយាបន្នៈ ដោយហេតុប្បច្ច័យ ។

[ ៥៦៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៥៦៨ ] កុសលធម៌ ជាអបរិយាបន្នៈ ( ធម៌ដែលមិនបានរាប់បញ្ចូលក្នុងតេភូមិកវដ្ត ) អាស្រ័យនូវកុសលធម៌ ជាអបរិយាបន្នៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាអបរិយាបន្នៈ អាស្រ័យនូវអព្យាកតធម៌ ជាអបរិយាបន្នៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៦៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៥៧០ ] កុសលធម៌ ជាអបរិយាបន្នៈ ជាបច្ច័យនៃកុសលធម៌ ជាអបរិយាបន្នៈ ដោយហេតុប្បច្ច័យ អព្យាកតធម៌ ជាអបរិយាបន្នៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអបរិយាបន្នៈ ដោយហេតុប្បច្ច័យ ។

[ ៥៧១ ] អព្យាកតធម៌ ជាអបរិយាបន្នៈ ជាបច្ច័យនៃអព្យាកតធម៌ ជាអបរិយាបន្នៈ ដោយអារម្មណប្បច្ច័យ ។ អព្យាកតធម៌ ជាអបរិយាបន្នៈ ជាបច្ច័យនៃកុសលធម៌ ជាអបរិយាបន្នៈ ដោយអារម្មណប្បច្ច័យ ។

[ ៥៧២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ កុសលត្តិកបរិយាបន្នទុកៈ ។**

# កុសលត្តិកនិយ្យានិកទុកៈ

[ ៥៧៣ ] កុសលធម៌ជានិយ្យានិកៈ ( ធម៌ដែលលះបង់សង្សារវដ្តទាំងអស់ ដោយឥតមានសេសសល់ ) អាស្រ័យនូវកុសលធម៌ ជានិយ្យានិកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៧៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៥៧៥ ] កុសលធម៌ ជាអនិយ្យានិកៈ អាស្រ័យនូវកុសលធម៌ ជា

អនិយ្យានិកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុ-សលធម៌ ជាអនិយ្យានិកៈ អាស្រ័យនូវអកុសលធម៌ ជាអនិយ្យានិកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ជាអនិយ្យានិកៈ អាស្រ័យនូវអព្យាកតធម៌ជាអនិយ្យានិកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៧៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនេះចុះ ។

**ចប់ កុសលត្តិកនិយ្យានិកទុកៈ ។**

# កុសលត្តិកនិយតទុកៈ

[ ៥៧៧ ] កុសលធម៌ ជានិយតៈ ( ធម៌ទៀង ) អាស្រ័យនូវកុសល-ធម៌ ជានិយតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ជានិយតៈ អាស្រ័យនូវអកុសលធម៌ ជានិយតៈ ទើបកើតឡើង ព្រោះហេ-តុប្បច្ច័យ ។

[ ៥៧៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារ
យ៉ាងនេះផងចុះ ។

[ ៥៧៩ ] កុសលធម៌ ជាអនិយតៈ អាស្រ័យនូវកុសលធម៌ ជាអនិយតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៥៨០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី

បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនេះផងចុះ ។

**ចប់ កុសលត្តិកនិយតទុកៈ ។**

# កុសលត្តិកសឧត្តរទុកៈ

[ ៥៨១ ] កុសលធម៌ ប្រកបដោយឧត្តរៈ ( ការរើឡើងនូវខ្លួន ) អាស្រ័យនូវកុសលធម៌ ប្រកបដោយឧត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រកបដោយឧត្តរៈ អាស្រ័យនូវអកុសលធម៌ ប្រកបដោយឧត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រកបដោយឧត្តរៈ អាស្រ័យនូវអព្យាកតធម៌ ប្រកបដោយឧត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៨២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៥៨៣ ] កុសលធម៌ប្រកបដោយឧត្តរៈ ជាបច្ច័យនៃកុសលធម៌ប្រកបដោយឧត្តរៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ប្រកបដោយឧត្តរៈ ជាបច្ច័យនៃអកុសលធម៌ ប្រកបដោយឧត្តរៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រកបដោយឧត្តរៈ ជាបច្ច័យនៃអព្យាកតធម៌ ប្រកបដោយឧត្តរៈ ដោយហេតុប្បច្ច័យ ។

[ ៥៨៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

[ ៥៨៥ ] កុសលធម៌ មិនមានឧត្តរៈ អាស្រ័យនូវកុសលធម៌ មិនមានឧត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមានឧត្តរៈ អាស្រ័យនូវអព្យាកតធម៌មិនមានឧត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៨៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៥៨៧ ] កុសលធម៌ មិនមានឧត្តរៈ ជាបច្ច័យនៃកុសលធម៌ មិនមានឧត្តរៈ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមានឧត្តរៈ ជាបច្ច័យនៃអព្យាកតធម៌ មិនមានឧត្តរៈ ដោយហេតុប្បច្ច័យ ។

[ ៥៨៨ ] អព្យាកតធម៌ មិនមានឧត្តរៈ ជាបច្ច័យនៃអព្យាកតធម៌ មិនមានឧត្តរៈ ដោយអារម្មណប្បច្ច័យ អព្យាកតធម៌ មិនមានឧត្តរៈ ជាបច្ច័យ

នៃកុសលធម៌ មិនមានឧត្តរៈ ដោយអារម្មណប្បច្ច័យ ។

[ ៥៨៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ កុសលត្តិកសឧត្តរទុកៈ ។**

## កុសលត្តិកសរណទុកៈ

[ ៥៩០ ] អកុសលធម៌ ប្រកបដោយរណៈ ( លាមក ) អាស្រ័យនូវអកុសលធម៌ ប្រកបដោយរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៩១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៥៩២ ] កុសលធម៌ មិនមានរណៈ អាស្រ័យនូវកុសលធម៌ មិនមានរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមានរណៈ អាស្រ័យនូវអព្យាកតធម៌ មិនមានរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមានរណៈ អាស្រ័យនូវកុសលធម៌

មិនមានរណៈផង នូវអព្យាកតធម៌មិនមានរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៩៣ ] កុសលធម៌ មិនមានរណៈ អាស្រ័យនូវកុសលធម៌ មិនមានរណៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អព្យាកតធម៌មិនមានរណៈ អាស្រ័យនូវអព្យាកតធម៌ មិនមានរណៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៥៩៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៥៩៥ ] កុសលធម៌ មិនមានរណៈ ជាបច្ច័យនៃកុសលធម៌ មិនមានរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមានរណៈ ជាបច្ច័យនៃអព្យាកតធម៌ មិនមានរណៈ ដោយហេតុប្បច្ច័យ ។

[ ៥៩៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា

បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ កុសលត្តិកសរណទុកៈ ។**

# វេទនាត្តិកសរណាទុកៈ

[ ៥៩៧ ] ធម៌ដែលសម្បយុត្តដោយសុខវេទនា ប្រកបដោយរណៈ អាស្រ័យនូវធម៌ ដែលសម្បយុត្តដោយសុខវេទនា ប្រកបដោយរណៈ ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។ ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា ប្រកបដោយរណៈ អាស្រ័យនូវធម៌ ដែលសម្បយុត្តដោយទុក្ខវេទនា ប្រកបដោយរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ ប្រកបដោយរណៈ អាស្រ័យនូវធម៌ ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ ប្រកបដោយរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៩៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៥៩៩ ] ធម៌ដែលសម្បយុត្តដោយសុខវេទនា ប្រកបដោយរណៈ ជាបច្ច័យនៃធម៌ ដែលសម្បយុត្តដោយសុខវេទនា ប្រកបដោយរណៈ ដោយហេតុប្បច្ច័យ ។ ធម៌ដែលសម្បយុត្តដោយទុក្ខវេទនា ប្រកបដោយរណៈ ជាបច្ច័យនៃធម៌ ដែលសម្បយុត្តដោយទុក្ខវេទនា ប្រកបដោយរណៈ ដោយហេតុប្បច្ច័យ ។ ធម៌ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ ប្រកបដោយរណៈ ជាបច្ច័យនៃធម៌ ដែលសម្បយុត្តដោយវេទនា មិនជាទុក្ខមិនជាសុខ ប្រកបដោយរណៈ ដោយហេតុប្បច្ច័យ ។

[ ៦០០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៦០១ ] ធម៌ដែលសម្បយុត្តដោយសុខវេទនា មិនមានរណៈ អាស្រ័យនូវធម៌ដែលសម្បយុត្តដោយសុខវេទនា មិនមានរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ មិនមានរណៈ អាស្រ័យនូវធម៌ដែលសម្បយុត្តដោយវេទនា មិនជាទុក្ខមិនជាសុខ មិនមានរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦០២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦០៣ ] ធម៌ដែលសម្បយុត្តដោយសុខវេទនា មិនមានរណៈ ជាបច្ច័យនៃធម៌ ដែលសម្បយុត្តដោយសុខវេទនា មិនមានរណៈ ដោយហេតុប្បច្ច័យ ។ ធម៌ដែលសម្បយុត្តដោយវេទនា មិនជាទុក្ខមិនជាសុខ មិនមានរណៈ ជាបច្ច័យនៃធម៌ ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខ មិនជាសុខ មិនមានរណៈ ដោយហេតុប្បច្ច័យ ។

[ ៦០៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ

យ៉ាងនោះចុះ ។

**ចប់ វេទនាត្តិកសរណទុកៈ ។**

# វិបាកត្តិកសរណទុកៈ

[ ៦០៥ ] ធម៌មានវិបាកធម៌ជាប្រក្រតី ជាសរណៈ អាស្រ័យនូវធម៌មានវិបាកធម៌ជាប្រក្រតី ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦០៦ ] ក្នុងហេតុប្បច្ច័យមានវារៈ ១ ក្នុងអវិគតប្បច្ច័យមានវារៈ ១ ។ ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[ ៦០៧ ] វិបាកធម៌ជាអរណៈ អាស្រ័យនូវវិបាកធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានវិបាកធម៌ជាប្រក្រតី ជាអរណៈ អាស្រ័យនូវធម៌ មានវិបាកធម៌ជាប្រក្រតី ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអរណៈ អាស្រ័យនូវធម៌មិនមែនជាវិបាកទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ វិបាកធម៌ ជាអរណៈ អាស្រ័យនូវធម៌ជាវិបាកជាអរណៈផង មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអរណៈ អាស្រ័យនូវ

ធម៌មានវិបាកធម៌ជាប្រក្រតី ជាអរណៈផង មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦០៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦០៩ ] វិបាកធម៌ ជាអរណៈ ជាបច្ច័យនៃវិបាកធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មានវិបាកធម៌ជាប្រក្រតី ជាអរណៈ ជាបច្ច័យនៃធម៌ មានវិបាកធម៌ជាប្រក្រតី ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអរណៈ ជាបច្ច័យនៃធម៌មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ ជាប្រក្រតី ជាអរណៈ ដោយហេតុប្បច្ច័យ ។

[ ៦១០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ
យ៉ាងនោះដែរ ។

**ចប់ វិបាកត្តិកសរណទុកៈ ។**

# ឧបាទិន្នុបាទានិយទុកៈ

[ ៦១១ ] អនុបាទិន្នុបាទានិយធម៌ ( ធម៌ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ) ប្រកបដោយរណៈ អាស្រ័យនូវអនុបាទិន្នុបាទានិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦១២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៦១៣ ] ឧបាទិន្នុបាទានិយធម៌ ( ធម៌ដែលកម្មប្រកបដោយកិលេសកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ) ជាអរណៈ ( មិនមានកិលេស ) អាស្រ័យនូវឧបាទិន្នុបាទានិយធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អនុបាទិន្នុបាទានិយធម៌ ជាអរណៈ អាស្រ័យនូវអនុបាទិន្នុបាទានិយធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អនុបាទិន្នអនុបាទានិយធម៌ ជាអរណៈ អាស្រ័យនូវអនុបាទិន្នអនុបាទានិយធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦១៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦១៥ ] ឧបាទិន្នុបាទានិយធម៌ជាអរណៈ ជាបច្ច័យនៃឧបាទិន្នុបាទានិយធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អនុបាទិន្នុបាទានិយធម៌ ជាអរណៈ ជាបច្ច័យនៃអនុបាទិន្នុបាទានិយធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ ។ អនុបាទិន្នអនុបាទានិយធម៌ ជាអរណៈ ជាបច្ច័យនៃអនុបាទិន្នអនុបាទានិយធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦១៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ ឧបាទិន្នត្តិកសរណទុកៈ ។**

# សង្កិលិដ្ឋត្តិកសរណទុកៈ

[ ៦១៧ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ( ធម៌ដែលសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មង ) ជាសរណៈ អាស្រ័យនូវសង្កិលិដ្ឋសង្កិលេសិកធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦១៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី

បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៦១៩ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ( ធម៌ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង ) ជាអរណៈ អាស្រ័យនូវអសង្កិលិដ្ឋសង្កិលេសិកធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាអរណៈ អាស្រ័យនូវអសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាអរណៈ អាស្រ័យនូវអសង្កិលិដ្ឋសង្កិលេសិកធម៌ ជាអរណៈផង នូវអសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦២០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦២១ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាអរណៈ ជាបច្ច័យនៃអសង្កិលិដ្ឋសង្កិលេសិកធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ ។ អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាអរណៈ ជាបច្ច័យនៃអសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦២២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ សន្ទិដ្ឋិលិដ្ឋត្តិកសរណទុកៈ ។**

# វិតក្កត្តិកសរណទុកៈ

[ ៦២៣ ] សវិតក្កសវិចារធម៌ ជាសរណៈ អាស្រ័យនូវសវិតក្កសវិចារធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អវិតក្កវិចារមត្តធម៌ ជាសរណៈ អាស្រ័យនូវសវិតក្កសវិចារធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ សវិតក្កសវិចារធម៌ ជាសរណៈក្តី អវិតក្កវិចារមត្តធម៌ ជាសរណៈក្តី អាស្រ័យនូវសវិតក្កសវិចារធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ សវិតក្កសវិចារធម៌ ជាសរណៈ អាស្រ័យនូវអវិតក្កវិចារមត្តធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ សវិតក្កសវិចារធម៌ជាសរណៈ អាស្រ័យនូវសវិតក្កសវិចារធម៌ ជាសរណៈ ផង នូវអវិតក្កវិចារមត្តធម៌ ជាសរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦២៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី

មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

[ ៦២៥ ] សវិតក្កសវិចារធម៌ ជាអរណៈ អាស្រ័យនូវសវិតក្កសវិចារធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៧ ។ អវិតក្កវិចារមត្តធម៌ ជាអរណៈ អាស្រ័យនូវអវិតក្កវិចារមត្តធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។ អវិតក្កអវិចារធម៌ ជាអរណៈ អាស្រ័យនូវអវិតក្កអវិចារធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦២៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣៧ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ វិតក្កត្តិកសរណទុកៈ ។**

# បីតិត្តិកសរណទុកៈ

[ ៦២៧ ] បីតិសហគតធម៌ ជាសរណៈ អាស្រ័យនូវបីតិសហគតធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ សុខសហគតធម៌ ជាសរណៈ អាស្រ័យនូវសុខសហគតធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ឧបេក្ខាសហគតធម៌ ជាសរណៈ អាស្រ័យនូវឧបេក្ខាសហគតធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេ-

តុប្បច្ច័យ ។ បីតិសហគតធម៌ ជាសរណៈ អាស្រ័យនូវបីតិសហគតធម៌ ជាសរណៈផង នូវសុខសហគតធម៌ ជាសរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦២៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១០ ក្នុងអវិគតប្បច្ច័យ មានវារៈ ១០ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦២៩ ] បីតិសហគតធម៌ ជាសរណៈ ជាបច្ច័យនៃបីតិសហគតធម៌ ជាសរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ សុខសហគតធម៌ ជាសរណៈ ជាបច្ច័យនៃសុខសហគតធម៌ជាសរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ ឧបេក្ខាសហគតធម៌ ជាសរណៈ ជាបច្ច័យនៃឧបេក្ខាសហគតធម៌ ជាសរណៈ ដោយហេតុប្បច្ច័យ មានវារៈ ១ ។ បីតិសហគតធម៌ ជាសរណៈក្តី សុខសហគតធម៌ ជាសរណៈក្តី ជាបច្ច័យនៃបីតិសហគតធម៌ ជាសរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៣០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១០ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ១០ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

[ ៦៣១ ] បីតិសហគតធម៌ ជាអរណៈ អាស្រ័យនូវបីតិសហគតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៣២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១០ ក្នុងអវិគតប្បច្ច័យ មានវារៈ ១០ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានបញ្ហាចំនួនប៉ុណ្ណោះដែរ ។

**ចប់ បីតិត្តិកសរណទុកៈ ។**

# ទស្សនត្តិកសរណទុកៈ

[ ៦៣៣ ] ទស្សនេនបហាតព្វធម៌ជាសរណៈ អាស្រ័យនូវទស្សនេនបហាតព្វធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ភាវនាយបហាតព្វធម៌ ជាសរណៈ អាស្រ័យនូវភាវនាយបហាតព្វធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៣៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
មានសេចក្តីពិស្តារគ្រប់បច្ច័យទាំងអស់ ។

[ ៦៣៥ ] នេវទស្សនេនភាវនាយបហាតព្វធម៌ ជាអរណៈ អាស្រ័យនូវនេវទស្សនេនភាវនាយបហាតព្វធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៣៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ

១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
សុទ្ធតែមានវារៈ ១ ។

**ចប់ ទស្សនត្តិកសរណទុកៈ ។**

## ទស្សនេនបហាតព្វហេតុកត្តិកសរណទុកៈ

[ ៦៣៧ ] អាស្រ័យនូវទស្សនេនបហាតព្វហេតុកធម៌ ជាសរណៈ... អាស្រ័យនូវភាវនាយបហាតព្វហេតុកធម៌ ជាសរណៈ... នូវទស្សនេនកាវនាយបហាតព្វហេតុកធម៌ ជាសរណៈ អាស្រ័យនូវនៅទស្សនេនភាវនាយបហាតព្វហេតុកធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

**ចប់ ទស្សនេនបហាតព្វហេតុកត្តិកសរណទុកៈ ។**

## អាចយគាមិត្តិកសរណទុកៈ

[ ៦៣៨ ] អាចយគាមិធម៌ ( ធម៌ដល់នូវការសន្សំកពូនឡើងដោយកម្មកិលេស ) ជាសរណៈ អាស្រ័យនូវអាចយគាមិធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៣៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៦៤០ ] អាចយគាមិធម៌ ជាអរណៈ អាស្រ័យនូវអាចយគាមិធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អបចយគាមិធម៌ ( ធម៌មិនដល់នូវការសន្សំកពូនឡើង ) ជាអរណៈ អាស្រ័យនូវអបចយគាមិធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ នេវាចយគាមិនាបចយគាមិធម៌ ( ធម៌មិនមែនជាដល់នូវការសន្សំកពូនឡើង និងធម៌មិនមែនជាមិនដល់នូវការសន្សំកពូនឡើង ) ជាអរណៈ អាស្រ័យនូវនេវាចយគាមិនាបចយគាមិធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នេវាចយគាមិនាបចយគាមិធម៌ ជាអរណៈ អាស្រ័យនូវអាចយគាមិធម៌ ជាអរណៈផង នូវនេវាចយគាមិនាបចយគាមិធម៌ ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នេវាចយគាមិនាបចយគាមិធម៌ ជាអរណៈ អាស្រ័យនូវអបចយគាមិធម៌ ជាអរណៈផង នូវនេវាចយគាមិនាបចយធម៌ ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៤១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។
សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦៤២ ] អាចយគាមិធម៌ ជាអរណៈ ជាបច្ច័យនៃអាចយគាមិធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អបចយគាមិធម៌ ជាអរណៈ

ជាបច្ច័យនៃអបចយគាមិធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ នេវាចយគាមិនាបចយគាមិធម៌ ជាអរណៈ ជាបច្ច័យនៃនេវាចយគាមិនាបចយគាមិធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ ។

[ ៦៤៣ ] អាចយគាមិធម៌ ជាអរណៈ ជាបច្ច័យនៃអាចយគាមិធម៌ ជាអរណៈ ដោយអារម្មណប្បច្ច័យ ។

[ ៦៤៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ អាចយគាមិត្តិកសរណទុកៈ ។**

## សេក្ខត្តិកសរណទុកៈ

[ ៦៤៥ ] នេវសេក្ខានាសេក្ខធម៌ ( ធម៌មិនមែនជារបស់សេក្ខបុគ្គល និងមិនមែនជារបស់អសេក្ខបុគ្គល ) ជាសរណៈ អាស្រ័យនូវនេវសេក្ខានាសេក្ខធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៤៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៦៤៧ ] សេក្ខធម៌ជាអរណៈ អាស្រ័យនូវសេក្ខធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ នេវសេក្ខានាសេក្ខធម៌ ជាអរណៈ អាស្រ័យនូវសេក្ខធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ សេក្ខធម៌ ជាអរណៈក្តី នេវសេក្ខានាសេក្ខធម៌ ជាអរណៈក្តី អាស្រ័យនូវសេក្ខធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អសេក្ខធម៌ ជាអរណៈ អាស្រ័យនូវអសេក្ខធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ នេវសេក្ខានាសេក្ខធម៌ ជាអរណៈ អាស្រ័យនូវនេវសេក្ខានាសេក្ខធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៤៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦៤៩ ] សេក្ខធម៌ ជាអរណៈ ជាបច្ច័យនៃសេក្ខធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អសេក្ខធម៌ ជាអរណៈ ជាបច្ច័យនៃអសេក្ខធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ នេវសេក្ខានាសេក្ខធម៌ ជាអរណៈ ជាបច្ច័យនៃនេវសេក្ខានាសេក្ខធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ ។

[ ៦៥០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៥ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៨ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ
យ៉ាងនោះចុះ ។

**ចប់ សេក្ខត្តិកសរណទុកៈ ។**

# បរិត្តត្តិកសរណទុកៈ

[ ៦៥១ ] បរិត្តធម៌ ( ធម៌មានសភាពតូចឆ្មារ ) ជាសរណៈ អាស្រ័យនូវបរិត្តធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៥២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៦៥៣ ] បរិត្តធម៌ ជាអរណៈ អាស្រ័យនូវបរិត្តធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ មហគ្គតធម៌ ( ធម៌ដល់នូវសភាពដ៏ធំ ) ជាអរណៈ អាស្រ័យនូវមហគ្គតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អប្បមាណធម៌ ( ធម៌មានប្រមាណមិនបាន ) ជាអរណៈ អាស្រ័យនូវអប្បមាណធម៌ជាអរណៈ ទើប

កើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ បរិត្តធម៌ជាអរណៈ អាស្រ័យនូវបរិត្តធម៌ ជាអរណៈផង នូវមហគ្គតធម៌ ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ បរិត្តធម៌ជាអរណៈ អាស្រ័យនូវបរិត្តធម៌ ជាអរណៈផង នូវអប្បមាណធម៌ ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៥៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី មានសេចក្តីពិស្តារ
គ្រប់បច្ច័យទាំងអស់ ។

**ចប់ បរិត្តត្តិកសរណទុកៈ ។**

## បរិត្តារម្មណត្តិកសរណទុកៈ

[ ៦៥៥ ] បរិត្តារម្មណធម៌ ( ធម៌មានអារម្មណ៍តូចឆ្មារ ) ជាសរណៈ អាស្រ័យនូវបរិត្តារម្មណធម៌ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មហគ្គតារម្មណធម៌ ( ធម៌មានអារម្មណ៍ដល់នូវសភាពដ៏ធំ ) ជាសរណៈ អាស្រ័យនូវមហគ្គតារម្មណធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៥៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ

២ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

[ ៦៥៧ ] បរិត្តារម្មណធម៌ ជាអរណៈ អាស្រ័យនូវបរិត្តារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មហគ្គតារម្មណធម៌ ជាអរណៈ អាស្រ័យនូវមហគ្គតារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អប្បមាណារម្មណធម៌ ជាអរណៈ អាស្រ័យនូវអប្បមា-ណារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៥៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

**ចប់ បរិត្តារម្មណត្តិកសរណទុកៈ ។**

## ហីនត្តិកសរណទុកៈ

[ ៦៥៩ ] ហីនធម៌ ( ធម៌ថោកទាប ) ជាសរណៈ អាស្រ័យនូវហីនធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៦០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ៦៦១ ] មជ្ឈិមធម៌ ( ធម៌យ៉ាងកណ្តាល ) ជាអរណៈ អាស្រ័យនូវមជ្ឈិមធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បណីតធម៌ ( ធម៌ឧត្តម ) ជាអរណៈ អាស្រ័យនូវបណីតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ មជ្ឈិមធម៌ជាអរណៈ អាស្រ័យនូវមជ្ឈិមធម៌ ជាអរណៈផង នូវបណីតធម៌ ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៦២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

**ចប់ ហីនត្តិកសរណទុកៈ ។**

# មិច្ឆត្តត្តិកសរណទុកៈ

[ ៦៦៣ ] មិច្ឆត្តនិយតធម៌ ( ធម៌មានសភាពខុសនិងទៀង ) ជាសរណៈ អាស្រ័យនូវមិច្ឆត្តនិយតធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អនិយតធម៌ ( ធម៌មិនទៀង ) ជាសរណៈ អាស្រ័យនូវអនិយតធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៦៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ

២ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

[ ៦៦៥ ] សម្មត្តនិយតធម៌ ( ធម៌មានសភាពត្រូវនិងទៀង ) ជាអរណៈ អាស្រ័យនូវសម្មត្តនិយតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អនិយតធម៌ ជាអរណៈ អាស្រ័យនូវសម្មត្តនិយតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ សម្មត្តនិយតធម៌ ជាអរណៈក្តី អនិយតធម៌ ជាអរណៈក្តី អាស្រ័យនូវសម្មត្តនិយតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អនិយតធម៌ ជាអរណៈ អាស្រ័យនូវអនិយតធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អនិយតធម៌ ជាអរណៈ អាស្រ័យនូវសម្មត្តនិយតធម៌ ជាអរណៈផង នូវអនិយតធម៌ ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៦៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ មិច្ឆត្តត្តិកសរណទុកៈ ។**

# មគ្គារម្មណត្តិកសរណទុកៈ

[ ៦៦៧ ] មគ្គារម្មណធម៌ ( ធម៌មានមគ្គជាអារម្មណ៍ ) ជាអរណៈ អាស្រ័យនូវមគ្គារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ មគ្គហេតុកធម៌ ( ធម៌មានមគ្គជាហេតុ ) ជាអរណៈ អាស្រ័យនូវមគ្គហេតុកធម៌ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ មគ្គាធិបតិធម៌ ( ធម៌មានមគ្គជាអធិបតិ ) ជាអរណៈ អាស្រ័យនូវមគ្គាធិបតិធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។ មគ្គារម្មណធម៌ ជាអរណៈ អាស្រ័យនូវមគ្គារម្មណធម៌ ជាអរណៈផង នូវមគ្គាធិបតិធម៌ ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ មគ្គហេតុកធម៌ ជាអរណៈ អាស្រ័យនូវមគ្គហេតុកធម៌ ជាអរណៈផង នូវមគ្គាធិបតិធម៌ ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៦៦៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៧ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦៦៩ ] មគ្គារម្មណធម៌ ជាអរណៈ ជាបច្ច័យនៃមគ្គារម្មណធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ មគ្គហេតុកធម៌ ជាអរណៈ ជាបច្ច័យនៃមគ្គហេតុកធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ មគ្គាធិបតិធម៌ ជាអរណៈ ជាបច្ច័យនៃមគ្គាធិបតិធម៌ ជាអរណៈ ដោយហេ-

តុប្បច្ច័យ មានវារៈ ៥ ។

[ ៦៧០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៧ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ មគ្គារម្មណត្តិកសរណទុកៈ ។**

## ឧប្បន្នត្តិកសរណទុកៈ

[ ៦៧១ ] ឧប្បន្នធម៌ ( ធម៌កើតឡើងហើយ ) ជាសរណៈ ជាបច្ច័យនៃឧប្បន្នធម៌ ជាសរណៈ ដោយហេតុប្បច្ច័យ ។

[ ៦៧២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ៦៧៣ ] ឧប្បន្នធម៌ ជាអរណៈ ជាបច្ច័យនៃឧប្បន្នធម៌ ជាសរណៈ ដោយហេតុប្បច្ច័យ ។

[ ៦៧៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

**ចប់ ឧប្បន្នត្តិកសរណទុកៈ ។**

# អតីតត្តិកសរណទុកៈ

[ ៦៧៥ ] បច្ចុប្បន្នធម៌ ( ធម៌ជាបច្ចុប្បន្ន ) ជាសរណៈ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ជាសរណៈ ដោយហេតុប្បច្ច័យ ។

[ ៦៧៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ៦៧៧ ] បច្ចុប្បន្នធម៌ ជាអរណៈ ជាបច្ច័យនៃបច្ចុប្បន្នធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ ។

[ ៦៧៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ អតីតត្តិកសរណទុកៈ ។**

# អតីតារម្មណត្តិកសរណទុកៈ

[ ៦៧៩ ] អតីតារម្មណធម៌ ( ធម៌មានអារម្មណ៍កន្លងហើយ ) ជាសរណៈ អាស្រ័យនូវអតីតារម្មណធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អនាគតារម្មណធម៌ ( ធម៌មានអារម្មណ៍មិនទាន់មកដល់ ) ជាសរណៈ អាស្រ័យនូវអនាគតារម្មណធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បច្ចុប្បន្នារម្មណធម៌ ( ធម៌មានអារម្មណ៍កើតឡើង

ចំពោះមុខ ) ជាសរណៈ អាស្រ័យនូវបច្ចុប្បន្នារម្មណធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៨០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិត
គប្បីឲ្យពិស្តារគ្រប់បច្ច័យទាំងអស់ចុះ ។

[ ៦៨១ ] អតីតារម្មណធម៌ ជាអរណៈ អាស្រ័យនូវអតីតារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អនាគតារម្មណធម៌ ជាអរណៈ អាស្រ័យនូវអនាគតារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បច្ចុប្បន្នារម្មណធម៌ ជាអរណៈ អាស្រ័យនូវបច្ចុប្បន្នា-រម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៨២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦៨៣ ] អតីតារម្មណធម៌ ជាអរណៈ ជាបច្ច័យនៃអតីតារម្មណធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ ។ អនាគតារម្មណធម៌ ជាអរណៈ ជាបច្ច័យនៃអនាគតារម្មណធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ ។ បច្ចុប្បន្នារម្មណ-ធម៌ ជាអរណៈ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ ជាអរណៈ ដោយហេ-តុប្បច្ច័យ ។

[ ៦៨៤ ] អតីតារម្មណធម៌ ជាអរណៈ ជាបច្ច័យ នៃអតីតារម្មណធម៌ ជាអរណៈ ដោយអារម្មណប្បច្ច័យ ។

[ ៦៨៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ អតីតារម្មណត្តិកសរណទុកៈ ។**

## អជ្ឈត្តត្តិកសរណទុកៈ

[ ៦៨៦ ] អជ្ឈត្តធម៌ ( ធម៌ខាងក្នុង ) ជាសរណៈ អាស្រ័យនូវអជ្ឈត្តធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ពហិទ្ធាធម៌ ( ធម៌ខាងក្រៅ ) ជាសរណៈ អាស្រ័យនូវពហិទ្ធាធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៨៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

[ ៦៨៨ ] អជ្ឈត្តធម៌ ជាអរណៈ អាស្រ័យនូវអជ្ឈត្តធម៌ ជាអរណៈ

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ពហិទ្ធាធម៌ ជាអរណៈ អាស្រ័យនូវ ពហិទ្ធាធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៨៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

**ចប់ អជ្ឈត្តត្តិកសរណទុកៈ ។**

## អជ្ឈត្តារម្មណត្តិកសរណទុកៈ

[ ៦៩០ ] អជ្ឈត្តារម្មណធម៌ជាសរណៈ អាស្រ័យនូវអជ្ឈត្តារម្មណធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ពហិទ្ធារម្មណធម៌ ជាសរណៈ អាស្រ័យនូវពហិទ្ធារម្មណធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៩១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

[ ៦៩២ ] អជ្ឈត្តារម្មណធម៌ ជាអរណៈ អាស្រ័យនូវអជ្ឈត្តារម្មណធម៌

ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ពហិទ្ធារម្មណធម៌ ជាអរណៈ អាស្រ័យនូវពហិទ្ធារម្មណធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦៩៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

**ចប់ អជ្ឈត្តារម្មណត្តិកសរណទុកៈ ។**

## សនិទស្សនត្តិកសរណទុកៈ

[ ៦៩៤ ] អនិទស្សនអប្បដិឃធម៌ ( ធម៌មិនមានការឃើញនិងមិនមានការប៉ះពាល់ ) ជាសរណៈ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១ ។

[ ៦៩៥ ] អនិទស្សនអប្បដិឃធម៌ ជាអរណៈ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១៧ ។

[ ៦៩៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២១ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦៩៧ ] អនិទស្សនអប្បដិឃធម៌ជាអរណៈ ជាបច្ច័យនៃអនិទស្សនអប្បដិឃធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ ។

[ ៦៩៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ២៥ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ សនិទស្សនត្តិកសរណទុកៈ ។**

**ចប់ អនុលោមត្តិកទុកប្បដ្ឋាន ។**

# អនុលោមត្តិកត្តិកប្បដ្ឋាន
# កុសលត្តិកវេទនាត្តិកៈ

[ ៦៩៩ ] ធម៌ជាកុសល ប្រកបដោយសុខវេទនា អាស្រ័យនូវធម៌ ជាកុសលធម៌ ប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអកុសលប្រកបដោយសុខវេទនា អាស្រ័យនូវធម៌ជាអកុសល ប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈ ប្រកបដោយសុខវេទនា អាស្រ័យនូវធម៌ជាអព្យាកតៈ ប្រកបដោយសុខ-វេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧០០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៧០១ ] ធម៌ជាកុសល ប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ជាកុសល ប្រកបដោយសុខវេទនា ដោយហេតុប្បច្ច័យ ។ ធម៌ជាអកុសល ប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ជាអកុសលប្រកបដោយសុខវេទនា ដោយហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈ ប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ជាអព្យាកតៈ ប្រកបដោយសុខវេទនា ដោយហេតុប្បច្ច័យ ។

[ ៧០២ ] ធម៌ជាកុសល ប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ជាកុសលប្រកបដោយសុខវេទនា ដោយអារម្មណប្បច្ច័យ ។

[ ៧០៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៩ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៧០៤ ] ធម៌ជាអកុសល ប្រកបដោយទុក្ខវេទនា អាស្រ័យនូវធម៌ជាអកុសល ប្រកបដោយទុក្ខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧០៥ ] ធម៌ជាអកុសល ប្រកបដោយទុក្ខវេទនា អាស្រ័យនូវធម៌ជាអកុសល ប្រកបដោយទុក្ខវេទនា ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ ធម៌ជាអព្យាកតៈប្រកបដោយទុក្ខវេទនា អាស្រ័យនូវធម៌ជាអព្យាកតៈប្រកបដោយទុក្ខវេទនា ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៧០៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៧០៧ ] ធម៌ជាអកុសល ប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ ជាអកុសល ប្រកបដោយទុក្ខវេទនា ដោយហេតុប្បច្ច័យ ។

[ ៧០៨ ] ធម៌ជាអកុសល ប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ជាអកុសលប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ ។ ធម៌ជាអព្យាកតៈប្រកបដោយទុក្ខវេទនា ជាបច្ច័យនៃធម៌ជាអកុសល ប្រកបដោយទុក្ខវេទនា ដោយអារម្មណប្បច្ច័យ ។

[ ៧០៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ២ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៧១០ ] ធម៌ជាកុសល ប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខ អាស្រ័យនូវធម៌ជាកុសល ប្រកបដោយវេទនាមិនជាទុក្ខមិនជាសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអកុសល ប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខ អាស្រ័យនូវធម៌ ជាអកុសលប្រកបដោយវេទនាមិនជាទុក្ខមិនជាសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈ ប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខ អាស្រ័យនូវធម៌ ជាអព្យាកតៈ ប្រកបដោយវេទនាមិនជាទុក្ខមិនជាសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧១១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៧១២ ] ធម៌ជាកុសល ប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខ ជាបច្ច័យនៃធម៌ ជាកុសល ប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខ ដោយហេតុប្បច្ច័យ ។ ធម៌ជាអកុសល ប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខ ជាបច្ច័យនៃធម៌ជាអកុសល ប្រកបដោយវេទនាមិនជាទុក្ខមិនជាសុខ ដោយហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈ ប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខ ជាបច្ច័យនៃធម៌ជាអព្យាកតៈប្រកបដោយវេទនា មិនជាទុក្ខមិនជាសុខ ដោយ

ហេតុប្បច្ច័យ ។

[ ៧១៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ កុសលត្តិកវេទនាត្តិកៈ ។**

# កុសលត្តិកវិបាកត្តិកៈ

[ ៧១៤ ] វិបាកធម៌ជាអព្យាកតៈ អាស្រ័យនូវវិបាកធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧១៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៧១៦ ] ធម៌មានវិបាកជាប្រក្រតី ជាកុសល អាស្រ័យនូវធម៌ មានវិបាកជាប្រក្រតី ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មានវិបាកជាប្រក្រតីជាអកុសល អាស្រ័យនូវធម៌មានវិបាកជាប្រក្រតី ជាអកុ-

សល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧១៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៧១៨ ] ធម៌មានវិបាកជាប្រក្រតី ជាកុសល ជាបច្ច័យនៃធម៌មានវិបាកជាប្រក្រតី ជាកុសល ដោយហេតុប្បច្ច័យ ។ ធម៌មានវិបាកជាប្រក្រតី ជាអកុសល ជាបច្ច័យនៃធម៌មានវិបាកជាប្រក្រតី ជាអកុសល ដោយហេតុប្បច្ច័យ ។

[ ៧១៩ ] ធម៌មានវិបាកជាប្រក្រតីជាកុសល ជាបច្ច័យនៃធម៌មានវិបាកជាប្រក្រតី ជាកុសល ដោយអារម្មណប្បច្ច័យ ធម៌មានវិបាកជាប្រក្រតី ជាកុសល ជាបច្ច័យនៃធម៌ មានវិបាកជាប្រក្រតី ជាអកុសល ដោយអារម្មណប្បច្ច័យ ។ ធម៌មានវិបាកជាប្រក្រតី ជាអកុសល ជាបច្ច័យនៃធម៌មានវិបាកជាប្រក្រតី ជាអកុសល ដោយអារម្មណប្បច្ច័យ ។ ធម៌មានវិបាក ជាប្រក្រតី ជាអកុសល ជាបច្ច័យនៃធម៌មានវិបាកជាប្រក្រតី ជាកុសល ដោយអារម្មណប្បច្ច័យ ។

[ ៧២០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៧២១ ] ធម៌ មិនមែនជាវិបាក ទាំងមិនមែនមានវិបាកជាប្រក្រតី ជាអព្យាកតៈ អាស្រ័យនូវធម៌មិនមែនជាវិបាក ទាំងមិនមែនមានវិបាកជាប្រ-ក្រតី ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧២២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

**ចប់ កុសលត្តិកវិបាកត្តិកៈ ។**

# កុសលត្តិកឧបាទិន្នត្តិកៈ

[ ៧២៣ ] ធម៌ដែលកម្មប្រកបដោយកិលេស ( មានតណ្ហាជាដើម ) កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ជាអព្យាកតៈ អាស្រ័យនូវធម៌ ដែលកម្មប្រកបដោយកិលេសកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧២៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី

បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៧២៥ ] ធម៌ជាកុសល ដែលកម្មប្រកបដោយកិលេស ( មានតណ្ហាជាដើម ) មិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន អាស្រ័យនូវធម៌ជាកុសល ដែលកម្មប្រកបដោយកិលេសកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអកុសល ដែលកម្មប្រកបដោយកិលេស មិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន អាស្រ័យនូវធម៌ជាកុសល ដែលកម្មប្រកបដោយកិលេស មិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអព្យាកតៈ ដែលកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន អាស្រ័យនូវធម៌ ជាអព្យាកតៈ ដែលកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧២៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៧២៧ ] ធម៌ជាកុសល ដែលកម្មប្រកបដោយកិលេស មិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃធម៌ជាកុសល ដែលកម្មប្រកបដោយកិលេស មិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន

ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអកុសល ដែលកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃធម៌ជាអកុសល ដែលកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអព្យាកតៈ ដែលកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃធម៌ជាអព្យាកតៈ ដែលកម្មប្រកបដោយកិលេស មិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ដោយហេតុប្បច្ច័យ ។

[ ៧២៨ ] ធម៌ជាកុសល ដែលកម្មប្រកបដោយកិលេស មិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃធម៌ជាកុសល ដែលកម្មប្រកបដោយកិលេស មិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអកុសល ដែលកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃធម៌ជាអកុសល ដែលកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអព្យាកតៈ ដែលកម្មប្រកបដោយកិលេស មិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ជាបច្ច័យនៃធម៌ ជាអព្យាកតៈ ដែលកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៧២៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១១ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៧៣០ ] ធម៌ជាកុសល ដែលកម្មប្រកបដោយកិលេស មិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន អាស្រ័យនូវធម៌ជាកុសល ដែលកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈដែលកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន អាស្រ័យនូវធម៌ជាអព្យាកតៈ ដែលកម្មប្រកបដោយកិលេសមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៣១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

**ចប់ កុសលត្តិកឧបាទិន្នត្តិកៈ ។**

# កុសលត្តិកសង្កិលិដ្ឋត្តិកៈ

[ ៧៣២ ] ធម៌ជាអកុសលដែលសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មង

អាស្រ័យនូវធម៌ ជាអកុសល ដែលសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៣៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៧៣៤ ] ធម៌ជាអកុសល ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង អាស្រ័យនូវធម៌ជាកុសល ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអព្យាកតៈ ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង អាស្រ័យនូវធម៌ជាអព្យាកតៈ ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៣៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

ក្នុងសហជាតវារៈក្តី ក្នុងបញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

[ ៧៣៦ ] ធម៌ជាកុសល ដែលមិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង អាស្រ័យនូវធម៌ជាកុសល ដែលមិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៣៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
បណ្ឌិតគប្បីឲ្យពិស្តារ គ្រប់បច្ច័យទាំងអស់ចុះ ។
**ចប់ កុសលត្តិកសង្កិលិដ្ឋត្តិកៈ ។**

# កុសលត្តិកវិតក្កត្តិកៈ

[ ៧៣៨ ] ធម៌ជាកុសល ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ អាស្រ័យនូវធម៌ ជាកុសល ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអកុសល ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ អាស្រ័យនូវធម៌ជាអកុសល ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ អាស្រ័យនូវធម៌ជាអព្យាកតៈ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៣៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៧៤០ ] ធម៌ជាកុសល ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ជាបច្ច័យនៃធម៌ជាកុសលប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ដោយហេតុប្បច្ច័យ ។ ធម៌ជាអកុសលប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ជាបច្ច័យនៃធម៌ ជាអកុសល ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ដោយហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ជាបច្ច័យនៃធម៌ជាអព្យាកតៈ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ដោយហេតុប្បច្ច័យ ។

[ ៧៤១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា

បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៧៤២ ] ធម៌ជាកុសល មិនមានវិតក្កៈ មានត្រឹមតែវិចារៈ អាស្រ័យនូវធម៌ជាកុសល មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ អាស្រ័យនូវធម៌ ជាអព្យាកតៈមិនមានវិតក្កៈ មានត្រឹមតែវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៤៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ

២ ។

ក្នុងសហជាតវារៈក្តី សម្បយុត្តវារៈក្តី បញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

[ ៧៤៤ ] ធម៌ជាកុសល មិនមានវិតក្កៈ ទាំងមិនមានវិចារៈ អាស្រ័យនូវធម៌ជាកុសល មិនមានវិតក្កៈ ទាំងមិនមានវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអព្យាកតៈ មិនមានវិតក្កៈ ទាំងមិនមានវិចារៈ អាស្រ័យនូវធម៌ជាអព្យាកតៈមិនមានវិតក្កៈ ទាំងមិនមានវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៤៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

**ចប់ កុសលត្តិកវិតក្កត្តិកៈ ។**

# កុសលត្តិកបីតិត្តិកៈ

[ ៧៤៦ ] ធម៌ជាកុសល ប្រកបដោយបីតិ អាស្រ័យនូវធម៌ ជាកុសល ប្រកបដោយបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអកុសល ប្រកបដោយបីតិ អាស្រ័យនូវធម៌ជាអកុសល ប្រកបដោយបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈ ប្រកបដោយបីតិ អាស្រ័យ

នូវធម៌ជាអព្យាកតៈ ប្រកបដោយបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៤៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៧៤៨ ] ធម៌ជាកុសល ប្រកបដោយបីតិ ជាបច្ច័យនៃធម៌ ជាកុសល ប្រកបដោយបីតិ ដោយហេតុប្បច្ច័យ ។ ធម៌ជាអកុសល ប្រកបដោយបីតិ ជាបច្ច័យនៃធម៌ ជាអកុសល ប្រកបដោយបីតិ ដោយហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈ ប្រកបដោយបីតិ ជាបច្ច័យនៃធម៌ជាអព្យាកតៈ ប្រកបដោយបីតិ ដោយហេតុប្បច្ច័យ ។

[ ៧៤៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៧៥០ ] ធម៌ជាកុសលប្រកបដោយសុខ អាស្រ័យនូវធម៌ ជាកុសល ប្រកបដោយសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអកុសល ប្រកបដោយសុខ អាស្រ័យនូវធម៌ជាអកុសលប្រកបដោយសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈ ប្រកបដោយសុខ អាស្រ័យនូវធម៌ជាអព្យាកតៈ ប្រកបដោយសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៥១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៧៥២ ] ធម៌ជាកុសល ប្រកបដោយឧបេក្ខា អាស្រ័យនូវធម៌ ជាកុសល ប្រកបដោយឧបេក្ខា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអកុសល ប្រកបដោយឧបេក្ខា អាស្រ័យនូវធម៌ ជាអកុសល ប្រកបដោយឧបេក្ខា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈប្រកបដោយឧបេក្ខា អាស្រ័យនូវធម៌ ជាអព្យាកតៈ ប្រកបដោយឧបេក្ខា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៥៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

**ចប់ កុសលត្តិកប្បីតិត្តិកៈ ។**

# កុសលត្តិកទស្សនត្តិកៈ

[ ៧៥៤ ] ធម៌ជាអកុសល ដែលត្រូវលះដោយទស្សនៈ អាស្រ័យនូវធម៌ ជាអកុសល ដែលត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេ-

តុប្បច្ច័យ ។

[ ៧៥៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៧៥៦ ] ធម៌ជាអកុសល ដែលត្រូវលះដោយភាវនា អាស្រ័យនូវធម៌ជាអកុសលដែលត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៥៧ ] ធម៌ជាកុសល ដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនត្រូវលះដោយភាវនា អាស្រ័យនូវធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៥៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

**ចប់ កុសលត្តិកទស្សនត្តិកៈ ។**

## កុសលត្តិកទស្សនេនបហាតព្វហេតុកត្តិកៈ

[ ៧៥៩ ] ធម៌ជាអកុសល មានហេតុដែលត្រូវលះដោយទស្សនៈ អា-

ស្រ័យនូវធម៌ ជាអកុសល មានហេតុដែលត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៦០ ] ធម៌ជាអកុសល មានហេតុដែលត្រូវលះដោយភាវនា អាស្រ័យនូវធម៌ជាអកុសល មានហេតុដែលត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៦១ ] ធម៌ជាកុសលមានហេតុ ដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនត្រូវលះដោយភាវនា អាស្រ័យនូវធម៌ជាកុសល មានហេតុដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៦២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី

មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

**ចប់ កុសលត្តិកទស្សនេនបហាតព្វហេតុកត្តិកៈ ។**

# កុសលត្តិកអាចយគាមិត្តិកៈ

[ ៧៦៣ ] ធម៌ជាកុសល ដល់នូវការសន្សំកពូនឡើង ( ដោយកម្មកិលេស ) អាស្រ័យនូវធម៌ជាកុសល ដល់នូវការសន្សំកពូនឡើង ទើបកើត

ឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអកុសល ដល់នូវការសន្សំកពូនឡើង អាស្រ័យនូវធម៌ ជាអកុសល ដល់នូវការសន្សំកពូនឡើង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៦៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

[ ៧៦៥ ] ធម៌ជាកុសល មិនដល់នូវការសន្សំកពូនឡើង អាស្រ័យនូវធម៌ជាកុសល មិនដល់នូវការសន្សំកពូនឡើង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

ក្នុងបច្ច័យទាំងអស់ ក្នុងបដិច្ចវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៧៦៦ ] ធម៌ជាអព្យាកតៈ មិនមែនដល់នូវការសន្សំកពូនឡើង និងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង អាស្រ័យនូវធម៌ ជាអព្យាកតៈ មិនមែនដល់នូវការសន្សំកពូនឡើង និងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៦៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

**ចប់ កុសលត្តិកអាចយគាមិត្តិកៈ ។**

# កុសលត្តិកសេក្ខត្តិកៈ

[ ៧៦៨ ] សេក្ខធម៌ជាកុសល អាស្រ័យនូវសេក្ខធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៦៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

[ ៧៧០ ] អសេក្ខធម៌ជាអព្យាកតៈ អាស្រ័យនូវអសេក្ខធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៧១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៧៧២ ] នេវសេក្ខានាសេក្ខធម៌ ( ធម៌មិនមែនជារបស់សេក្ខបុគ្គល និងមិនមែនជារបស់អសេក្ខបុគ្គល ) ជាកុសល អាស្រ័យនូវនេវសេក្ខានាសេក្ខធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ នេវសេក្ខានាសេក្ខធម៌ ជាអកុសល អាស្រ័យនូវនេវសេក្ខានាសេក្ខធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ នេវសេក្ខានាសេក្ខធម៌ ជាអព្យាកតៈ អាស្រ័យនូវនេវសេក្ខានាសេក្ខធម៌ ជាអព្យាកតៈ

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៧៧៣ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៧៧៤ ] នេវសេក្ខានាសេក្ខធម៌ ជាកុសល ជាបច្ច័យនៃនេវសេក្ខានាសេក្ខធម៌ ជាកុសល ដោយហេតុប្បច្ច័យ ។

[ ៧៧៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ កុសលត្តិកសេក្ខត្តិកៈ**

# កុសលត្តិកបរិត្តត្តិកៈ

[ ៧៧៦ ] បរិត្តធម៌ ( មានសភាពតូចឆ្មារ ) ជាកុសល អាស្រ័យនូវបរិត្តធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ បរិត្តធម៌ជាអព្យាកតៈ អាស្រ័យនូវបរិត្តធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ បរិត្តធម៌ជាកុសលក្តី បរិត្តធម៌ជាអព្យាកតៈក្តី អាស្រ័យនូវបរិត្តធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បរិត្តធម៌ជាអកុសល អាស្រ័យនូវបរិត្តធម៌

ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ បរិត្តធម៌ជាអព្យាកតៈ អាស្រ័យនូវបរិត្តធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បរិត្តធម៌ ជាអព្យាកតៈ អាស្រ័យនូវបរិត្តធម៌ជាកុសលផង នូវបរិត្តធម៌ ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បរិត្តធម៌ជាអព្យាកតៈ អាស្រ័យនូវបរិត្តធម៌ ជាអកុសលផង នូវបរិត្តធម៌ ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៧៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៧៧៨ ] បរិត្តធម៌ជាកុសល ជាបច្ច័យនៃបរិត្តធម៌ ជាកុសល ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ បរិត្តធម៌ ជាអកុសល ជាបច្ច័យនៃបរិត្តធម៌ជាអកុសល ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ បរិត្តធម៌ ជាអព្យាកតៈជាបច្ច័យនៃបរិត្តធម៌ ជាអព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ៧៧៩ ] បរិត្តធម៌ជាកុសល ជាបច្ច័យនៃបរិត្តធម៌ជាកុសល ដោយអារម្មណប្បច្ច័យ ។

[ ៧៨០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈយ៉ាងណា

បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៧៨១ ] មហគ្គតធម៌ ( ធម៌ដល់នូវសភាពធំ ) ជាកុសល អាស្រ័យនូវមហគ្គតធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មហគ្គតធម៌ជាអព្យាកតៈ អាស្រ័យនូវមហគ្គកតធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៨២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

[ ៧៨៣ ] អប្បមាណធម៌ ( ធម៌ប្រមាណមិនបាន ) ជាកុសល អាស្រ័យនូវអប្បមាណធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អប្បមាណធម៌ជាអព្យាកតៈ អាស្រ័យនូវអប្បមាណធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៨៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

**ចប់ កុសលត្តិកបរិត្តត្តិកៈ ។**

# កុសលត្តិកបរិត្តារម្មណត្តិកៈ

[ ៧៨៥ ] បរិត្តារម្មណធម៌ ( ធម៌មានអារម្មណ៍តូចឆ្មារ ) ជាកុសល អាស្រ័យនូវបរិត្តារម្មណធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បរិត្តារម្មណធម៌ជាអកុសល អាស្រ័យនូវបរិត្តារម្មណធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បរិត្តារម្មណធម៌ ជាអព្យាកតៈ អាស្រ័យនូវបរិត្តារម្មណធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៨៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៧៨៧ ] មហគ្គតារម្មណធម៌ ( ធម៌មានអារម្មណ៍ដល់នូវសភាពធំ ) ជាកុសល អាស្រ័យនូវមហគ្គតារម្មណធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មហគ្គតារម្មណធម៌ ជាអកុសល អាស្រ័យនូវមហគ្គតា-រម្មណធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មហគ្គតា-រម្មណធម៌ជាអព្យាកតៈ អាស្រ័យនូវមហគ្គតារម្មណធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៨៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

[ ៧៨៩ ] អប្បមាណារម្មណធម៌ ( ធម៌មានអារម្មណ៍ប្រមាណមិនបាន ) ជាកុសល អាស្រ័យនូវអប្បមាណារម្មណធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អប្បមាណារម្មណធម៌ ជាអព្យាកតៈ អាស្រ័យនូវអប្បមាណារម្មណធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៩០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
មានសេចក្តីពិស្តារ គ្រប់បច្ច័យទាំងអស់ ។

**ចប់ កុសលត្តិកបរិត្តារម្មណត្តិក ។**

# កុសលត្តិកហីនត្តិកៈ

[ ៧៩១ ] ហីនធម៌ ( ធម៌ថោកទាប ) ជាអកុសល អាស្រ័យនូវហីនធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៩២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។ សេចក្តីពិស្តារ មានក្នុងបច្ច័យទាំងអស់ ។

[ ៧៩៣ ] មជ្ឈិមធម៌ ( ធម៌យ៉ាងកណ្តាល ) ជាកុសល អាស្រ័យនូវមជ្ឈិមធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មជ្ឈិមធម៌ជាអព្យាកតៈ អាស្រ័យនូវមជ្ឈិមធម៌ជាកុសល ទើបកើតឡើង ព្រោះហេ-

តុប្បច្ច័យ មជ្ឈិមធម៌ជាកុសលក្តី មជ្ឈិមធម៌ជាអព្យាកតៈក្តី អាស្រ័យនូវមជ្ឈិមធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មជ្ឈិមធម៌ជាអព្យាកតៈ អាស្រ័យនូវមជ្ឈិមធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មជ្ឈិមធម៌ជាអព្យាកតៈ អាស្រ័យនូវមជ្ឈិមធម៌ ជាកុសលផង នូវមជ្ឈិមធម៌ ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៧៩៤ ] មជ្ឈិមធម៌ជាកុសល អាស្រ័យនូវមជ្ឈិមធម៌ជាកុសល ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ មជ្ឈិមធម៌ជាអព្យាកតៈ អាស្រ័យនូវមជ្ឈិមធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[ ៧៩៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៧៩៦ ] មជ្ឈិមធម៌ ជាកុសល ជាបច្ច័យនៃមជ្ឈិមធម៌ ជាកុសល ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ មជ្ឈិមធម៌ ជាអព្យាកតៈ ជាបច្ច័យនៃមជ្ឈិមធម៌ ជាអព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ៧៩៧ ] មជ្ឈិមធម៌ ជាកុសល ជាបច្ច័យនៃមជ្ឈិមធម៌ ជាកុសល ដោយអារម្មណប្បច្ច័យ មជ្ឈិមធម៌ ជាកុសល ជាបច្ច័យនៃមជ្ឈិមធម៌ ជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ ។ មជ្ឈិមធម៌ ជាអព្យាកតៈ ជាបច្ច័យនៃមជ្ឈិមធម៌ ជាអព្យាកតៈ ដោយអារម្មណប្បច្ច័យ មជ្ឈិមធម៌ជាអព្យាកតៈ ជាបច្ច័យនៃមជ្ឈិមធម៌ ជាកុសល ដោយអារម្មណប្បច្ច័យ ។

[ ៧៩៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៧៩៩ ] បណីតធម៌ ( ធម៌ដ៏ឧត្តម ) ជាកុសល អាស្រ័យនូវបណីតធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ បណីតធម៌ជាអព្យាកតៈ អាស្រ័យនូវបណីតធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨០០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី
សេចក្តីពិស្តារ មានក្នុងបច្ច័យទាំងអស់ ។
**ចប់ កុសលត្តិកហីនត្តិកៈ ។**

# កុសលត្តិកមិច្ឆត្តត្តិកៈ

[ ៨០១ ] មិច្ឆត្តនិយតធម៌ ( ធម៌មានសភាពខុសនិងទៀង ) ជាកុសល អាស្រ័យនូវមិច្ឆត្តនិយតធម៌ជាអកុសល ទើបកើតឡើងព្រោះហេតុប្បច្ច័យ ។

[ ៨០២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ

១ ។ សេចក្ដីពិស្ដារ មានក្នុងបច្ច័យទាំងអស់ ។

[ ៨០៣ ] សម្មត្តនិយតធម៌ ( ធម៌មានសភាពត្រូវនិងទៀង ) ជាកុសល អាស្រ័យនូវសម្មត្តនិយតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨០៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្ដី

បញ្ហាវារៈក្ដី សុទ្ធតែមានវារៈ ១ ។

[ ៨០៥ ] អនិយតធម៌ ( ធម៌មិនទៀង ) ជាកុសល អាស្រ័យនូវអនិយតធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អនិយតធម៌ ជាអព្យាកតៈ អាស្រ័យនូវអនិយតធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អនិយតធម៌ ជាកុសលក្ដី អនិយតធម៌ ជាអព្យាកតៈក្ដី អាស្រ័យនូវអនិយតធម៌ជាកុសល ទើបកើតឡើង ដោយហេតុប្បច្ច័យ ។ អនិយតធម៌ ជាអកុសល អាស្រ័យនូវអនិយតធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អនិយតធម៌ ជាអព្យាកតៈ អាស្រ័យនូវអនិយតធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨០៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្ដី សម្បយុត្តវារៈក្ដី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៨០៧ ] អនិយតធម៌ ជាកុសល ជាបច្ច័យនៃអនិយតធម៌ ជាកុសល

ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អនិយតធម៌ ជាអកុសល ជាបច្ច័យនៃ អនិយតធម៌ ជាអកុសល ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អនិយតធម៌ ជាអព្យាកតៈ ជាបច្ច័យនៃអនិយតធម៌ ជាអព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ៨០៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ កុសលត្តិកមិច្ឆត្តត្តិកៈ ។**

# កុសលត្តិកមគ្គារម្មណត្តិកៈ

[ ៨០៩ ] មគ្គារម្មណធម៌ ( ធម៌មានមគ្គជាអារម្មណ៍ ) ជាកុសល អាស្រ័យនូវមគ្គារម្មណធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មគ្គារម្មណធម៌ជាអព្យាកតៈ អាស្រ័យនូវមគ្គារម្មណធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨១០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ សេចក្តីពិស្តារ មានក្នុងបច្ច័យទាំងអស់ ។

[ ៨១១ ] មគ្គហេតុកធម៌ ( ធម៌មានមគ្គជាហេតុ ) ជាកុសល អាស្រ័យនូវមគ្គហេតុកធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨១២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

[ ៨១៣ ] មគ្គាធិបតិធម៌ ( ធម៌មានមគ្គជាអធិបតិ ) ជាកុសល អាស្រ័យនូវមគ្គាធិបតិធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មគ្គាធិបតិធម៌ ជាអព្យាកតៈ អាស្រ័យនូវមគ្គាធិបតិធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨១៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ កុសលត្តិកមគ្គារម្មណត្តិកៈ ។**

# កុសលត្តិកឧប្បន្នត្តិកៈ

[ ៨១៥ ] ឧប្បន្នធម៌ ( ធម៌ដែលកើតឡើងហើយ ) ជាកុសល ជាបច្ច័យនៃឧប្បន្នធម៌ ជាកុសល ដោយហេតុប្បច្ច័យ មានវារៈ ៧ ។

**ចប់ កុសលត្តិកឧប្បន្នត្តិកៈ ។**

# កុសលត្តិកអតីតត្តិកៈ

[ ៨១៦ ] បច្ចុប្បន្នធម៌ ( ធម៌កើតឡើងចំពោះមុខ ) ជាកុសល ជាបច្ច័យនៃបច្ចុប្បន្នធម៌ ជាកុសល ដោយហេតុប្បច្ច័យ មានវារៈ ៧ ។

**ចប់ កុសលត្តិកអតីតត្តិកៈ ។**

# កុសលត្តិកអតីតារម្មណត្តិកៈ

[ ៨១៧ ] អតីតារម្មណធម៌ ( ធម៌មានអារម្មណ៍ជាអតីត ) ជាកុសល អាស្រ័យនូវអតីតារម្មណធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អតីតារម្មណធម៌ ជាអកុសល អាស្រ័យនូវអតីតារម្មណធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អតីតារម្មណធម៌ ជាអព្យាកតៈ អាស្រ័យនូវអតីតារម្មណធម៌ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨១៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៨១៩ ] អតីតារម្មណធម៌ ជាកុសល ជាបច្ច័យនៃអតីតារម្មណធម៌ ជាកុសល ដោយហេតុប្បច្ច័យ ។ អតីតារម្មណធម៌ ជាអកុសល ជាបច្ច័យនៃអតីតារម្មណធម៌ ជាអកុសល ដោយហេតុប្បច្ច័យ ។ អតីតារម្មណធម៌ ជាអព្យាកតៈ ជាបច្ច័យនៃអតីតារម្មណធម៌ជាអព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ៨២០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៨២១ ] អនាគតារម្មណធម៌ ( ធម៌មានអារម្មណ៍ជាអនាគត ) ជាកុសល អាស្រ័យនូវអនាគតារម្មណធម៌ ជាកុសល ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ ។

[ ៨២២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៨២៣ ] អនាគតារម្មណធម៌ជាកុសល ជាបច្ច័យនៃអនាគតារម្មណធម៌ ជាកុសល ដោយហេតុប្បច្ច័យ ។

[ ៨២៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៨២៥ ] បច្ចុប្បន្នារម្មណធម៌ ( ធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ) ជាកុសល អាស្រ័យនូវបច្ចុប្បន្នារម្មណធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨២៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៨២៧ ] បច្ចុប្បន្នារម្មណធម៌ ជាកុសល ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ជាកុសល ដោយហេតុប្បច្ច័យ ។ បច្ចុប្បន្នារម្មណធម៌ ជាអកុសល ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ជាអកុសល ដោយហេតុប្បច្ច័យ ។ បច្ចុប្បន្នា-

ម្មណធម៌ជាអព្យាកតៈ ជាបច្ច័យនៃបច្ចុប្បន្នារម្មណធម៌ជាអព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ៨២៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ កុសលត្តិកអតីតារម្មណត្តិកៈ ។**

# កុសលត្តិកអជ្ឈត្តត្តិកៈ

[ ៨២៩ ] អជ្ឈត្តធម៌ ( ធម៌ខាងក្នុង ) ជាកុសល អាស្រ័យនូវអជ្ឈត្តធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អជ្ឈត្តធម៌ ជាអកុសល អាស្រ័យនូវអជ្ឈត្តធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អជ្ឈត្តធម៌ ជាអព្យាកតៈ អាស្រ័យនូវអជ្ឈត្តធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៣០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនេះផងចុះ ។

[ ៨៣១ ] អជ្ឈត្តធម៌ ជាកុសល ជាបច្ច័យនៃអជ្ឈត្តធម៌ ជាកុសល ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អជ្ឈត្តធម៌ ជាអកុសល ជាបច្ច័យនៃអជ្ឈត្តធម៌ ជាអកុសល ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អជ្ឈត្តធម៌ ជាអព្យាកតៈ ជាបច្ច័យនៃអជ្ឈត្តធម៌ ជាអព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ៨៣២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៨៣៣ ] ធម៌ខាងក្រៅជាកុសល អាស្រ័យនូវធម៌ខាងក្រៅ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ខាងក្រៅ ជាអកុសល អាស្រ័យនូវធម៌ខាងក្រៅ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ខាងក្រៅ ជាអព្យាកតៈ អាស្រ័យនូវធម៌ខាងក្រៅ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៨៣៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៨៣៥ ] ធម៌ខាងក្រៅជាកុសល ជាបច្ច័យនៃធម៌ខាងក្រៅ ជាកុសល ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ខាងក្រៅ ជាអកុសល ជាបច្ច័យនៃធម៌ខាងក្រៅ ជាអកុសល ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ខាង

ក្រៅ ជាអព្យាកតៈ ជាបច្ច័យនៃធម៌ខាងក្រៅ ជាអព្យាកតៈ ដោយហេតុប្បច្ច័យ ។

[ ៨៣៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ កុសលត្តិកអជ្ឈត្តត្តិកៈ ។**

# កុសលត្តិកអជ្ឈត្តារម្មណត្តិកៈ

[ ៨៣៧ ] អជ្ឈត្តារម្មណធម៌ ( ធម៌មានអារម្មណ៍ខាងក្នុង ) ជាកុសល អាស្រ័យនូវអជ្ឈត្តារម្មណធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៣៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[ ៨៣៩ ] ពហិទ្ធារម្មណធម៌ ( ធម៌មានអារម្មណ៍ខាងក្រៅ ) ជាកុសល អាស្រ័យនូវពហិទ្ធារម្មណធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៤០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

**ចប់ កុសលត្តិកអជ្ឈត្តារម្មណត្តិកៈ ។**

# កុសលត្តិកសនិទស្សនត្តិកៈ

[ ៨៤១ ] អនិទស្សនសប្បដិឃធម៌ ( ធម៌មិនមានការឃើញតែប្រកប ដោយការប៉ះពាល់ ) ជាអព្យាកតៈ អាស្រ័យនូវអនិទស្សន សប្បដិឃធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៤២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៨៤៣ ] អនិទស្សនអប្បដិឃធម៌ ( ធម៌មិនមានការឃើញ ទាំងមិន មានការប៉ះពាល់ ) ជាកុសល អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ជា កុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អនិទស្សនអប្បដិឃធម៌ ជា អព្យាកតៈ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អនិទស្សនអប្បដិឃធម៌ ជាកុសលក្តី អនិទស្សនអប្បដិឃធម៌ ជាអព្យាកតៈក្តី អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អនិទស្សនអប្បដិឃធម៌ ជាអកុសល អាស្រ័យនូវអនិទស្សន អប្បដិឃធម៌ ជាអកុសល ទើបកើតឡើង ព្រោះ ហេតុប្បច្ច័យ មានវារៈ ៣ ។ អនិទស្សនអប្បដិឃធម៌ ជាអព្យាកតៈ អាស្រ័យនូវអនិទស្សនអប្បដិឃធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៤៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី បញ្ហាវារៈក្តី

បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

**ចប់ កុសលត្តិកសនិទស្សនត្តិកៈ ។**

## វេទនាត្តិកកុសលត្តិកៈ

[ ៨៤៥ ] ធម៌ជាកុសល ប្រកបដោយសុខវេទនា អាស្រ័យនូវធម៌ជាកុសល ប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាកុសល ប្រកបដោយវេទនាមិនមែនជាទុក្ខ មិនមែនជាសុខ អាស្រ័យនូវធម៌ជាកុសល ប្រកបដោយវេទនាមិនមែនជាទុក្ខ មិនមែនជាសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៤៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៨៤៧ ] ធម៌ជាកុសល ប្រកបដោយសុខវេទនា ជាបច្ច័យនៃធម៌ ជាកុសល ប្រកបដោយសុខវេទនា ដោយហេតុប្បច្ច័យ ។ ធម៌ជាកុសល ប្រកបដោយវេទនា មិនមែនជាទុក្ខមិនមែនជាសុខ ជាបច្ច័យនៃធម៌ជាកុសល ប្រកបដោយវេទនាមិនមែនជាទុក្ខ មិនមែនជាសុខ ដោយហេតុប្បច្ច័យ ។

[ ៨៤៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៤៩ ] ធម៌ជាអកុសល ប្រកបដោយសុខវេទនា អាស្រ័យនូវធម៌ជាអកុសល ប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអកុសល ប្រកបដោយទុក្ខវេទនា អាស្រ័យនូវធម៌ជាអកុសល ប្រកបដោយទុក្ខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអកុសល ប្រកបដោយវេទនា មិនមែនជាទុក្ខ មិនមែនជាសុខ អាស្រ័យនូវធម៌ជាអកុសល ប្រកបដោយវេទនា មិនមែនជាទុក្ខ មិនមែនជាសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៥០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៥១ ] ធម៌ជាអព្យាកតៈ ប្រកបដោយសុខវេទនា អាស្រ័យនូវធម៌ជាអព្យាកតៈ ប្រកបដោយសុខវេទនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអព្យាកតៈប្រកបដោយវេទនាមិនមែនជាទុក្ខ មិនមែនជាសុខ អាស្រ័យនូវធម៌ជាអព្យាកតៈ ប្រកបដោយវេទនាមិនមែនជាទុក្ខ មិនមែនជាសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៥២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

**ចប់ វេទនាត្តិកកុសលត្តិកៈ ។**

# វិបាកត្តិកកុសលត្តិកៈ

[ ៨៥៣ ] ធម៌មានវិបាកធម៌ជាប្រក្រតី ជាកុសល អាស្រ័យនូវធម៌មានវិបាកធម៌ជាប្រក្រតី ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៥៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ៨៥៥ ] ធម៌មានវិបាកធម៌ជាប្រក្រតី ជាអកុសល អាស្រ័យនូវធម៌មានវិបាកធម៌ជាប្រក្រតី ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៥៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

[ ៨៥៧ ] វិបាកធម៌ជាអព្យាកតៈ អាស្រ័យនូវវិបាកធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាវិបាកនិងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអព្យាកតៈ អាស្រ័យនូវធម៌ មិនមែនជាវិបាកនិងមិនមែនមានវិបាកធម៌ជាប្រក្រតីជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ វិបាកធម៌ជាអព្យាកតៈ អាស្រ័យនូវធម៌ ជាវិបាកជាអព្យាកតៈផង មិនមែនជាវិបាក និងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអព្យាកតៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៨៥៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ វិបាកត្តិកកុសលត្តិកៈ ។**

# ឧបាទិន្នត្តិកកុសលត្តិកៈ

[ ៨៥៩ ] អនុបាទិន្នុបាទានិយធម៌ ( ធម៌ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ និងជាប្រយោជន៍ដល់ឧបាទាន ) ជាកុសល អាស្រ័យនូវអនុបាទិន្នុបាទានិយធម៌ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៦០ ] អនុបាទិន្នុបាទានិយធម៌ ជាអកុសល អាស្រ័យនូវអនុបាទិន្នុ-បាទានិយធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៦១ ] ឧបាទិន្នុបាទានិយធម៌ ( ធម៌ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើម កាន់យកហើយ និងជាប្រយោជន៍ដល់ឧបាទាន ) ជាអព្យាកតៈ អាស្រ័យនូវឧបាទិន្នុបាទានិយធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អនុបាទិន្នុបាទានិយធម៌ ជាអព្យាកតៈ អាស្រ័យនូវអនុបាទិន្នុបាទានិយធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេ-តុប្បច្ច័យ មានវារៈ ១ ។ អនុបាទិន្នអនុបាទានិយធម៌ ( ធម៌ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើម មិនកាន់យកហើយ និងមិនជាប្រយោជន៍ដល់ឧបាទាន ) ជាអព្យាកតៈ អាស្រ័យនូវអនុបាទិន្នអនុបាទានិយធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៦២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

ចប់ ឧបាទិន្នត្តិកកុសលត្តិកៈ ។

## សង្កិលិដ្ឋត្តិកកុសលត្តិកៈ

[ ៨៦៣ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ( ធម៌ដែលមិនសៅហ្មង តែប្រកបដោយសេចក្តីសៅហ្មង ) ជាកុសល អាស្រ័យនូវអសង្កិលិដ្ឋសង្កិលេសិកធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អសង្កិលិដ្ឋអសង្កិលេសិកធម៌ ( ធម៌ដែលមិនសៅហ្មង ទាំងមិនប្រកបដោយសេចក្តីសៅហ្មង ) ជាកុសល អាស្រ័យនូវអសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ២ ។

[ ៨៦៤ ] សង្កិលិដ្ឋសង្កិលេសិកធម៌ ( ធម៌ដែលសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មង ) ជាអកុសល អាស្រ័យនូវសង្កិលិដ្ឋសង្កិលេសិកធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១ ។

[ ៨៦៥ ] អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាអព្យាកតៈ អាស្រ័យនូវអសង្កិលិដ្ឋសង្កិលេសិកធម៌ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ ។

**ចប់ សង្កិលិដ្ឋត្តិកកុសលត្តិកៈ ។**

## វិតក្កត្តិកកុសលត្តិកៈ

[ ៨៦៦ ] ធម៌ជាកុសល ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ អាស្រ័យនូវធម៌ ជាកុសល ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មាន

វារៈ ៣ ។ ធម៌ជាកុសល មិនមានវិតក្កៈ មានត្រឹមតែវិចារៈ អាស្រ័យនូវធម៌ជាកុសល មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៤ ។ ធម៌ជាកុសល មិនមានវិតក្កៈ ទាំងមិនមានវិចារៈ អាស្រ័យនូវធម៌ ជាកុសល មិនមានវិតក្កៈ ទាំងមិនមានវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៦៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១១ ។

[ ៨៦៨ ] ធម៌ជាអកុសល ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ អាស្រ័យនូវធម៌ជាអកុសល ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអកុសល ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ អាស្រ័យនូវធម៌ជាអកុសល មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៨៦៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ។

[ ៨៧០ ] ធម៌ជាអព្យាកតៈ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ អាស្រ័យនូវធម៌ ជាអព្យាកតៈ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣៧ ។

**ចប់ វិតក្កត្តិកកុសលត្តិកៈ ។**

# បីតិត្តិកកុសលត្តិកៈ

[ ៨៧១ ] ធម៌ជាកុសល ប្រកបដោយបីតិ អាស្រ័យនូវធម៌ ជាកុសល ប្រកបដោយបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាកុសល ប្រកបដោយសុខ អាស្រ័យនូវធម៌ជាកុសល ប្រកបដោយសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាកុសល ប្រកបដោយឧបេក្ខា អាស្រ័យនូវធម៌ជាកុសល ប្រកបដោយឧបេក្ខា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១០ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៧២ ] ធម៌ជាអកុសល ប្រកបដោយបីតិ អាស្រ័យនូវធម៌ ជាអកុសល ប្រកបដោយបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអកុសល ប្រកបដោយសុខ អាស្រ័យនូវធម៌ ជាអកុសល ប្រកបដោយសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអកុសល ប្រកបដោយឧបេក្ខា អាស្រ័យនូវធម៌ជាអកុសល ប្រកបដោយឧបេក្ខា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១០ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៧៣ ] ធម៌ជាអព្យាកតៈ ប្រកបដោយបីតិ អាស្រ័យនូវធម៌ ជាអព្យាកតៈ ប្រកបដោយបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាអព្យាកតៈ ប្រកបដោយសុខ អាស្រ័យនូវធម៌ ជាអព្យាកតៈ ប្រកបដោយសុខ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌

ជាអព្យាកតៈ ប្រកបដោយឧបេក្ខា អាស្រ័យនូវធម៌ ជាអព្យាកតៈ ប្រកបដោយឧបេក្ខា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១០ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ បីតិត្តិកកុសលត្តិកៈ ។**

# ទស្សនត្តិកកុសលត្តិកៈ

[ ៨៧៤ ] ធម៌ជាកុសល ដែលមិនមែនត្រូវលះដោយទស្សនៈ និងមិនមែនត្រូវលះដោយភាវនា អាស្រ័យនូវធម៌ជាកុសល ដែលមិនមែនត្រូវលះដោយទស្សនៈ និងមិនមែនត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១ ។

[ ៨៧៥ ] ធម៌ជាអកុសល ដែលត្រូវលះដោយទស្សនៈ អាស្រ័យនូវធម៌ជាអកុសល ដែលត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាកុសល ដែលត្រូវលះដោយភាវនា អាស្រ័យនូវធម៌ជាអកុសល ដែលត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៧៦ ] ធម៌ជាអព្យាកតៈ ដែលមិនមែនត្រូវលះដោយទស្សនៈ និងមិនមែនត្រូវលះដោយភាវនា អាស្រ័យនូវធម៌ ជាអព្យាកតៈ ដែលមិនមែនត្រូវលះដោយទស្សនៈនិងមិនមែនត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះ

ហេតុប្បច្ច័យ ។

មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

ចប់ ទស្សនត្តិកកុសលត្តិកៈ ។

## ទស្សនេនបហាតព្វហេតុកត្តិកកុសលត្តិកៈ

[ ៨៧៧ ] ធម៌ជាកុសល មានហេតុដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនត្រូវលះដោយភាវនា អាស្រ័យនូវធម៌ជាកុសល មានហេតុដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១ ។ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៧៨ ] ធម៌ជាអកុសល មានហេតុដែលត្រូវលះដោយទស្សនៈ អាស្រ័យនូវធម៌ជាអកុសល មានហេតុដែលត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាអកុសល មានហេតុដែលត្រូវលះដោយភាវនា អាស្រ័យនូវធម៌ជាអកុសលមានហេតុដែលត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ ។ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៧៩ ] ធម៌ជាអព្យាកតៈ មានហេតុ ដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនត្រូវលះដោយភាវនា អាស្រ័យនូវធម៌ ជាអព្យាកតៈ មាន

ហេតុដែលមិនមែនត្រូវលះដោយទស្សនៈ មិនមែនត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

ចប់ ទស្សនេនបហាតព្វហេតុកត្តិកកុសលត្តិកៈ ។

# អាចយគាមិត្តិកកុសលត្តិកៈ

[ ៨៨០ ] ធម៌ជាកុសល ដល់នូវការសន្សំកពូនឡើង អាស្រ័យនូវធម៌ជាកុសលដល់នូវការសន្សំកពូនឡើង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាកុសល មិនដល់នូវការសន្សំកពូនឡើង អាស្រ័យនូវធម៌ ជាកុសលមិនដល់នូវការសន្សំកពូនឡើង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៨១ ] ធម៌ជាអកុសល ដល់នូវការសន្សំកពូនឡើង អាស្រ័យនូវធម៌ ជាអកុសល ដល់នូវការសន្សំកពូនឡើង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៨៨២ ] ធម៌ជាអព្យាកតៈ មិនមែនដល់នូវការសន្សំកពូនឡើង និងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង អាស្រ័យនូវធម៌ ជាអព្យាកតៈ មិនមែនដល់នូវការសន្សំកពូនឡើង និងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំង

អស់ ។

ចប់ អាចយគាមិត្តិកកុសលត្តិកៈ ។

## សេក្ខត្តិកកុសលត្តិកៈ

[ ៨៨៣ ] សេក្ខធម៌ ( ធម៌ជារបស់សេក្ខបុគ្គល ) ជាកុសល អាស្រ័យនូវសេក្ខធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ នេវសេក្ខានាសេក្ខធម៌ ( ធម៌មិនមែនជារបស់សេក្ខបុគ្គល និងមិនមែនជារបស់អសេក្ខបុគ្គល ) ជាកុសល អាស្រ័យនូវនេវសេក្ខានាសេក្ខធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៨៤ ] នេវសេក្ខានាសេក្ខធម៌ជាអកុសល អាស្រ័យនូវនេវសេក្ខានាសេក្ខធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៨៨៥ ] សេក្ខធម៌ជាអព្យាកតៈ អាស្រ័យនូវសេក្ខធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៩ ។ បណ្ឌិតគប្បីឲ្យពិស្តារគ្រប់បច្ច័យទាំងអស់ផងចុះ ។

ចប់ សេក្ខត្តិកកុសលត្តិកៈ ។

# បរិត្តត្តិកកុសលត្តិកៈ

[ ៨៨៦ ] បរិត្តធម៌ ( ធម៌មានសភាពតូចឆ្មារ ) ជាកុសល អាស្រ័យនូវបរិត្តធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មហគ្គតធម៌ ( ធម៌ដល់នូវសភាពធំ ) ជាកុសល អាស្រ័យនូវមហគ្គតធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អប្បមាណធម៌ ( ធម៌ប្រមាណមិនបាន ) ជាកុសល អាស្រ័យនូវអប្បមាណធម៌ ជាកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៨៧ ] បរិត្តធម៌ ជាអកុសល អាស្រ័យនូវបរិត្តធម៌ ជាអកុសល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៨៨៨ ] បរិត្តធម៌ ជាអព្យាកតៈ អាស្រ័យនូវបរិត្តធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ មហគ្គតធម៌ ជាអព្យាកតៈ អាស្រ័យនូវមហគ្គតធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អប្បមាណធម៌ជាអព្យាកតៈ អាស្រ័យនូវអប្បមាណធម៌ ជាអព្យាកតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១៣ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ បរិត្តត្តិកកុសលត្តិកៈ ។**

# បរិត្តារម្មណត្តិកកុសលត្តិកៈ

[ ៨៨៩ ] កុសលធម៌ ជាបរិត្តារម្មណ៍ អាស្រ័យនូវកុសលធម៌ ជាបរិត្តារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ ជាមហគ្គតារម្មណ៍ អាស្រ័យនូវកុសលធម៌ ជាមហគ្គតារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ជាអប្បមាណារម្មណ៍ អាស្រ័យនូវកុសលធម៌ ជាអប្បមាណារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៩០ ] អកុសលធម៌ ជាបរិត្តារម្មណ៍ អាស្រ័យនូវអកុសលធម៌ ជាបរិត្តារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ជាមហគ្គតារម្មណ៍ អាស្រ័យនូវអកុសលធម៌ ជាមហគ្គតារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៩១ ] អព្យាកតធម៌ ជាបរិត្តារម្មណ៍ អាស្រ័យនូវអព្យាកតធម៌ ជាបរិត្តារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាមហគ្គតារម្មណ៍ អាស្រ័យនូវអព្យាកតធម៌ ជាមហគ្គតារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ជាអប្បមាណារម្មណ៍ អាស្រ័យនូវអព្យាកតធម៌ ជាអប្បមាណារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ៣ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

ចប់ បរិត្តារម្មណត្តិកកុសលត្តិកៈ ។

# ហីនត្តិកកុសលត្តិកៈ

[ ៨៩២ ] កុសលធម៌ ជាកណ្តាល អាស្រ័យនូវកុសលធម៌ជាកណ្តាល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ ដ៏ឧត្តម អាស្រ័យនូវកុសលធម៌ដ៏ឧត្តម ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៩៣ ] អកុសលធម៌ដ៏ថោកទាប អាស្រ័យនូវអកុសលធម៌ដ៏ថោកទាប ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៨៩៤ ] អព្យាកតធម៌ ជាកណ្តាល អាស្រ័យនូវអព្យាកតធម៌ ជាកណ្តាល ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ដ៏ឧត្តម អាស្រ័យនូវអព្យាកតធម៌ដ៏ឧត្តម ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ៥ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ ហីនត្តិកកុសលត្តិកៈ ។**

# មិច្ឆត្តត្តិកកុសលត្តិកៈ

[ ៨៩៥ ] កុសលធម៌ មានសភាពត្រូវនិងទៀង អាស្រ័យនូវកុសលធម៌មានសភាពត្រូវនិងទៀង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ មិនទៀង អាស្រ័យនូវកុសលធម៌ មិនទៀង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៩៦ ] អកុសលធម៌ មានសភាពខុសនិងទៀង អាស្រ័យនូវអកុសលធម៌ មានសភាពខុសនិងទៀង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌មិនទៀង អាស្រ័យនូវអកុសលធម៌ មិនទៀង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៨៩៧ ] អព្យាកតធម៌ មិនទៀង អាស្រ័យនូវអព្យាកតធម៌មិនទៀង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

**ចប់ មិច្ឆត្តត្តិកកុសលត្តិកៈ ។**

# មគ្គារម្មណត្តិកកុសលត្តិកៈ

[ ៨៩៨ ] កុសលធម៌ជាមគ្គារម្មណ៍ អាស្រ័យនូវកុសលធម៌ ជាមគ្គារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ កុសលធម៌ ជាមគ្គហេតុកៈ អាស្រ័យនូវកុសលធម៌ ជាមគ្គហេតុកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ កុសលធម៌ ជាមគ្គាធិបតិ អាស្រ័យនូវកុសលធម៌ ជាមគ្គាធិបតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១៧ ។

[ ៨៩៩ ] អព្យាកតធម៌ ជាមគ្គារម្មណ៍ អាស្រ័យនូវអព្យាកតធម៌ ជាមគ្គារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកត-

ធម៌ ជាមគ្គាធិបតិ អាស្រ័យនូវអព្យាកតធម៌ ជាមគ្គាធិបតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ៥ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ មគ្គារម្មណត្តិកកុសលត្តិកៈ ។**

# ឧប្បន្នត្តិកកុសលត្តិកៈ

[ ៩០០ ] កុសលធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃកុសលធម៌ ដែលកើតឡើងហើយ ដោយហេតុប្បច្ច័យ មានវារៈ ១ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៩០១ ] អកុសលធម៌ ដែលកើតឡើងហើយ ជាបច្ច័យនៃអកុសល-ធម៌ ដែលកើតឡើងហើយ ដោយហេតុប្បច្ច័យ មានវារៈ ១ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៩០២ ] អព្យាកតធម៌ដែលកើតឡើងហើយ ជាបច្ច័យនៃអព្យាកតធម៌ ដែលកើតឡើងហើយ ដោយហេតុប្បច្ច័យ មានវារៈ ១ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ ឧប្បន្នត្តិកកុសលត្តិកៈ ។**

# អតីតត្តិកកុសលត្តិកៈ

[ ៩០៣ ] កុសលធម៌ ជាបច្ចុប្បន្ន ជាបច្ច័យនៃកុសលធម៌ ជាបច្ចុប្បន្ន ដោយហេតុប្បច្ច័យ មានវារៈ ១ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៩០៤ ] អកុសលធម៌ជាបច្ចុប្បន្ន ជាបច្ច័យនៃអកុសលធម៌ ជាបច្ចុប្បន្ន ដោយហេតុប្បច្ច័យ មានវារៈ ១ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៩០៥ ] អព្យាកតធម៌ជាបច្ចុប្បន្ន ជាបច្ច័យនៃអព្យាកតធម៌ជាបច្ចុប្បន្ន ដោយហេតុប្បច្ច័យ មានវារៈ ១ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ អតីតត្តិកកុសលត្តិកៈ ។**

# អតីតារម្មណត្តិកកុសលត្តិកៈ

[ ៩០៦ ] កុសលធម៌ មានអារម្មណ៍ជាអតីត អាស្រ័យនូវកុសលធម៌ មានអារម្មណ៍ជាអតីត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ មានអារម្មណ៍ជាអនាគត អាស្រ័យនូវកុសលធម៌ មានអារម្មណ៍ជាអនាគត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន អាស្រ័យនូវកុសលធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៩០៧ ] អកុសលធម៌ មានអារម្មណ៍ជាអតីត អាស្រ័យនូវអកុ-

សលធម៌ មានអារម្មណ៍ជាអតីត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ មានអារម្មណ៍ជាអនាគត អាស្រ័យនូវអកុសលធម៌ មានអារម្មណ៍ជាអនាគត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន អាស្រ័យនូវអកុសលធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៩០៨ ] អព្យាកតធម៌ មានអារម្មណ៍ជាអតីត អាស្រ័យនូវអព្យាកតធម៌មានអារម្មណ៍ជាអតីត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មានអារម្មណ៍ជាអនាគត អាស្រ័យនូវអព្យាកតធម៌ មានអារម្មណ៍ជាអនាគត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌មានអារម្មណ៍ជាបច្ចុប្បន្ន អាស្រ័យនូវអព្យាកតធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ អតីតារម្មណត្តិកកុសលត្តិកៈ ។**

# អជ្ឈត្តត្តិកកុសលត្តិកៈ

[ ៩០៩ ] កុសលធម៌ខាងក្នុង អាស្រ័យនូវកុសលធម៌ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ខាងក្រៅ អាស្រ័យនូវកុសល-

ធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៩១០ ] អកុសលធម៌ខាងក្នុង អាស្រ័យនូវអកុសលធម៌ ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ខាងក្រៅ អាស្រ័យនូវអកុសលធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៩១១ ] អព្យាកតធម៌ខាងក្នុង អាស្រ័យនូវអព្យាកតធម៌ ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ខាងក្រៅ អាស្រ័យនូវអព្យាកតធម៌ខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ អជ្ឈត្តត្តិកកុសលត្តិកៈ ។**

# អជ្ឈត្តារម្មណត្តិកកុសលត្តិកៈ

[ ៩១២ ] កុសលធម៌ មានអារម្មណ៍ខាងក្នុង អាស្រ័យនូវកុសលធម៌ មានអារម្មណ៍ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ២ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៩១៣ ] អកុសលធម៌ មានអារម្មណ៍ខាងក្នុង អាស្រ័យនូវអកុសល-ធម៌ មានអារម្មណ៍ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ

២ ។ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៩១៤ ] អព្យាកតធម៌មានអារម្មណ៍ខាងក្នុង អាស្រ័យនូវអព្យាកតធម៌ មានអារម្មណ៍ខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ២ ។ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ អជ្ឈត្តារម្មណត្តិកកុសលត្តិកៈ ។**

# សនិទស្សនត្តិកកុសលត្តិកៈ

[ ៩១៥ ] កុសលធម៌ មិនមានការឃើញនិងមិនមានការប៉ះពាល់ អាស្រ័យនូវកុសលធម៌ មិនមានការឃើញ និងមិនមានការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៩១៦ ] អកុសលធម៌ មិនមានការឃើញ និងមិនមានការប៉ះពាល់ អាស្រ័យនូវអកុសលធម៌ មិនមានការឃើញ និងមិនមានការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៩១៧ ] អព្យាកតធម៌ មិនមានការឃើញតែប្រកបដោយការប៉ះពាល់ អាស្រ័យនូវអព្យាកតធម៌ មិនមានការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ១ អព្យាកតធម៌ ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ អាស្រ័យនូវអព្យាកតធម៌ មិនមានការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ

មានវារៈ ២ អព្យាកតធម៌ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ អាស្រ័យនូវអព្យាកតធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ អព្យាកតធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ក្តី អព្យាកតធម៌មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវអព្យាកតធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៤ អព្យាកតធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក្តី អព្យាកតធម៌ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវអព្យាកតធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៥ អព្យាកតធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ក្តី អព្យាកតធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក្តី អាស្រ័យនូវអព្យាកតធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៦ អព្យាកតធម៌ ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ក្តី អព្យាកតធម៌មិនមានការឃើញ តែប្រកបដោយការប៉ះពាល់ក្តី អព្យាកតធម៌មិនមានការឃើញ ទាំងមិនមានការប៉ះពាល់ក្តី អាស្រ័យនូវអព្យាកតធម៌មិនមានការឃើញ តែប្រកបដោយការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៧ ។ អព្យាកតធម៌ មិនមានការឃើញ ទាំងមិនមាន

ការប៉ះពាល់ អាស្រ័យនូវអព្យាកតធម៌ មិនមានការឃើញ ទាំងមិនមានការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៧ ។ អព្យាកតធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ អាស្រ័យនូវអព្យាកតធម៌ មិនមានការឃើញ តែប្រកបដោយការប៉ះពាល់ផង នូវអព្យាកតធម៌ មិនមានការឃើញ ទាំងមិនមានការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៧ ។

[ ៩១៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២១ ក្នុងអវិគតប្បច្ច័យ មានវារៈ ២១ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

**ចប់ សនិទស្សនត្តិកកុសលត្តិកៈ ។**

**ចប់ អនុលោមត្តិកត្តិកប្បដ្ឋាន ។**

## អនុលោមទុកទុកបច្ចដ្ឋាន

## ហេតុទុកសហេតុកទុកៈ

[ ៩១៩ ] ធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ជាហេតុទាំងប្រព្រឹត្តទៅជាមួយនឹងហេតុក្តី ធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក្តី អាស្រ័យនូវធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ជាហេតុទាំងប្រព្រឹត្តទៅជាមួយនឹងហេតុក្តី ធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក្តី អាស្រ័យនូវធម៌ មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ ជា

ហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុក្តី មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក្តី អាស្រ័យនូវធម៌ ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩២០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩២១ ] ធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះនអធិបតិប្បច្ច័យ ។

[ ៩២២ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៩ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៩ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៩ ។

[ ៩២៣ ] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ព្រោះហេតុប្បច្ច័យ ។

[ ៩២៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ព្រោះនអធិបតិប្បច្ច័យ ។

សហជាតវារៈក្តី បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៩២៥ ] ធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យនៃធម៌

ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយហេតុប្បច្ច័យ ធម៌ជាហេតុ ប្រ-ព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយហេតុប្បច្ច័យ ធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យនៃធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាហេតុ ប្រ-ព្រឹត្តទៅជាមួយនឹងហេតុផង ដោយហេតុប្បច្ច័យ ។

[ ៩២៦ ] ធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យនៃធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយអារម្មណប្បច្ច័យ ធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យនៃធម៌ មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយអារម្មណប្បច្ច័យ ធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យនៃធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុផង ដោយអារម្មណប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យនៃធម៌ មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយអារម្មណប្បច្ច័យ ធម៌មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យនៃធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយអារម្មណប្បច្ច័យ ធម៌មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ជាបច្ច័យនៃធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុផង ដោយអារម្មណប្បច្ច័យ ។ ធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុក្តី មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយអារម្មណប្បច្ច័យ

ធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុក្តី មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុក្តី ជាបច្ច័យនៃធម៌មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយអារម្មណប្បច្ច័យ ធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុក្តី មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុក្តី ជាបច្ច័យនៃធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុផង មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុផង ដោយអារម្មណប្បច្ច័យ ។

[ ៩២៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៩២៨ ] ធម៌មិនមែនជាហេតុ មិនមានហេតុ អាស្រ័យនូវធម៌ជាហេតុ មិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាហេតុ មិនមានហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាហេតុ មិនមានហេតុ អាស្រ័យនូវធម៌ជាហេតុ មិនមានហេតុផង មិនមែនជាហេតុ មិនមានហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩២៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៩៣០ ] ធម៌ជាហេតុ មិនមានហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ មិនមានហេតុ ដោយហេតុប្បច្ច័យ ។

[ ៩៣១ ] ធម៌ជាហេតុ មិនមានហេតុ ជាបច្ច័យនៃធម៌ជាហេតុ មិនមានហេតុ ដោយអារម្មណប្បច្ច័យ ធម៌ជាហេតុ មិនមានហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ មិនមានហេតុ ដោយអារម្មណប្បច្ច័យ ។ ធម៌មិនមែនជាហេតុ មិនមានហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ មិនមានហេតុ ដោយអារម្មណប្បច្ច័យ ធម៌មិនមែនជាហេតុ មិនមានហេតុ ជាបច្ច័យនៃធម៌ ជាហេតុ មិនមានហេតុ ដោយអារម្មណប្បច្ច័យ ។

[ ៩៣២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ ហេតុទុកសហេតុកទុកៈ ។**

## ហេតុទុកហេតុសម្បយុត្តទុកៈ

[ ៩៣៣ ] ធម៌ជាហេតុ ប្រកបដោយហេតុ អាស្រ័យនូវធម៌ ជាហេតុ ប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជា

ហេតុ ប្រកបដោយហេតុ អាស្រ័យនូវធម៌ជាហេតុ ប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាហេតុ ប្រកបដោយហេតុក្តី មិនមែនជាហេតុ ប្រកបដោយហេតុក្តី អាស្រ័យនូវធម៌ជាហេតុ ប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ប្រកបដោយហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាហេតុ ប្រកបដោយហេតុ អាស្រ័យនូវធម៌ជាហេតុ ប្រកបដោយហេតុផង មិនមែនជាហេតុ ប្រកបដោយហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៣៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

[ ៩៣៥ ] ធម៌ជាហេតុ ប្រកបដោយហេតុ ជាបច្ច័យនៃធម៌ជាហេតុ ប្រកបដោយហេតុ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៣៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៩៣៧ ] ធម៌មិនមែនជាហេតុ ប្រាសចាកហេតុ អាស្រ័យនូវធម៌ជាហេតុ ប្រាសចាកហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ប្រាសចាកហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ប្រាសចាកហេតុ

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ប្រាសចាកហេតុ អាស្រ័យនូវធម៌ជាហេតុ ប្រាសចាកហេតុផង មិនមែនជាហេតុ ប្រាសចាកហេតុផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៣៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរបណ្ឌិត

គប្បីឲ្យពិស្តារផងចុះ ។

[ ៩៣៩ ] ធម៌ជាហេតុ ប្រាសចាកហេតុ ជាបច្ច័យនៃធម៌មិនមែនជាហេតុ ប្រាសចាកហេតុ ដោយហេតុប្បច្ច័យ ។

[ ៩៤០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា

បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

**ចប់ ហេតុទុកហេតុសម្បយុត្តទុកៈ ។**

## ហេតុទុកហេតុសហេតុកទុកៈ

[ ៩៤១ ] ធម៌ជាហេតុ ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យនូវធម៌ជាហេតុ ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើត

ឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៩៤២ ] ធម៌មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ទាំងមិនមែនជាហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ទាំងមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

ចប់ ហេតុទុកហេតុសហេតុកទុកៈ ។

## ហេតុទុកហេតុហេតុសម្បយុត្តទុកៈ

[ ៩៤៣ ] ធម៌ជាហេតុ ជាហេតុ ទាំងប្រកបដោយហេតុ អាស្រ័យនូវធម៌ជាហេតុ ជាហេតុ ទាំងប្រកបដោយហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៩៤៤ ] ធម៌មិនមែនជាហេតុ ប្រកបដោយហេតុទាំងមិនមែនជាហេតុ អាស្រ័យនូវធម៌ មិនមែនជាហេតុ ប្រកបដោយហេតុ ទាំងមិនមែនជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

ចប់ ហេតុទុកហេតុហេតុសម្បយុត្តទុកៈ ។

## ហេតុទុកនហេតុសហេតុកទុកៈ

[ ៩៤៥ ] ធម៌មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ អាស្រ័យ

នូវធម៌ មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៩៤៦ ] ធម៌មិនមែនជាហេតុ មិនមានហេតុ អាស្រ័យនូវធម៌មិនមែនជាហេតុ មិនមានហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

**ចប់ ហេតុទុកនហេតុសហេតុកទុកៈ ។**

# ហេតុទុកសប្បច្ចយទុកៈ

[ ៩៤៧ ] ធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ អាស្រ័យនូវធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ អាស្រ័យនូវធម៌មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ អាស្រ័យនូវធម៌ ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យផង មិនមែនហេតុ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៤៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[ ៩៤៩ ] ធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ជាបច្ច័យនៃធម៌ជាហេតុ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ដោយហេតុប្បច្ច័យ ។

[ ៩៥០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

**ចប់ ហេតុទុកសប្បច្ចយទុកៈ ។**

## ហេតុទុកសង្ខតទុកៈ

[ ៩៥១ ] ធម៌ជាហេតុ ដែលបច្ច័យតាក់តែង អាស្រ័យនូវធម៌ជាហេតុ ដែលបច្ច័យតាក់តែង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៥២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ ( ទុកៈនេះ ) ប្រហែលគ្នានឹងសប្បច្ចយទុកៈដែរ ។

**ចប់ ហេតុទុកសង្ខតទុកៈ ។**

## ហេតុទុកសនិទស្សនទុកៈ

[ ៩៥៣ ] ធម៌ជាហេតុ មិនមានការឃើញ អាស្រ័យនូវធម៌ជាហេតុ មិនមានការឃើញ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាហេតុ មិនមានការឃើញ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិន

មានការឃើញ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាហេតុ មិនមានការឃើញ អាស្រ័យនូវធម៌ជាហេតុ មិនមានការឃើញផង មិនមែនជាហេតុ មិនមានការឃើញផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៥៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

**ចប់ ហេតុទុកសនិទស្សនទុកៈ ។**

# ហេតុទុកសប្បដិឃទុកៈ

[ ៩៥៥ ] ធម៌មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងការប៉ះពាល់ អាស្រ័យនូវធម៌ មិនមែនជាហេតុ ប្រព្រឹត្តទៅជាមួយនឹងការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៩៥៦ ] ធម៌ជាហេតុ មិនមានការប៉ះពាល់ អាស្រ័យនូវធម៌ ជាហេតុ មិនមានការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាហេតុ មិនមានការប៉ះពាល់ អាស្រ័យនូវធម៌ជាហេតុ មិនមានការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាហេតុ មិនមានការប៉ះពាល់ក្តី មិនមែនជាហេតុ មិនមានការប៉ះពាល់ក្តី អាស្រ័យនូវធម៌ជាហេតុ មិនមាន

ការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាហេតុ មិនមានការប៉ះពាល់ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមានការប៉ះពាល់ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាហេតុ មិនមានការប៉ះពាល់ អាស្រ័យនូវធម៌ជាហេតុ មិនមានការប៉ះពាល់ផង មិនមែនជាហេតុ មិនមានការប៉ះពាល់ផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៥៧ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

**ចប់ ហេតុទុកសប្បដិឃទុកៈ ។**

# ហេតុទុករូបីទុកៈ

[ ៩៥៨ ] ធម៌មិនមែនជាហេតុ មានរូប អាស្រ័យនូវធម៌ មិនមែនជាហេតុ មានរូប ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ មានវារៈ ១ គ្រប់បច្ច័យទាំងអស់ ។

[ ៩៥៩ ] ធម៌ជាហេតុ មិនមានរូប អាស្រ័យនូវធម៌ជាហេតុ មិនមានរូប ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាហេតុ មិនមានរូប អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមានរូប ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាហេតុ មិនមានរូប អា-

ស្រ័យនូវធម៌ជាហេតុ មិនមានរូបផង មិនមែនជាហេតុ មិនមានរូបផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៦០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

**ចប់ ហេតុទុករូបីទុកៈ ។**

## ហេតុទុកលោកិយទុកៈ

[ ៩៦១ ] ធម៌ជាហេតុ ជាលោកិយ អាស្រ័យនូវធម៌ជាហេតុ ជាលោកិយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាហេតុ ជាលោកិយ អាស្រ័យនូវធម៌ មិនមែនជាហេតុ ជាលោកិយ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាហេតុ ជាលោកិយ អាស្រ័យនូវធម៌ ជាហេតុ ជាលោកិយផង មិនមែនជាហេតុ ជាលោកិយផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៦២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិត
គប្បីឲ្យពិស្តារ យ៉ាងនេះផងចុះ ។

[ ៩៦៣ ] ធម៌ជាហេតុ ជាលោកុត្តរៈ អាស្រ័យនូវធម៌ជាហេតុ ជាលោកុត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាហេតុ ជាលោកុត្តរៈ អាស្រ័យនូវធម៌មិនមែនជាហេតុ ជាលោកុត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាហេតុ ជាលោកុត្តរៈ អាស្រ័យនូវធម៌ជាហេតុ ជាលោកុត្តរៈផង មិនមែនជាហេតុ ជាលោកុត្តរៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៦៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី បញ្ហាវារៈក្តី ប្រហែល
គ្មានទីងបដិច្ចវារៈដែរ បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

**ចប់ ហេតុទុកលោកិយទុកៈ ។**

## ហេតុទុកកេនចិវិញ្ញេយ្យទុកៈ

[ ៩៦៥ ] កេនចិវិញ្ញេយ្យធម៌ ( ធម៌ដែលបុគ្គលគប្បីដឹងច្បាស់ដោយវិញ្ញាណណានីមួយ ) ជាហេតុ អាស្រ័យនូវកេនចិវិញ្ញេយ្យធម៌ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៦៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។

[ ៩៦៧ ] កេនចិនវិញ្ញេយ្យធម៌ជាហេតុ អាស្រ័យនូវកេនចិនវិញ្ញេយ្យធម៌ ជាហេតុ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៦៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ ហេតុទុកកេនចិវិញ្ញេយ្យទុកៈ ។**

## ហេតុទុកអាសវទុកៈ

[ ៩៦៩ ] ធម៌ជាហេតុ ជាអាសវៈ អាស្រ័យនូវធម៌ជាហេតុ ជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌មិនមែនជាហេតុ ជាអាសវៈ អាស្រ័យនូវធម៌ជាហេតុ ជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ធម៌ជាហេតុ ជាអាសវៈក្តី មិនមែនជាហេតុ ជាអាសវៈក្តី អាស្រ័យនូវធម៌ ជាហេតុជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌មិនមែនជាហេតុ ជាអាសវៈ អាស្រ័យនូវធម៌ មិនមែនជាហេតុ ជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ជាហេតុ ជាអាសវៈ អាស្រ័យនូវធម៌ជាហេតុ ជាអាសវៈផង មិនមែនជាហេតុ ជាអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៧០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មាន

វារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៩៧១ ] ធម៌ជាហេតុ មិនមែនអាសវៈ អាស្រ័យធម៌ជាហេតុ មិនមែនអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌មិនមែនជាហេតុ មិនមែនអាសវៈ អាស្រ័យនូវធម៌ មិនមែនជាហេតុ មិនមែនអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ជាហេតុ មិនមែនអាសវៈ អាស្រ័យនូវធម៌ ជាហេតុ មិនមែនអាសវៈផង មិនមែនជាហេតុ មិនមែនអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[ ៩៧២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ ហេតុទុកអាសវទុកៈ ។**

## ហេតុទុកអាសវសម្បយុត្តទុកៈ

[ ៩៧៣ ] ធម៌ជាហេតុ ប្រកបដោយអាសវៈ អាស្រ័យនូវធម៌ជាហេតុ ប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៧៤ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ សេចក្តីពិស្តារ មានគ្រប់បច្ច័យទាំងអស់ ។

[ ៩៧៥ ] ធម៌ជាហេតុ ប្រាសចាកអាសវៈ អាស្រ័យនូវធម៌ជាហេតុ ប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៧៦ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។

**ចប់ ហេតុទុកអាសវសម្បយុត្តទុកៈ ។**

## ហេតុទុកអាសវសាសវទុកៈ

[ ៩៧៧ ] ធម៌ជាហេតុ ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យនូវធម៌ជាហេតុ ជាអាសវៈទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៩៧៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។ សេចក្ដីពិស្ដារ មានគ្រប់បច្ច័យទាំងអស់ ។

